KHIN Sok

# L'ANNEXION DU CAMBODGE PAR LES VIETNAMIENS AU XIX° SIÈCLE

## D'APRÈS LES DEUX POÈMES DU VÉNÉRABLE BÂTUM BARAMEY PICH

## រឿងកំពប់តែអុង



The Annexation of Cambodia by the Vietnamese
during the 19th Century.
Based on 2 Poems by Ven. Botum Boromei Pich



Ouvriers khmers en activités pendant les travaux du creusement du canal Prêk Yuan.
(*Sastra voat Kròch*, str. : 312-316)

Khmer workers digging the Prek Yuon canal



Ouvriers khmers noyés dans le canal de Prêk Yuan.
(*Sastra voat Kròch*, str. : 331-333)

Khmer workers drowned in the Prek Yuon canal



Arrestations et mise à mort des mandarins khmers par les Vietnamiens.
(*Sastra voat Kroch*, str. : 1007-1013)

Arrest and killing of Khmer officials by the Viets



Khmers jetés vivants dans une fosse commune par les Vietnamiens.
(*Satra lbaœk rôba khsat*, str. : 234-235)

Khmers buried alive in a mass grave





Scène de tortures subies par des enfants khmers dans la province de Baray.
(*Satra lbaœk rôba khsat*, str. : 232-234)

Torture of Khmer children in Baray province



Les têtes des enfants étaient utilisées comme trépied pour faire bouillir d'autres enfants.
(*Satra lbaœk rôba khsat*, str. : 233)

Children's head used as hearth for boiling water

# EDITION

# DU SASTRA VOAT KROCH

សាស្ត្រាវត្តក្រូច

Sastra Wat Kroch Edition

## សាស្រ្តាវត្តក្រូច ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម
(លេខ ១០៤៩)

1 ទុស្សករកុលិយោ[1] សិរោមេឱនអង្គអញ ភិវាទ[2]កោរព្ភ[3]
ពុទ្ធបាទកបកង់ចក្ក។

2 ព្រះបាទព្រះរាជភ្ញូវ កើតកបត្រូវព្រះលោយល័ក្ខ
មួយរយប្រាំបីជាក់ ជាពុំនាក់ភព្វបីបាន។

3 បង្គមគុនព្រះធម្ម តួដសូពាណោភៀត្រាយាន នាំសតសង្សាបាន
ត្រង់ត្រើយត្រានឥតអំពល់។

4 បង្គមគុនព្រះសង្ឃ សីលសីងទ្រង់ករុណាសល់
ជាស្រូវស្រែបុណ្យផល នាមតាកដល់ផ្ទល់សុក្ខា។

5 ហេតុនោះអង្គអញខ្ញុំ ក្រាបបង្គំគុនរតណា
សូមសុកសូមទីឃា យុយឺនយូរយស្សវែងឆ្ងាយ។

6 ដេជៈអង្គអញខ្ញុំក្រាប បង្គំបង្កេចក្យ សូមសុកសូមសប្បាយ
ដោយតេជព្រះរតណា។

7 បពិតរីសំណូម នោះខ្ញុំសូមសុំសបាទ សូមឆុតចំហុតប្រាកដ្ឋ
វៀងរូចដល់និព្វាន្ត។

8 ជាតិនេះខ្ញុំអាភ័ព្វ ឥតគេរាប់កំណើតប្រាន ជាតិក្រោយឲ្យខ្ញុំបាន
ទាន់ព្រះអង្គគុងធម្មា។

9 សូមទេពទាំងទិសទស ត្បូរសោឡសសោយសុក្ខា
រូចរាល់រាល់ព្រហ្មា សូមជួយជាញាណសក្ខីយ។

10 ឆ្នាំកុរសបស័ក្ក ហោមន្តជៀរជាក់ ចូល១០រោជឱ្យយ
ព្រហស្បត៍ឧតម្ព សានសំរិទ្ធិ ខែបុស្សពិតពៃយ

---

[1] Il faut lire ទសករកល្យេ du pali *dasa* + *kara* + *kalya* "dix+main+pur".

[2] Il faut lire អភិវាទ du pali *abhivadadati* "saluer".

[3] Il faut lire គោរព du sanskrit *gaurava* "respectabilité".

ឡើងប្រាងហើយណា ។
11 សករាជគ្រប់គ្រាន់ កន្លងពីរពាន់ បួនរយគនា ប្រាំបីដណ្តប់
ឆ្នាំគ្រប់វស្សារ ខែប្រាំបីជា ៩ថ្ងៃផ្លាយ ។
12 អហំនាម្នោ ចន្ទសរោ ត្រូវគ្រប់ទាំងឡាយ គន់គិតគ្រប់គ្រង
សង្ស្បផងខ្វល់ខ្វាយ ប្រដៅសម្កាយ ជាធំធិបតី ។
13 គុងវព្យចុងកោះ ប្រាកមានបិតនោះ ឈ្មោះពិតព្រះទ័យ
ចម្លងសោវតា លោកតានាមនៃ បុទុមបរមី ដើមឈ្មោះពេជ្រា ។
14 រីឯអង្គអញ យល់ស្រុកខ្មែរមិញ មិនសូវសុក្ខា តែងកើតទោសទុក្ខ
អាក្រក់គ្រប់គ្រា ក្រុងកម្ពុជា នោះនឹងស្វាត់បាត់ ។
15 ហេតុនេះអង្គអញ សូមសំដែងចេញ ជាកិរទៀតទាត់
សូមថ្វាយព្រះពរ បរវរន្ទវរត្ន សូមព្រះនាមក្សត្រ
ជាម្ចាស់សិរិសារ ។
16 សំដែងទុកទៅ ឲ្យអស់កូនចៅ ដឹងដើមដូនតា កាលពីព្រេងព្រឹទ្ធ
បាត់ស្វាត់យូរយារ ទុកជាមាត្រា របារអស់ក្សត្រ ។
17 ពាក្យពិតសភាព បពិត្រពោលរាប់ ក្រែងភ្លាំងភ្លេចភ្លាត់
ពិតពុំទាក់ទង ទំនងមហាក្សត្រ អ្នកណាចាំស្នាត់ តម្រង់ឲ្យទាន ។
18 ទុកទៅជាកេរ្តិ៍ ក្រោយគ្រាន់ចំណេរ តទៅមុខមាន
កុំឲ្យសូន្យស្វាត់ បង់បាត់បូរាណ ទុកជានិទាន របាក្សត្រផង ។
19 ដ្បិតកាលពីមុន មហាក្សត្រមានបុណ្យ ស្តេចគង់គ្រប់គ្រង
បន្ទាយឧដុង្គ មានដែយនោះហោង តំណែលតម្កង
តំណាក់ទាំងឡាយ[1] ។
20 កាលស្តេចកុមារ ព្រះវរមាតា បិតាច្បងច្បាស់ មានព្រះឱង្ការ
រក្សាត្រង់ត្រាស់ ព្រះនាមបុត្រច្បាស់ ឲ្យហៅអង្គតន់[2] ។
21 ស្តេចឲ្យមេនំ ពីលៀងព្រៀងបំ ពេពិតពីក្មេង លុះពេញរូបអង្គ
ទ្រើសទ្រង់ឆោមផ្សឹង ព្រះបិតាឯង ឲ្យបុត្តបន្ទូល ។
22 គ្រប់គ្រងរាជា ព្រះជៃជេដ្ឋា រាម្នាឥស្វរ គ្រប់គ្រងសម្បត្តិ
ជាតិជាកំពូល រាជរដ្ឋអនុកូល រាជជាបូរី ។

[1] Dans le texte imprimé *Rœang Roba khsat srok khmê*, on lit : តំណាក់វាំងចាស់ "résidences royales dans l'ancien palais".

[2] A corriger en អង្គអេង "Ang Eng".



23 ស្តែងស្តេចទ្រង់ធម៌ ប្រសើរឥស្វរ រុងរឿងនាថ្មីយ[1] ថ្កុំថ្កើងសាន្តសុក
អស់មុខមន្ត្រី សេណាបុតី រុងនាសម្តព ។
24 នៅអស់បរោហិត កវីបន្ទិត ព្រាហ្មព្រឹទ្ធប្រាជ្ញប្រាយ ស្នេហាស្និទ្ធជាទំ
អ្នញជមសព្វសាយ រាស្ត្រផងទាំងឡាយ មិនមានហ្មងសៅ ។
25 ព្រះជៃជេដ្ឋា ស្តេចមានបុត្រា ជាច្បងនៃបនៅ ព្រះវរបិតា
មាតាស្ងួនពៅ សន្មតនាមហៅ អង្គចន្ទកុមារា ។
26 ព្រះរាជបុត្រច្បង កាលកើតនោះហោង ព្រះពុទ្ធសាសនា
កន្លងពីពាន់ បីរយគនា និង១០វស្សា ឮយសែសឆ្នាំបួន ។
27 ឯបុត្តបន្ទាប់ ព្រះនាមស្រេចស្រាប់ ឲ្យហៅអង្គស្ងួន
អង្គអីមអង្គដួង គ្រប់ល្ងងទាំងបួន បិតាថែរថ្នួន ស្ងួនគ្រប់បេត្តិ ។
28 ទើបអង្គអាត្មា គុនគិតកាព្យា សរសើរសេចក្តី ពិតពីព្រះបាទ
ននាដ្ឋចក្រី ឥស្វរសិរសី ទ្រង់រាជថ្កើងថ្កាន ។
29 លុះស្តេចរាជា សោយព្រះវិលា ល្បែលុះចាកស្ថាន
ឥស្សរាស្ត្ររវល់ អំពល់ព្រួយប្រាណ ពុំសូវសុកសាន្ត ក្នុងរាជពិភព ។
30 ដ្បិតលោកចៅហ្វា ប៉ុកពិតជាតិជា បិតាធម៌ថប
តាក់តែងមន្ត្រី សេនីសាយសព្វ សង់មេនមានប់ ក្សរក្សាច់រចនា ។
31 ធ្វើបុណ្យសព្វថ្ងៃ ទុកព្រះសពថ្លៃ ពេញពីរវស្សារ ឲ្យទានទ្រព្យធុន
ធ្វើបុណ្យមហិមា ទើបបានបូជា ថ្វាយព្រះអាគ្គី ។
32 ហើយលោកគុនគិត ឲ្យតែងអស់ឥដ្ឋ ក៏ជាចេតី
បញ្ចុះព្រះធាតុ ព្រះបាទចក្រី ធ្វើបុណ្យប្រក្រតី អធិថ្វាយទៅ ។
33 លោករួមរក្សា ព្រះរាជបុត្រា ទាំងបួនចោមចៅ គ្រប់គ្រងធានី
បូរីឥតសៅ អស់រាស្ត្រក្នុងក្រៅ សឹងសុកសប្បាយ ។
34 លុះយូរបន្តិច បុត្រ៤អង្គស្តេច ចំរើនរូបកាយ ពាលពេញព្រះអង្គ
ទ្រើសទ្រង់ឆោមឆាយ នាំល្ងងទៅថ្វាយ សម្តេចពុទ្ធិចៅ ។
35 រីឯចៅហ្វា, ប៉ុកពុំយូរយារ អញ្ជើញស្តេចទៅ ឲ្យរៀបជើងទឹក
ពន្លឹកក្រែក្រៅ ពលពាលខ្វលខ្មៅ ដង្ហែស្តេចស្តែង ។
36 ចរចុះជើងទឹក ទីយនាំងភ្លើភ្លឹក រន្ទាលទិព្វទែន ឲ្យគោះដំស្គរ
ទូងទរគគ្រេង ដេញដំផ្លុំភ្លេង ស្វូរសព្ទរងំ ។

[1] Il faut lire ធានិ "capitale".

[2] Il faut lire : ឱទ្ទិស.

37 លុះបានពេលា លាក្ខឫក្សជោគជា ប្រពៃយឧត្តម តាំងហោចរចេញ
បាញ់កាំភ្លើងធំ ទូម្លេងភ្លេងភ្លំ រងំចេញទៅ។

38 អស់រាស្ត្រទាំងឡាយ ស្រើបស្រាលសប្បាយ បទបុត្តចោមចៅ
ចរចេញហែរស្តេច ត្រង់ត្រេចសំដៅ តម្រង់ឆ្ពោះទៅ
ត្រូវបាត់ដំបង។

39 ឯអង្គអព្ភៃ ត្បែសបែននោះនៃ អរក្រៃកន្លង ហេតុត្រូវគំនិត
គូនគិតប៉ុនប៉ង និងថ្វាយកូនផង ជាតិជាសំរាប់។

40 គិតស្រេចពុំលង់ លោកក៏រៀបសង់ បន្ទាជាឆាប់ ជិតជើងកំពង់
រៀបប្រុងប្រដាប់ គ្រប់គ្រងសំរាប់ ឥតឯខ្វះឡើយ។

41 សម្តេចចៅហ្វា លួង៤អង្គារ ចូលរាបចាត់ហើយ ពិតពុំយូរយារ
លេលាត្រង់ត្រើយ ព្រះពន្លាហើយ ស្តេចឡើងទៅគង់។

42 អព្ភៃត្បែសស្រួល រករៀបទទួល ទាំង៤ព្រះអង្គ សំរាលអាស្នារ
អាហារផ្ចិតផ្ចង់ ថ្វាយទាំង៤អង្គ ឲ្យសោយសោះឃ្លាន។

43 ស្រេចហើយអព្ភៃ ត្បែសបែននោះនៃ គូនគិតពិធ្យាន
ចង់ថ្វាយបុត្រី ប្រីមប្រិយកល្យាណ ឃាត់ស្តេចឲ្យខាន
កំសាន្តព្រះទ័យ។

44 ទាំងលោកចៅហ្វា ប៉ុកពិតពុំជា ម្តេចៗឡើយនៃ ព្រមឲ្យលួងខាន
កំសាន្តព្រះទ័យ នៅនេះយូរថ្ងៃ ឯម្ចាស់អង្គច័ន្ទ។

45 ឃើញកូនអព្ភៃ ត្បែសបែននោះនៃ ព្រះទ័យខ្នាន់ខ្នាញ់
គិតកើតស្នេហា ចិន្តាក្តួចកាន រករិះដិះដាន ជាទេពីពិត។

46 អព្ភៃត្បែសបាន ដឹងដោយដើមដាន ព្រះទ័យស្តេចគិត
ចង់បានបុត្រី តូចក្តីគំនិត អព្ភៃត្បែសគិត ចូលទូលស្តេចថា។

47 បពិត្តបើស្តេច សព្វព្រះទ័យស្រេច កូនខ្ញុំករុណា នឹងថ្វាយស្តេចបាន
តូចក្នានចិន្តារ កុំព្រួយព្រះហារ ទៃគិតត្រង់ណោះ។

48 សូមតែស្តេចទៅ បង្គំព្រះចៅ ដូចដោយចំពោះ បើស្តេចស្តែងបាន
វិលថ្កានមកស្មោះ ខ្ញុំថ្វាយកាលនោះ តាមសព្វព្រះទ័យ។

49 ស្តេចស្តាប់ស្រើសព្រហ្ម ព្រះទ័យល្ហាក់ល្ហម តាមពាក្យអព្ភៃ
ត្បែសសោតរៀបខ្លួន ជូនហៃក្សត្រថ្លៃ ដល់ដូចព្រះទ័យ
នៃស្តេចកាលនោះ ។

50 ដល់ហើយចូលថ្វាយ បង្គំករកាយ ទូលទៅសព្វសុះ



ព្រះចៅយុធ្យា គួរណាស្មើស្មោះ អព្ភៃត្បែសនោះ ឲ្យវិលវឹងវិញ។

51 ឯលោកចៅហ្វារ ប៉ុកពុំឃ្លាតឃ្លា រក្សាស្តេចមិញ ឡិតនៅកុមារ
មិនទាន់ឲ្យចេញ មកស្រុកខ្មែរវិញ ឡិតក្មេងនៅឡើយ។

52 ចៅហ្វាប៉ុកនៅ លួងប្អូនព្រះចៅ ឃាត់នៅនោះហើយ
ពុំបាននិយាយ ថែងចាយទៀតឡើយ ទុកស្លេះសិនហើយ
ទិម្ស នោះនឹងនៅ។

53 បទពុំនោលនិទានទៅ សំដីសំដៅ សម្តែងឯស្រុកខ្មែរវិញ។

54 កាលក្រោយចៅហ្វាប៉ុកចេញ ទៅសៀមនោះមិញ
មិនសូវសុកសានសប្បាយ។

55 អស់រាស្ត្ររកស៊ីសព្វសាយ ចេញចូលជួញចាយ
ខ្វល់ខ្វាយរិះរកទ្រាព្យធន់។

56 មានចោរកាចកិច្ចប្លមប្លន់ យកអស់ទ្រាព្យធន់
បញ្ឆោតបញ្ឆុកលុកកាប់។

57 បើពុំព្រមឲ្យអស់ទ្រព្យ ទៅវាវាកាប់ យកទ្រព្យអស់ឥតសំចៃ។

58 សព្វស្រុកពុំសុកឡើយនៃ គ្រប់ខែត្តទីទៃ
តែងធ្វើអំពើរនោះហោង។

59 ឮលេចពាក្យពេចន៍អ្នកផង ស្រដីអឹងកង ដល់បាត់ដំបងនោះនៃ។

60 កាលនោះឯអង្គអព្ភៃ ត្បែសបែននោះនៃ
វៃយដឹងដោយឈ្មួញជួញប្រែ។

61 ថាកើតកង្វល់ស្រុកខ្មែរ រាស្ត្ររកជួញប្រែ សឹងតែពុំបានគ្រប់ច្រក។

62 អព្ភៃត្បែសបែន រិះរកធ្វើសំបុត្រមក ប្តឹងទៅចៅហ្វារវិញថា។

63 ឲ្យគិតគំនិតប្រាជ្ញា យកសេចក្តីនោះណា សំគួរក្រាបទូលព្រះចៅ។

64 តាមដោយសំបុត្រប្តឹងទៅ ចៅហ្វារប៉ុកនៅ
នាយចូលទូលតាមសេចក្តី។

65 សម្តេចពុទ្ធិចៅចក្រី បានជ្រាបសេចក្តី
ទើបមានមេត្រីត្រាស់ថា។

66 នឹងឲ្យចៅ៤អង្គារ សម្តេចចៅហ្វារ វិលទៅឯស្រុកខ្មែរវិញ។

[1] Son synonyme est : ត្រើម. "treem" qui signifie "juste, égal, à l'endroit".

67 ដ្បិតក្មេងកុមារនោះមិញ បើច្នេះអង្គអញ ឲ្យអព្ភៃយវៀតសបែន
ទៅ។
68 គិតស្រេចសម្តេចពុទ្ធិចៅ តាងបន្ទូលទៅ ឲ្យអង្គអព្ភៃយវៀតសឯង។
69 គ្រងជាចៅហ្វាយតាក់តែង ចេញចាប់ចោរលេង
ឯស្រុកខ្មែរឯងឲ្យបាន។
70 អព្ភៃវៀតសដឹងដើមដាន ស្តេចត្រាស់ប្រើប្រាណ
ពុំហ៊ានបង្អង់លង់ឡើយ។
71 គិតចេញមកស្រុកខ្មែរហើយ ពិតពុំយូរឡើយ ឲ្យហៅនាហ្មឺនតូចធំ។
72 ស្រុកខ្មែរមកដល់ជួបជុំ គុនគិតជំនុំ សួរអំពីពុតពាលនោះ។
73 នាហ្មឺនខ្មែរប្តឹងសព្វសុះ គ្រប់ខេត្តទាំងនោះ ឥតឯចន្លោះខ្វះឡើយ។
74 អព្ភៃវៀតសបានដឹងហើយ គិតពុំឆ្ងល់ឡើយ
លោកយល់យកនឹងប្រាជ្ញា។
75 លោកធ្វើអំពើរកិច្ចការ ហៅមនុស្សណាជា ជឿចិត្តគំនិតប្រើប្រាប់។
76 បាងចូលទៅនៅផ្ទាប់ មេចោរយកទ្រព្យ តាមវាបង្អាប់គិតធ្វើ។
77 ចូលទៅជាបាវបំរើ តាមដោយអំពើ វាធ្វើដូចម្តេចធ្វើនោះ។
78 សម្ងំកុំឲ្យដឹងស្មោះ គំនិតវានោះ ពិតហើយមកប្រាប់អង្គអញ។
79 នឹងគិតបំពត់វាវិញ ផ្តាំស្រេចប្រើចេញ
ទៅនៅគ្រប់ខេត្តទាំងឡាយ។
80 មេចោរខេត្តកំពង់ស្វាយ ឈ្មោះតេងឈ្មោះឡាយ
ជានាយនាំរាស្ត្រគិតប្លន់។
81 យករអស់របស់ទ្រព្យធន់ វានៅចាំប្លន់ នៅភ្នំយាយសួរនោះហោង។
82 ចេញទៅទន្លេសាបផង មើលអស់ឈ្មួញឆ្លង
នឹងប្លន់យកទ្រព្យធន់នោះ។
83 អស់បំរើអព្ភៃ វៀតសបែនចូលដៃ ដឹងដើមដំណើរសាយសព្វ។
84 ចូលទៅប្តឹងលោកទាំងគ្រប់ លោកប្រើត្រឡប់
យកទ្រព្យទៅឲ្យអស់រាស្ត្រ។
85 សឹងតែខៀនព្រៃជា ជាជាតិទេសង្កា ឲ្យខំធ្វើការឲ្យបាន។
86 នឹងឲ្យរង្វាន់ធនធាន អស់មេគ្រប់ប្រាណ ប៉ុន្មានមូលមកបានម្តង។
87 អញបន្ទឹងស្គាល់មុខផង មាសប្រាក់កែវកង អញឲ្យដោយចិត្តប្រាថ្នា។



88 ទ្រព្យធនទាំងប៉ុន្មានសក្ខតា បើបានធ្វើការ
បានហើយអញឲ្យទាំងគ្រប់។
89 ផ្តែផ្តាំបំរើសារសព្វ នាំទ្រព្យត្រឡប់ ទៅឲ្យដោយមេគ្រួបគ្នា។
90 សឹងតែខៀនព្រៃជាៗ មេបានទ្រព្យា ហើយខំធ្វើការគ្រប់ខ្លួន។
91 លុះបានច្រើនជាសំនួន ហើយនាំទាំងខ្លួន
ទៅជូនលោកឲ្យស្គាល់ជាក់។
92 អព្ភៃវៀតសអរឲ្យស័ក្តិ ឲ្យមាសឲ្យប្រាក់ យសស័ក្តិសឹងតែជាធំ។
93 ហើយលៀងឲ្យស៊ីបន្សំ អស់មេធំៗ អរឯងអស់បាត់ចេញទៅ។
94 មានមេវះវែងក្រៅ មិនបានចូលទៅ ហេតុនៅពុំទាន់ជឿជាក់។
95 ឃើញគ្នាបានឡើងបុណ្យស័ក្តិ បានមាសបានប្រាក់
ប្រាកដប្រកបថ្កើងក្រៃ។
96 អស់មេវេះវេហាក្នុងព្រៃ អរឯងទីទៃ ចូលទៅទាំងអស់ឥតសល់។
97 អព្ភៃវៀតសអរឥតដល់ ឲ្យអស់ពួកពល លាងបាយឲ្យស៊ីផឹកផង។
98 ស្រវឹងពេកពន់កន្លង លោកឲ្យចាប់ចង ចាក់កាប់សម្លាប់អស់ទៅ។
99 ស្រុកខ្មែរឥតឯមានសៅ ហ្មងមោះទោសទៅ
មករក់ស៊ីសុកសប្បាយ។
100 អស់រាស្ត្ររកស៊ីស្ទះសាយ ចេញចូលជួញចាយ
ទៅជិតទៅឆ្ងាយសឹងបាន។
101 ឥតចោរឃោរឃៅឈ្លានពាន ប្លមប្លន់រុករាន
ឲ្យមានមន្ទិលទោសទុក។
102 សឹងស្ងួនស្ងាត់បាត់គ្រប់ស្រុក រាយរកស៊ីចុក
សឹងសុកសប្បាយក្សេមក្សាន្ត។
103 ទោះទ្រព្យភ្លេចចោលសព្វស្ថាន ឥតអ្នកណាហ៊ាន
និងបានរើសយកគ្មានសោះ។
104 ទោះទាំងកាំបិតបន្ទោះ ទ្រព្យតិចឡើយនោះ
ចោលចុះដោយដីឥតក្រែង។
105 ស្រុកខ្មែរសឹងតែនោះឯង ឥតអារម្មក្រែង
ក្របីគោលែងចោលបាន។
106 សឹងសុខសប្បាយក្សេមក្សាន្ត សព្វស្រុកសព្វស្ថាន
ឥតមានមន្ទិលទោសា។

107 សកលមណ្ឌលភពភា ក្រុងកម្ពុជា បុរីបុរាណសាន្តសុខ[1] ។
108 រាស្ត្រផងចងជាទំនុក ច្រៀងលេងគ្រប់ស្រុក
ជាសុកសប្បាយគ្រប់គ្នា ។

109 បទកាកគតិតែង តំណើរតំណែង ទំនុកនោះថា
សរសើរឫទ្ធិបុណ្យ គុណគិតរក្សា រាស្ត្ររេងសុក្ខា ឥតឯកំដើង ។
110 ផ្តលានព្វណែន កាលរាជចៅហ្វាវបែន ក្រមុំដប់មួយស្លឹង
ខ្លះយកទទេ ឥតឯកុំដើង មេម៉ាយកំព្រើង ១០ស្លាពុកមួយ ។
111 ស្រុកយើងសកល ឥតឯអំពល់ អំពីចោ ុយ
លោកចាប់ចោរឃ្លូល អស់ឥតទុក្ខ ។
112 រាស្ត្រច្រៀងសរសើរ ទំនុកដំណើរ តំណោលកាលគ្រា
អព្ទៃត្បែសបែន គ្រងជាចៅហ្វារ រាស្ត្ររែងសុក្ខា ឥតឯអំពល់ ។
113 ឯអង្គអព្ទៃ ត្បែសបែននោះនៃ នៅនឹកយុងយល់
ថាអញពិតជា រក្សាសុកល ភូមិភពមណ្ឌល ក្រុងកម្ពុជា ។
114 ឥឡូវសុកសាន្ត ដូចដោយនូវភ្នាន គំនិតប្រាជ្ញា
គួរគិតចូលទៅ ព្រះចៅយុធ្យា ទូលតាមដោយនា ដំណើរសេចក្តី ។
115 គិតស្រេចពុំលង់ លោកប្រើប្រៀបប្រុង ចងគ្រឿងដំរី
បប្ចូរស្រព្វស្រេច រំពេចឆាបខ្មី ទៅទេពបូរី ដល់ដូចចិន្តា ។
116 ដល់ហើយចូលទូល តាមដោយនៅបូរ បូរីរម្យា បពិត្រក្រាបទូល
ឥស្វរសិរិសា ក្រុងកម្ពុជា សុកសាន្តឥតហ្មង ។
117 ព្រះចៅយុធ្យា បានជ្រាបប្រការ ប្រាកដនោះហោង
ទ្រង់ព្រះចិន្តា ថាចៅជាច្បង អង្គច័ន្ទនោះហោង ល្មមគ្រងសីមារ ។
118 គិតស្រេចពុំយូរ មានព្រះបន្ទូល និងលោកចៅហ្វារ
អព្ទៃត្បែសផង នាំល្វងលេលា មកគ្រងសេមារ
ឯស្រុកខ្មែរវិញ ។
119 ហើយត្រាស់ប្រើពញា យោមរាជជាតិជា សៀមសុតនោះមិញ
ឲ្យរៀបទ័ពទឹក ពន្លឹកចចេញ ជូនល្វងមកវិញ ដល់បាត់ដំបង ។
120 ឯអព្ទៃត្បែស ពិតពុំប្រហែស ប្រាមប្រាប់អ្នកផង



ឲ្យសង់ដំណាក់ ទំនៀបផ្ទផ្គង ទទួលស្តេចហោង ជិតជើងកំពង់ ។
121 ស្តេចដល់ចូលចាប់ បោះបង្គោលខ្ជាប់ ស្តេចឡើងទៅគង់
ជាសុខក្សេមក្សាន្ត ទាំង៤ព្រះអង្គ អព្ទៃត្បែសផ្គង់ គ្រប់អង្គទាំង៤ ។
122 ស្រេចហើយអព្ទៃ ត្បែសយកកូនស្រី បង្កើតនឹងខ្លួន
ល្អណាស់ឥតអង្គ ត្រូចង់សមសួន កូនស្រីទាំង៤ រើសតាមទ័យា ។
123 ឯល្វងអង្គច័ន្ទ ព្រះទ័យគួចកាន់ នាងទេពធិតា
អង្គកាយកណ្តាល ត្រកាលនេត្រា ភ្នែយន់ជ្រះថ្លារ ភិរក្ខាផូផង់ ។
124 ស្តេចសព្វព្រះទ័យ នាងនោះណាស់នៃ នឹកនឹងរួមអង្គ
អព្ទៃត្បែសយល់ កិច្ចកល់ពុំលង់ ថ្វាយតាមចំណង់ ព្រះរាជចិន្តា ។
125 ហើយធ្វើសំបុត្រ ប្រាមប្រាបប្រាកដ អស់រាស្ត្រប្រជា
ឲ្យទាំងប្រាប់ផ្លូវ ឲ្យត្រូវគ្រប់គ្នា ឲ្យរៀបពន្លា ធ្វើជារហ៏ស ។
126 ពីបាត់ដំបង ពោធិសាត់ក្តីហោង មកដល់ទាំងរាស្ត្រ
ឲ្យខំប្រាលប្រាប់ ឲ្យរៀបរហ៏ស ស្តេចបន្ទូលត្រាស់ ប្រើធ្វើឲ្យឆាប់ ។
127 ឲ្យមានទំនៀប តំណាក់រៀងរាប តាមផ្លូវឲ្យស្រាប
ស្តេចយាងជើងគោក នឹងយកទោសស្លាប់ ឲ្យធ្វើប្រញាប់
តាមព្រះបារទ័យ ។
128 អស់រាស្ត្រទាំងឡាយ ឮហើយប្រញាយ ភ័ន្តភាំងភិតភ័យ
ខំធ្វើគ្មានឈប់ ទាំងយប់ទាំងថ្ងៃ តាមព្រះបប្ចទ័យ ភិតភ័យស្មើគ្នា ។
129 បានធ្វើរួចស្រេច ទើបទៅទូលស្តេច នូវលោកចៅហ្វា
ស្តេចឲ្យអព្ទៃ ត្បែសបែនជិតា ក្មេកនិងពញា យមរាជជើងទឹក ។
130 សម្តេចចៅហ្វារ នាំល្វងលេលា ជើងគោកគគឹក
ពលពាលពេញពាស ដើរដាស់ពន្លឹក ដំរីសេះសឹក បាំងក្លសលំយម ។
131 ស្តេចយាងកំសាន្ត ផ្លូវភ្លងឮសាន ស្វូរសព្ទរងំ ដរាបរៀងទៅ
តាមផ្លូវធ្លាធំ ស្តេចយាងមិនខំ ផ្ទំគ្រប់ដំណាក់ ។
132 លុះបានដល់ទៅ ព្រះពន្លាហៅ កំពង់ល្វងតាក ឲ្យរៀបរាំលេង
គ្រប់ល្បែងឥតអាក់ រាស្ត្រក៏គ្រឹកគ្រាក់ អរឯងទីទៃយ ។
133 តិចទើបចៅពញា យោមរាជជាតិជា សៀមសុទ្ធធំក្រៃ
អព្ទៃត្បែសបែន ជើងទឹកនោះនៃ ដល់ក្រោយបីថ្ងៃ
ដាក់ជើងកំពង់ ។
134 ស្តេចឲ្យអស់ល្បែង ដេញដំផ្គុំភ្លេង កំសាន្តព្រះអង្គ

[1] Ce passage est emprunté au texte imprimé, *Rœang Roba khsat srok khmê*, vol. I, p. 12.

បានប្រាំពីរថ្ងៃ ក្សត្រីថ្លៃឡើងគង់ បន្ទាយឧត្តុង្គ ដើមដែលដូនតា។
135 ស្ដេចបានឡើងដល់ មន្ទីមណ្ឌល់ ទៀងទើបក្សត្រា
ឲ្យហៅគុណគូរ រកឫកពិលា និងសោយរាជា គ្រប់គ្រងបូរី។
136 ឲ្យរើសរកស្នំ ពាស់ពេញក្រមុំ រូបរាងប្រិមប្រិយ៍
ល្អល្អះសក្តិសម សឹងព្រហ្មចារិ្យ រើសរៀបស្រេចស្រី
ស្នំស្និទ្ធទាំងឡាយ។
137 កំណានសំអាង សំអាតរូបរាង ទុនភ្លន់កែក្រាយ
ខ្ញុំណាន់បន្ទំ ឧត្តមពុំទ្រនាយ កំណាន់ព្រះនាយ ព្រះសិទ្ធរស។
138 កំណាន់ព្រះខាត ព្រះខ័នមហាក្សត្រ សឹងសម្រក់ពុះ
កំពង់ពេញពាល សៀមសារស្រេចស្រស់ ព្រះពាតព្រះពុស
ព្រះពានព្រះស្រី។
139 ស្លៀកជង់ស្លៀកជាយ ស្បៃស្បិតបន្លាយ ជំពូវទេសថ្មី
កោសៃយកោសា យម្មនាជាតិ ជំពូវអន់ថ្មី សាវសំពុតទ្រនាយ។
140 ខ្លះស្បៃបែតង ដំណើរញ៉ែញញ៉ង ឯនអនកែក្រាយ
របៃបួងបទ ស្រកូតអង្កាយ នាងខ្លះស្បៃស្វាយ កោភាវតាវតែង។
141 សំអាតអស់ភ្នំ ត្រេងត្រួបស័ក្តសម ល្អល្អះលើសលែង អណោក
អណាន្ទ ពេកពន់ឯកឯង ស្ទួសសមស័ក្តិសែង លើសលែងលោកផង។
142 ឯអង្គអព្ចៃ ត្បែសបែននោះនៃ នាំបុត្រស្នេហ៍ស្នង ទៅថ្វាយ
ព្រះបាទ ននាដ្ឋប្បាស់ប្បង ឲ្យស្ដេចស្ដែងគ្រង ជាទេពីធំ។
143 ស្ដេចឲ្យរើសស្ត្រី មុខមាត់ប្រិមប្រិយ ពាសពេញក្រមុំ
សម្រាប់នាងនាដ្ឋ ជាទេពីធំ ឲ្យស្ងួនសក្ដសម ច្រើនក្រៃកន្លង។
144 រកឫកជោគជ័យ ល្អល្អះប្រពៃ ពេកពិតឥតហ្មង
ស្រេចបានពេលា ដាក់ជាកន្លង ស្ដេចសោយរាជគ្រង ក្រុងកម្ពុជា។
145 អស់មុកមន្ត្រី ធំតូចផងក្តី គង់គាល់ត្រៀបត្រា ផ្គំភ្លេងរងំ
ស្វូរសព្ទសមគ្នា ពលពាលអាសារ សម្រាប់ច្រើនក្រៃ។
146 លេងភ្លេងមហោស្រព នៅល្បែងផងគ្រប់ ជួបប្រាំពីរថ្ងៃ
ទើបអស់ព្រាហ្មព្រិទ្ធ បរោហិតសាយសៃ ផ្លុំស័ង្ខជាញជ័យ
ថ្វាយព្រះនាម្រា។
147 ឡើងព្រះនាមនាដ្ឋ សម្ដេចព្រះបាទ ឧទៃរាជា គ្រប់គ្រងមន្ត្រី
សេណីសេណា ក្រុងកម្ពុជា បូរីរាជស្ថាន។



148 រាស្ត្ររែងសុកល ភូមិភពមណ្ឌល សប្បាយក្សេមក្សាន្ត
អង្គឥតសត្រូវ ណានិងបៀតបាន បទបុណ្យក្សត្រក្សាន្ត
គ្រប់គ្រងបូរី។
149 ឯពញាយោមរាជ សៀមសុទ្ធឯងអាង ជាធំធិបតី
បំរើពុទ្ធិចៅ ចេញទៅរីងខ្មី អព្ចៃយត្បែសក្តី
សឹងទៅទាំងអស់។
150 អព្ចៃត្បែសនោះ ទុកកូនមួយឈ្មោះ ម៉្វាជាចោងប្រុស
ឲ្យនៅមើលផ្គុន ថែថ្នួនគឺបខុស បទបងជាប្រុស
ខុសឆ្កង់មើលគ្នា។
151 ឯអង្គព្រះបាទ សម្ដេចនានាដ្ឋ ឧទៃរាជា គ្រប់គ្រងមហេសី
បេតីស្នេហា ឯបងឈ្មោះម៉្វា ឲ្យជាធំធួន។
152 ធ្វើជាព្រះអង្គ ព្រះញាតិវង្ស សាស័ក្ដសមស្ងួន តែងទុកព្រះទ័យ
អាល័យស្មើខ្លួន ឲ្យមើលថែថ្នួន ធំក្នុងបូរី ។
153 ឯលោកចៅហ្វារ ប៉ុកពិតជារា ចាស់ណាស់ស្មារតី
និងគិតរាជការ រក្សារបូរី មិនបានបទក្តី ជូនចាស់ជារា។
154 ព្រះអណ្ដជទាំងបី លោកឲ្យមន្ត្រី ទាំងបីអង្គារ ចក្រីក្រហោម
យោមរាជរក្សា បងលោកជរា រក្សាមិនបាន។
155 ចៅហ្វារប៉ុកនៅ យូរបន្តិចទៅ ជូនចាស់ចាកស្ថាន
ខ្សិនក្ស័យជីវិត អស់ឥតវិញ្ញាណ ស្ដេចធ្វើបុណ្យទាន
បរបូណ៌ប្រពៃយ។
156 ធ្វើមេនមាន់ដប់ ហាក់ដូចព្រះសព ព្រះបិតាថ្លៃ
ធ្វើបុណ្យឲ្យទាន មិនមានសង្ស័យ ស្ដេចទុកព្រះទ័យ
ស្មោះស្មើបិតា។
157 ដំណើរក្រោយនោះ ចៅហ្វារប៉ុកលុះ ក្សិនក្ស័យជន្មា
ស្ដេចតាំងឈ្មោះនាន្ទ ឲ្យកាន់កិច្ចការ ធ្វើជាចៅហ្វារ
រក្សារាស្ត្រផង។
158 យូរបន្តិចទៅ ព្រះអណ្ដជហៅ អង្គស្ងួននោះហោង
ស្ដេចអាក់ងន់ឯង ទាស់ទែងនឹងបង បន្តិចទៅហោង
ហេតុព្រោះបទស្រី។
159 ខានពុំបានគាល់ ព្រះរាមរៀងរាល់ ដូចកាលប្រក្រតី

ខានជាជួបចាប់ គំរប់ថ្ងៃបី ទើបឡើងទៅខ្មី
កាន់ព្រះរៀមរីក។

160 ព្រះរាមស្ដេចយល់ ព្រះអាណុជដល់ ឡើងលើដំណាក់
ស្ដេចមានបន្ទូល សារសួរស្មោះស្ម័គ្រ ផ្អូនមានបើអាក់
អន់អ្វីនឹងបង។

161 បានមិនមកគាល់ សព្វថ្ងៃរៀងរាល់ ដូចដោយមួយដង
បើប្អូនអនអាក់ ថ្នមថ្នាក់ម្ដេចម្ដង ប្អូនប្រាប់មកបង
ឲ្យបានដឹងជាក់។

162 ឯព្រះអាណុជ ស្ដេចស្ដាប់ចោទចុច ចង់ដឹងចិត្តជាក់
ទូលទៅថាខ្ញុំ ពិតពុំអន់អ័ក និងព្រះរាមរីក អ័កតើបទអ្វី។

163 ទូលទៅដំណោះ អ័កអន់ក្នុងពោះ ពិតពុំស្រដី
ស្រេចហើយម្ទីម្នា លុះលាបាខ្មី ទៅដល់ទាល់ទី លំនៅអាត្មា។

164 ស្ងាត់ហើយជុំនំ នាម៉ឺនចាស់ទុំ តែងទុកចិន្ដា នៅអស់មហាត្លឹក
ពួកពលអាសារ ថាអញនោះណា នៅនេះមិនបាន។

165 ចូរឯងរាល់គ្នា រួសរៀបអាត្មា គ្រប់គ្រឿងប្រុងប្រាណ
ប្រដាប់គ្រឿងសេះ យុបនោះចងអាន អាទ្រាតស្ងាត់បាន
ចចាកចេញខ្មី។

166 អញចង់ចទៅ ត្រេចត្រង់សំដៅ ក្រុងទេពបូរី បង្គំព្រះចៅ
និងនៅនេះថ្មី ទោស្សតែពីស្រី ស្រដីមិនបាន។

167 ពួកពលអាសា ស្ដាប់ស្ដេចត្រាសថា ដូច្នេះស្មោះស្មាន
យកសេះចងគ្រឿង រួងរឿងស្រេចបាន ស្ដេចចេញចាកស្ថាន
បន្ទាយវាំងចាស់។

168 ស្ដេចយាងទាំងយុប ពិតពុំយេរឈប់ ស្រូតរូតរហ័ស
អាទ្រាតយប់ជ្រៅ ចេញទៅភ្លឺច្បាស់ ទើបស្ដេចត្រេកត្រាស់
ឲ្យបទឈប់នៅ។

169 សំរាកជើងពល បរិភោគស្កប់ស្កល់ ស្រេចហើយទើបទៅ
ស្ដេចគង់អស្សពារ លេលាសំដៅ ដើរតាមដោយផ្លូវ
ទៅទេពបូរី។

170 ព្រឹកព្រាងសូរិយា ឧទ័យរាជា បានជ្រាបសេចក្ដី
ថាអាណុជក្សត្រ រត់បាត់ពិតពៃ ដំណាក់នោះខ្មី ស្ដេចត្រាស់ប្រើឲ្យ។



171 ហៅមហាអការ[1] កែនពលម្ទីម្នា លើកតាមដោយក្រោយ
ថាបើទាន់ក្សត្រ ហើយឃាត់កុំឲ្យ ស្ដេចទៅមុខឲ្យ
មកក្រោយវិញថ្វាត់។

172 ឯមហាអការ ស្រូតរូតដោយម្ទីម្នា ដល់ពោធិសាត់
ទៅទាន់ស្ដេចគង់
ក្នុងខេត្តនោះថ្វាត់ ទើបឯមហាក្សត្រ បន្ទឹងវិញថា។

173 ឯងមករកអ្វី តាមអញនោះថ្មី ទើបមហាអការ ក្រាបទូលទៅ
វិញ អញខ្ញុំនោះណា ព្រះរាមរាជា ត្រាស់ប្រើឲ្យមក។

174 អញ្ជើញស្ដេចទៅ ទីស្ថានលំនៅ កុំទៅបាងកក ព្រះរាមរាជា
ត្រាស់ថាឲ្យមក ឲ្យខ្ញុំខំយក ស្ដេចទៅឲ្យបាន។

175 ទើបស្ដេចត្រាស់ថា ឈ្មោះមហាអការ ចិត្តឯងនោះហាន
មកចាប់ចងអញ នោះមិញមិនខាន ទើបយកទៅបាន
ដូចដោយបង្គាប់។

176 ពះក្មេងអស់គ្នា ចាប់មហាអការ នោះយកទៅកាប់
ដោតក្បាលឲ្យបាន នៅឆ្នាមនោះនា ចាប់កុំឲ្យវាឆ្លប់
មើលងាយអង្គស្ដេច។

177 មហាត្លឹកទាំងឡាយ ចូលចាប់ប្រញាយ ចាប់ចងប្រានស្រេច
ហើយនាំយកទៅ ក្រៅកាប់កដាច់ ដោតក្បាលបានស្រេច
តាមស្ដេចបង្គាប់។

178 ទើបស្ដេចលីលា ឡើងលើអស្សពារ គុនគូរស្រេចស្រាប់
ស្រូតស្រាវចេញចរ បរជាប្រញាប់ ប្រញាប់ឆៀងឆាប់
ដល់ដីបាងកក។

179 ចូលថ្វាយបង្គំ គាល់ព្រះចៅធំ ទ្រង់សារសួរមក
ថាចៅអង្គស្ងួន ជូនបើមករក ឬមានបើឆ្លក ទាស់ទែងនឹងគ្នា។

180 រីឯអង្គស្ងួន ស្ដាប់ស្ដេចសួរខ្លួន ពិតពុំមុសារ ក្រញក្រាបទូលទៅ
ព្រះចៅយុទ្យា អស់អាតិតា ស្ដេចស្ដាប់ស្ងៀមនៅ។

181 ដំណើរនែនៅ សង្ខេបទុកស្ទេះ នឹងនិទានទៅ តពីដើមដាន
ក្សត្រក្សាន្តចោមចៅ ឧទ័ទរាជា គ្រងរាជរដ្ឋា។

---

[1] Il faut lire អយ្យកា.

182 យូរយល់បន្តិច ទៀងទើបសម្តេច បទចៅពញាធម្មា
នាមដើមឈ្មោះតី ជាតិជាជិតា បង្កើតក្សត្រា ឧទៃរាជស្មោះ ។

183 មានមួយទិវា សម្តេចចៅពញា ដីទូលជំពាក់ ថាដ្បិតឧកញ្ញា
ក្រឡាហោមឈ្មោះ ឯកឯងពុំស្មោះ គិតក្បត់ក្សត្រា ។

184 ពីនិងចក្រី បែនបានស្រដី គូបគិតនិងគ្នា ថាបើស្តេចធ្វេស
ប្រហែសកាលណា គេគិតព្រមគ្នា លព្វលុកលុះបាន ។

185 បទពំនោលនៅនិទាន ឯអង្គក្សត្រក្សាន្ត ព្រះបាទឧទៃរាជា ។

186 ស្តេចស្តាប់សាសាប់វាចា ពាក្យពីជិតា
ទូលទៅដូច្នេះក្រោធក្រៃ ។

187 ខំអត់សង្កត់ព្រះទ័យ ពុំថ្លែងសម័យ ដោយន័យគំនិតគិតនោះ ។

188 ស្តេចគិតគំនិតក្នុងពោះ បើក្បត់ដូច្នេះ វានោះនិងទុកធ្វើអ្វី ។

189 គួរកាប់សម្លាប់ទៅខ្ញី ក្រហោមចក្រី អញតាំងជាថ្មីឡើងបាន ។

190 គិតស្រេចសម្តេចក្សត្រក្សាន បើកបន្ទូលប្តាន សម្តេចតៃជាជិតា ។

191 ឲ្យជ្រើសរើសរកសេណា ជឿចិត្តចិន្តា ម្នីម្នាគិតការឲ្យឆាប់ ។

192 សម្តេចចៅពញាបានស្តាប់ ស្តេចត្រាស់ប្រើប្រាប
បង្គាប់អង្គឯងដូច្នេះ ។

193 ក្រាបលាម្នីម្នាចរចាក ចុះចេញមកស្មោះ
ហៅទួនផនោះមកគិត ។

194 ទួនជ្វាម្នីម្នាចូលជិត បៀតបានដល់គិត ខំឃាតជិតខ្សិបប្រាប់ថា ។

195 ដូចនៃព្រទ័យក្សត្រា ត្រាស់ប្រើអាត្មា
គិតការជាឆាប់ប្រញាប់ ។

196 ទួនជ្វាចិន្តាស្រាលស្រាប់ ចូលចិត្តចង់ចាប់
សម្លាប់ដោយកាប់អាត្មា ។

197 ជ្រើសរស់ជ្វាជាសេណា ប្អូនៗភ្ញៀវភ្លា
ក្រាបក្រាកាន់គ្រឿងគ្រប់ដៃ ។

198 គិតស្រេចរំពេចឆាប់វ័យ ខ្លះទៅនៅនៃ ផ្ទៃវាំងទាំងកាយា ។

199 ខ្លះទៅចាំនៅសាលា ប្រុងប្រៀបអាត្មា ក្រធាត់ក្រទូលចំម្ងន ។

200 ចក្រីក្រហោមធំធ្ងន ហេតុគ្រោះក្រខ្លួន ជួបជួនជីវិតនិងក្ស័យ ។

201 ពំដឹងទោសទួទីទៃ តែងទៅសព្វថ្ងៃ ប្រាស្រ័យគាល់មហាក្សត្រ ។

202 ប្អូនថ្ងៃនោះនៃក្រឡា ហោមទៅសាលា ពិភក្សាក្តីអ្នកផង ។



203 កូនក្មួយក្មេងៗទេសហោង ទើបទៅដល់ផ្លូង
ប៉ុនបងឡើងលើសាលា ។

204 ដើងជាន់ជណ្តើម្និម្នា ទើបទៅទិមទ្វារ ទួនជ្វារចាក់ធ្លាក់មកខ្ញី ។

205 សេណាចាមជ្វានៅដី ព្រួតវាយរឹងខ្ញី លុះបាត់ស្មារតីសូន្យសោះ ។

206 ហើយទើបចាក់កកាលេនោះ រំសទៅក្រៅស្មោះ
ចោលចោះបង្វៀតទៅខ្ញី ។

207 និយាយថៃងចាយសេចក្តី ឯអង្គចក្រី ប៉ែនបានឃ្មាតឃ្មីលេលា ។

208 ទៅដល់មណ្ឌលទីមទ្វារ ទើបពានសេណា
ចោមជុំអាត្មាច្រើនក្រៃ ។

209 គេរាំងទ្វាររាំងនោះនៃ ប្រើងប្រែវិលវ័យ
ដៃដល់តប់ទាត់តតាំង ។

210 ចក្រីបែនភិតភាំង លោលោតឡើងវាំង រលះរលាំងលិកលាន ។

211 ខានតិចនិងលេចឡើងបាន ឯអស់ទាហាន
ព្រួតប្រាណប្រទប់ជុំវិញ ។

212 ឯអង្គចក្រីបែនមិញ និងលោលោតចេញ ពុំរួចដូចចិន្តា ។

213 ពលរេគេចោមជុំចាត ចាក់កាប់អាត្មា គ្រាំគ្រាតំណំស្មើក្ស័យ ។

214 សេណាគ្នាគេច្រើនក្រៃ ចក្រីបែនដៃ ទទេតែទោះទាត់តប់ ។

215 ទាត់ទៅត្រូវដួលសន្លប់ គ្នាគេច្រើនខ្ចប់ ប្រទប់ប្រទះរារាំង ។

216 ចក្រីអន់អស់កំឡាំង និងប្រឹងប្រណាំង តតាំងទុលទុពពុំបាន ។

217 គេព្រួតវាយអន់អង្គប្រាណ ចោមចាប់ចងបាន
ដូចគំនិតគិតនោះ ។

218 គេគិតកាប់ចាក់មិនចុះ មិនមុតមិនឆ្លុះ
គេប្រានប្រមុជក្សិណក្ស័យ ។

219 គេឲ្យរំសចោលក្នុងព្រៃ កូនក្មួយភិតភ័យ រូតរត់ទីទៃគ្រប់គ្នា ។

220 ស្រេចហើយអស់អង្គសេណា នោះនាំគ្នីគ្នា
ទៅរើរិបទ្រព្យឥតសល់ ។

221 បញ្ជីត្រួតត្រាត្រិនពល នាំយកទៅដល់
ថ្វាយស្តេចដូចដោយចិន្តា ។

222 ទើបមានព្រះបន្ទូលថា ព្រះចំនទ្រាព្យា
ឲ្យអស់សេណានោះន័យ ។

223 ស្រេចហើយព្រះបាទឧទៃយ តាំងខ្លួនជនៃ
ឲ្យធ្វើយមរាជវិញស្នង ។
224 ឯអង្គនាម៉ឺនដែលត្រង់ ងារថ្មីនោះហោង
ឥតហ្មង់មន្ទិលទោសា ។
225 សិងថ្កើងសើយយសស័ក្ត ដោយបុណ្យក្សត្រា
គុនគិតរាជការនិងនៅ ។
226 លុះលង់ពីពង្សចោមចៅ អង្គអាណុជនៅ
យូរទៅបន្តិចស្តេចបាន ។
227 ជ្រួតជ្រាបស្វភាពដើមដាន ជាព្រះរាមមាន
បន្ទូលទៅថ្កានយួនខុង ។
228 តាគុនធំលុននៅក្នុង ព្រៃនគចង់ ឲ្យអង្គអាណុជស្តេចទៅ ។
229 ឲ្យយួនយកអាណុជនៅ ពីពង្សអង្គទៅ
ពុំចូលចិត្តនិងយួននោះ ។
230 ស្តេចដិងដើមដល់ក្នុងពោះ វៀមពិតពុំស្មោះ
អង្គអាណុជនោះដឹងដូន ។
231 ស្តេចគិតគំនិតថៃថ្នូន រកពិរៀបខ្លួន ទៅតាមអង្គស្ងួនវៀមវ៉ា ។
232 ដល់ទៅចូលពឹងពាក់ ពុទ្ធិចៅជាតិជាក់ ជាខ្ញុំបង្គំកកាយ ។
233 ពុទ្ធិចៅសួរទៅសព្វសាយ ល្វងពីពង្សកាយ
ក្រាបថ្វាយទូលសព្វសេចក្តី ។
234 អំពីក្រហោមចក្រី ដូចដើមសេចក្តី ឥតបីឃ្លាងឃ្លាតអតីតា ។
235 កាលនោះព្រះចៅយុធ្យា ទ្រង់ព្រះចិន្តា ថាឯអង្គចន័យល់ឆ្គង ។
236 ថាបើនាម៉ឺនមានហ្មង គិតក្បត់ម្តេចម្តង
ចងកាប់សម្លាប់បានហើយ ។
237 តួរខ្លួនចូលដល់ម្តេចឡើយ ស្ងៀមស្ងាត់ព្រងើយ
កន្តើយពិតពុំនាំពា ។
238 កាលនោះព្រះចៅយុធ្យា ទ្រង់ព្រះចិន្តា ថាបើដូច្នេះគួរអញ ។
239 ប្រើពញាយោមរាជចេញ ទៅសាកសួរវិញ
ឲ្យដឹងដំណើរនោះកូវ ។
240 គិតស្រេចស្តេចត្រាស់ឲ្យចៅ ពញាយោមរាជ
នៅថៃយណាម្ទរូងមើងបីបាន ។



241 មកដល់មណ្ឌលក្សត្រក្សាន ដល់ហើយស្តេចមាន
ព្រះរាជឱង្ការត្រាស់ថា ។
242 ឲ្យនាំពលពាលយោធា មកសួររាជា កក្រុងកម្ពុជាបូរី ។
243 រីឯអង្គពញាទាំងបី ឱនអង្គសិរសី ស្តាប់ដឹងសេចក្តីសាសព្វ ។
244 គ្រួចក្រាបស្រពាប់ឱនអភ្ញ ភិវាទគំរប់ ទទួលបន្ទូលឱង្ការ ។
245 ស្រាប់ស្រេចរំពេជល្មុតលា នាំពលយោធារ
យល់ជាមួយពាន់ប្លាយបាន ។
246 មកដល់មណ្ឌលទីស្ថាន ស្រុកន្នាមាមាន
ហៅហិនអង្វែរនោះឯង ។
247 ទើបពញារូងមើងចាត់ចែង ជុំទប់អង្គឯង
ព្រះសរសម្តែងនាម្នា ។
248 ឲ្យដើរបែកចេញពីគ្នា ពលពីរយហា
សិបសិងលេលាមកអាយ ។
249 ដើរផ្លូវត្រូវកំពង់ស្វាយ រាងរាបមកអាយ
ដល់ខែត្តបារាយឈប់នៅ ។
250 សឹងគិតរាតត្បាតកំដៅ រាស្ត្រខ្មែរស្រុកក្រៅ
ក្នុងខែត្តទាបនឹងភូមិធំ ។
251 ឲ្យរើសយកកូនក្រមុំ រាស្ត្រខ្មែរទៅជុំ
ទៅភូមិបារាយណ៍បាណក ។
252 មកភូមិទ្រាលប្រិចរើសយក បាននាំចូលមក
ជួបជុំនៅភូមិបារាយណ៍ ។
253 ឯអស់អង្គអាពុកម្តាយ សឹងសោកសឹងស្តាយ
អាណិតដ្បិតបុត្តសង្សា ។
254 យកដៃដាល់តប់ឱរា ក្តួលក្តៅខ្លោចផ្សារ
ស្មើរនិងមរណាអស់ប្រាណ ។
255 តំណើរនោះស្ទេះឈប់ខាន ទើបទៅនិទាន
ឯពញាយោមរាជនោះវិញ ។
256 ក្រោយចាត់សរសម្តេះចេញ យមរាជឯងមិញ
ថៃយណាមនៅរូងមឿងម៉ា ។

257 បានដល់មណ្ឌលវាំងរក ស្ដេចពុំឃើញបក
សំបុត្រច្បាប់មួយទូលទៅ។
258 ឲ្យអស់អាមាត្រក្នុងក្រៅ ក្រាបទូលព្រះចៅ
ដោយនូវដំណើរអក្ខរា។
259 ស្ដេចបានដឹងតាមអតិតា អង្គចំនួក្សត្រា
ត្រេចត្រូវទៅយួនស្មោះស្ម័គ្រ។
260 ស្រេចស្ដេចប្រើទៅស្មៀនស្មេរម្នាក់ ធ្វើបន្ទូលតាក់
ប្រើតំណើរព្រះអាមាត្រ។
261 អញ្ជើញព្រះបន្ទូលសីហនាដ្ឋ ចុះដើងទឹកស្អាត
កំពតសំពៅត្រូវត្រង់។
262 ទៅស្ដេចទេព្ដាពុំលង់ ដល់ហើយឱនអង្គ
ក្រួចក្រាបទូលថ្វាយរាជសារ។
263 រីឯអង្គស្ដេចទេព្ដា ឲ្យស្មៀនសូតសារ
អស់អាតំណើរសេចក្ដី។
264 ស្រាប់ស្រេចស្ដេចបន្ទូលខ្វី ដោយដើមសេចក្ដី
ពីបុរីបុរាណរាជា។
265 ថាឯស្ដេចខ្មែរនោះណា នគរតូចជា ឲ្យទុកជាកូនពុំងា។
266 នគយួនយើងនៅអាយ លោកទុកជាម្ដាយ
បង្កើតពិតពុំដទៃ។
267 នគរពុទ្ធិចៅនោះន័យ ពិតពុំដទៃ ទុកលោកស្មោះស្មើអាពុក។
268 បើកូនមាននោកនុក[1] ខុសនិងអាពុក
ទោសទុកទៅខ្ញុំដើងម្ដាយ។
269 ឲ្យអង្គអាពុកនៅអាយ គុណគិតវែងឆ្ងាយ
រំសាយលែងទោសទាន់ទុក។
270 បើខុសនិងម្ដាយមិនសុខ រតរកអាពុក
ទោសទុកឲ្យម្ដាយលែងចេញ។
271 ស្ដេចបន្ទូលថានោះមិញ ធ្វើបន្ទូលវិញ ឲ្យអាមាត្រនាំទៅ។

[1] Il faut lire ឆោកឆ្នុក "outrepasser, exagérer".



272 ទូលទាល់សម្ដេចពុទ្ធិចៅ ស្ដេចជ្រាបដោយនូវ
តម្នើដើមដានអក្ខរា។
273 ស្ដេចប្រើបំរើម្ទីម្នា បនថយអស់ពញ្ញា
យោមរាជរូងមឿងថៃយណាម។
274 យោមរាជរូងមឿងសឹងតាម ទាំងពញ្ញាថៃយណាម
សឹងតាមបំរើពុទ្ធិចៅ។
275 លេលាយាត្រាវិលទៅ ទីស្ថានលំនៅ បង្គំពុទ្ធិចៅឥតប្រួង។
276 រីឯដំណើរទំនង រាជសារនោះហោង
ជាសុខស្ងួស្ដីខ្មែរមកក្សាន្ត។
277 ទុកស្លេះនៅនោះនិទាន ទៅឯក្សត្រក្សាន្ត
ព្រះបាទឧទៃរាជា។
278 ក្រោយសាព្រះអាមាត្រលា នោះស្ដេចទេព្ដា
ចាត់ប្រើឲ្យអ្នងតាគុន។
279 · នាំស្ដេចមកទីតម្បូន់ ឯអ្នងតាគុន
ក្រាបផើបលុតលាចរចេញ។
280 មកដល់មណ្ឌលស្ដេចវិញ វាំងចាស់នោះមិញ
ឯអ្នងតាគុនគិតថា។
281 និងស្ដេចឲ្យប្រើសេណា មន្ត្រីយោធារ ធ្វើវាំងនៅនាភ្នំពេញ។
282 ឲ្យរើធ្វើជាថ្មីវិញ អ្នងតាគុង[1] មិញ ក៏ទុកអ្នងឲ្យមួយឈ្មោះ។
283 បាហោនៅឈរចំពោះ រក្សាស្ដេចនោះ
នៅជាឯជើងវាំងវិញ។
284 ឯវាំងមហាក្សត្រនោះមិញ អគ្នេយភ្នំពេញ
ជិតមាតទន្លេ៤មុខ។
285 គិតស្រេចអ្នងតាគុងទុក រាជ្ញាគ្រប់មុខ
ទុកលើល្វងនិងអ្នងស្មោះ។
286 រីឯអ្នងតាគុងនោះ លាល្វងបរបោះ ចេញទៅនៅព្រៃគរ។
287 ឯល្វងនៅអ្នងបាហោ តែងប្រើទៅមក ថ្វាញ់ព្រៃនគរពុំតេច។

[1] Il faut lire អ្នងតាគុន .

288 បទព្រហ្មគិតកាប់ ចរចាចាប់ចង់ពាក្យពេជ្រ
ពីក្រោយនោះបន្តិច រើបអង្គស្តេចឧទៃរាជា។
289 ស្តេចគង់សុកសប្បាយ ខ្មែរមលោះលាយអង្គឯងអាច
ស្តេចឲ្យទូនយោមរាជ ដរចៅហ្វាកាលនោះមិញ។
290 ឡើងសក់សឹងជាធំ ជ្វាចាមជុំចូលពាសពេញ
ចៅហ្វារទូននោះមិញ តាំងចិញ្ចឹមជាងទាំងឡាយ។
291 សុទ្ធសឹងតែចាមជ្វា ឲ្យធ្វើជាងសុះសព្វសាយ
គ្រប់ខែត្តផងទាំងឡាយ សឹងជានាយជាធំធ្ងន់។
292 កាលនោះអ្នកតាគុង ខ្មើយមានបុណ្យស័ក្តិសមសួន
គាត់ប្រើបំរើឃ្លួន មកបង្គាប់ម្ចាស់យើងអាយ។
293 ឲ្យគិតកែនយកមនុស្ស ខ្មែរឲ្យអស់ខែត្តទាំងឡាយ
សំនួនពលពីរអាយ អស់គ្រួបនាយ៥ម៉ឺនគត់។
294 ហើយឲ្យមានមន្ត្រី ត្រួតបញ្ជីជាកំណត់
៥ម៉ឺនមែនប្រាកដ ទើបអ្នកឲ្យលេងទោសនោះ។
295 បទអ្នកចង់ជីកដី ព្រែកជាថ្មីកាត់ទំលុះ ពីពាមមាត់ជ្រូកនោះ
កាត់ទម្លុះត្រង់ទៅ។
296 ត្រូវពាមព្រះសោទិត មាត់ស្រុកទ្រនោះឯងកូវ
ហេតុនោះអ្នកឲ្យត្រូវ កែនមនុស្សទៅជួយរាជការ។
297 ព្រះបាទឧទៃរាជ ភិតខ្លបខ្លាចអ្នកណាស់ណា
ចាត់ចែងចែកយោធា ចេញដោយនាខែត្តទាំងឡាយ។
298 ឯព្រះរាជអាញ្ញា ចេញត្រួតត្រាខេត្តបារាយណ៍
កាលនោះនាមចៅហ្វាយ សែរង្វាងហ្វារក្សាស្រុក។
299 ឯដើមដំណើរនោះ តាមហៅឈ្មោះឧកញ៉ាម៉ុក
ធ្វើជារក្សាស្រុក ស្នងនាមនោះឈ្មោះហៅកែ។
300 គិតកែនមនុស្សទាំងឡាយ ខែត្តបារាយមកបង្ហែរ
ចូលជុំផ្ទះស្នងកែ គិតថ្វូនថៃអស់គ្រប់គ្រាន់។
301 សំនួនតាមបញ្ជី ចែកពិតពីក្បាលខែត្តខាន់
ទើបចែកមេគិតកាន់ តាមសំនួនកូនក្រុំមេ។
302 ឯអង្គឧញ្ញាម៉ុក ផ្តាំដាក់ទុកនិងស្នងកែ



ឲ្យមើលឲ្យធ្ងនថែរ ធ្វើជាមេធំសម្រេច។
303 ផ្តែផ្តាំអស់ហ្មត់ហ្មង រៀបផ្លូវផ្គងចេញចរត្រាច់
នាំមនុស្សទៅថ្វាយស្តេច ដូចតំរាស់ព្រះអាជ្ញា។
304 ព្រះបាទឧទៃរាជា រាស្ត្រភ្លបខ្លាចឥតឧបមា
កែនបានមកត្រៀបត្រា គ្រប់សំនួនបញ្ចូនអស់។
305 ហើយត្រាស់ឲ្យឧកញ៉ា យោមរាជជាងដើមឈ្មោះ
រស្សនាំមនុស្សទៅទាំងអស់ ជាមេកងជីកព្រែកនោះ។
306 យោមរាជរស្សជាធំ មេកងជុំជិតពិគ្រោះ
និងជីកព្រែកនោះទំលុះ តាមអ្នកនោះវាសចែកចាយ។
307 រីឯអង្គស្នងកែ ដែលជាមេខែត្តបារាយ
យោមរាជរស្សជានាយ ធំសំរេចដាច់រាជ្ការ។
308 ស្នងកែគាត់មិនខ្លាច បុណ្យយោមរាជរស់ធំជា
សំរេចដាច់រាជការ បង្គាប់ការពុំកោតខ្លាច។
309 គាត់អាងបុណ្យក្សត្រា ទ្រង់ករុណាអង្គឯងអាជ្ញ
ហេតុនោះគាត់ពុំខ្លាច ពុំកោតក្រែងយោមរាជសោះ។
310 ឯឧកញ៉ាយោមរាជ យល់ពុំខ្លាចខ្លួនដូច្នេះ
សំគាល់ទោសទាំងនោះ ចំណាំចាំទុកទៅ។
311 លុះចាប់ជីកព្រែក អ្នកឲ្យចែកនាយមួយកូវ
កូន១០ដើរមួយផ្លូវ សែងដីទៅទាក់ទាល់ទើស។
312 ប្រាំបីនាក់ស្នែងប្អូន គិតសំនួនប្រនិកពីរ ឲ្យចាំជីកនៅទី
ក្នុងពោះព្រែកចែកនោះហោង។
313 នាយមួយមានឃ្លួនបី ចាំក្បាលទីចុងទីផង
កណ្តាលឃ្លួនមួយផង ចាំវាយខ្នងឲ្យរត់ឆាប់។
314 ដើមទីប្រើកើបដី មិនឃ្លាតខ្មីខំប្រញាប់
អង្គុយកើបវាយខ្វាប់ៗ ឲ្យឈរកាប់កកាយវិញ។
315 កើបបានហើយឲ្យឯង លើកលីសែងរត់ឃ្លាតខ្នាញ់
ដល់ចុងទីនោះមិញ ឲ្យរលាក់ចាក់ប្រញាយ។
316 បើធ្វើឲ្យយឺតយូរ មិនបន្ទូរឲ្យធ្លាក់ឆាប់ ចុងទីវាវាយខ្វាប់
ឲ្យប្រញាប់វិលវិញ។
317 តែងសែងរត់ទៅមក មិនឲ្យជ្រកដល់តិចសោះ

រីមនុស្សអស់ទាំងនោះ ស្មើរនិងសោះស្លាប់ទីទៃ ។
318 ដរាបដល់ព្រលប់ ចាស់ដេកលុកយប់នោះនៃ
ទើបអ្នងឯងឲ្យវាយ ត្រដោកឈប់យប់ដេកនៅ ។
319 លុះមានរងាវក្ស វាយឲ្យចុះលើកទៀតទៅ
សព្វថ្ងៃដូច្នេះកូវ រាស្ត្រនឹងនៅទ្រាំពុំបាន ។
320 អង្គុរអ្នងឲ្យដាក់ ជាដំណាក់រាស្រគប់ប្រាណ
អណ្តែតលើទឹកបាន ឃ្លានប៉ុន្មានលេបចង្អោរ ។
321 អង្គុរគេដាក់ឃ្លាង គេបំព្រាងទឹកកំបោរ ខំលេបទៅចង្អោរ
ហើយហើមពោះចុកផ្ទៃផង ។
322 ឯទឹកសោតសឹងល្អក អាសោចល្អកក្រែកន្លង
ដោយសារមនុស្សច្រើនផង នឹងរករុងកលគិតគ្មាន ។
323 ឯមនុស្សផងគ្រប់គ្នា ខំធ្វើការហើយស្រេកឃ្លាន
និងផឹកទឹកមិនបាន អស់អង្គប្រាណរលាស់ទីទៃ ។
324 ដល់ដាលទៅជាឈើ មានជម្ងឺលុះក្សិណក្ស័យ
លំបាកពន់ពេកក្រៃ ល្វិតល្វើយល្វៃអស់អាត្មា ។
325 អស់រាស្ត្រផងទាំងឡាយ ពុំសប្បាយបទរាជការ
នឿយហត់អត់គ្រប់គ្នា នឹងភោគ្គាពុំពេញពោះ ។
326 ពលខ្មែរគ្រប់សំនួន ដោយពលយួនធ្វើការនោះ
ដោយគិតគួរពីគ្រោះ ទាំងអស់នោះសែនមួយប្លាយ ។
327 ចុះម្តងដាក់ដោយទី គ្រប់បញ្ជីពលទាំងឡាយ
សំនួនឯចម្ងាយ ដើរគិតផ្លូវត្រូវយប់ ។
328 ទើបផុតអស់ពួកពល ធ្វើការយល់យួនប្រសព្វ
ពួកខ្មែរយើងទាំងគ្រប់ ពុំប្រសព្វការទាន់យួន ។
329 គេចុះទីណាម្តង រួចហ្មត់ហ្មងគ្រប់សំនួន គេចាំងគ្រប់ខ្លួន
បានសំនួននឹងបើកទឹក ។
330 អ្នងឲ្យគេប្រាមប្រាប់ ធ្វើឲ្យឆាប់រួចពីព្រឹក
ស្រេចហើយគេបើកទឹក ហូរគគិកពេញពោះព្រែក ។
331 អ្នកណាឃើតដៃជើង ពិតពុំឡើងកាលគេស្រែក
លិចលុងក្នុងពោះព្រែក ព្រោះហូរប្លែកណាស់នៃ ។
332 ហូរចូលបាតតើក ខ្លាំងពន្លឹកពន់ពេកក្រៃ



លិចលុងក្នុងនោះក្ស័យ សត្វដោយន័យគង្គារហោង ។
333 ទទឹងព្រែក១០ព្យាម ជំរៅទាម៥ព្យាមស្មោះ
លិចលង់ក្នុងព្រែកនោះ សត្វសានចុះដោយទឹកទៅ ។
334 ធ្វើការជីកព្រែកនោះ ហៀបនឹងបានស្រមុតក្រៅ
មនុស្សនឿយណាស់និងនៅ ពិតពុំបានបទស្លាប់ណាស់ ។
335 វានឿយហើយស្គមស្គាំង អន់កំឡាំងពុំរហ័ស
យួនយល់ឃើតវាសណាស់ ថាខ្មែរចាស់ពុទ្ធវាច្រើន ។
336 វាយដំកំរើកខ្លួន នោះឯងយួនរីតរឹងខឹង ថាខ្មែរមិនខំប្រឹង
វាបានដឹងវាយពុំលែង ។
337 បើវាយពុំកក្រើក ពុំរំពើកខ្លួននោះឯង
ទើបបានយួនវាលែង ល្មមតែឯងស្លាប់ប្រាកដ ។
338 ខ្មែរយល់យួនដូច្នេះ គិតគ្នាស្រុះស្រាប់សន្មត់
យល់យប់ស្ងាត់ប្រាកដ គិតគ្នារតចេញប្រញាយ ។
339 រត់ចរចាកចេញទៅ ដោយនៅស្រុកជិតឆ្ងាយ
គ្រប់ខែត្តផងទាំងឡាយ បែកខ្ចាត់ខ្ចាយគ្នាទីទៃ ។
340 ខ្លះរត់រួចដល់ទៅ ទីលំនៅឯងនោះន័យ នាំកូនចៅចូលព្រៃ
ពឹងប្រាស្រ័យលាក់អង្គប្រាណ ។
341 ខ្លះមានទន្លេខាន់ ទៅពុំទាន់ដល់ទីស្ថាន លួចទូកឆ្លងពុំបាន
នៅយប់ខានពួនទីព្រៃ ។
342 ព្រោះខ្លាចគយល្បាតគេ គ្រប់ទន្លេព្រែកធ្វែកន្សៃ
រង្គាត់តែសព្វថ្ងៃ បើបានដៃចាប់ជូនអ្នង ។
343 អស់រាស្ត្ររត់ទាំងឡាយ និងនិយាយឲ្យចប់ចុង
វាច្រើនណាស់បង្អង់ និយាយចុងឯក្រោយវិញ ។
344 បទកាលក្រោយរាស្ត្ររត់ អស់ប្រាកដនោះឯងមិញ
យោមរាជរស់គេចេញ ទៅប្តឹងអ្នងឯងសព្វសាយ ។
345 ថារាស្ត្ររត់ទាំងនេះ ហេតុជំនេះ[1] ស្នងបារាយ
ស្នងកែជានាយ[2] នាំនិយាយឲ្យរាស្ត្ររត់ ។
346 ទើបរាស្ត្រខែត្តឯទៀត វាឈ្លបឈ្លៀតដឹងប្រាកដ

[1] Il faut lire ចំណេះ "cânnéh], qui signifie "idée, intention, volonté".

[2] Ce morceau est emprunté à la version imprimée, *Rœang Roba khsat srok khmer*, vol. I, p. 39.

ថាស្នងកែគេមុត ឲ្យវារត់ទៅកុំខ្លាច។
347 ឯអ្នុងយួនបានស្ដាប់ អស់សារសព្វពាក្យយោមរាជ
ថាស្នងកែគិតកាច អាចបញ្ចេះរាស្ត្រទាំងឡាយ។
348 អ្នុងយួនពុំពិគ្រោះ ឲ្យជំពោះពាក្យនិយាយ
ចូលចិត្តដើរសព្វសាយ គិតចាត់ចាយចេញចោមចាប់។
349 រីឯស្នងកែនោះ ពុំដឹងគ្រោះក្រនិងស្លាប់
លុះតែគេចោមចាប់ ចងបានខ្ជាប់ភ្ជាក់អាត្មា។
350 ពុំដឹងទោសកលអ្វី និងស្រដីដោះទោស្សា គេចាប់ចងអាត្មា
និងទៀបទៅសម្លាប់។
351 ដោតក្បាលជាបម្រាម កុំឲ្យតាមយកតម្រាប់
ស្រេចហើយគេយកទ្រព្យ គ្រឿងប្រដាប់ឥតសង្ស័យ។
352 ចិញ្ចៀនត្បូងមាសប្រាក់ ដែលគាត់ពាក់គ្រប់ម្រាមដៃ
គេបូតយកទីទៃ អង្គឯងក្ស័យសូន្យអាសារ។
353 ឱះឱរូបសព្វសត្វ គួរគន់គិតរូបរាល់គ្នា ទ្រព្យធនបុនស័ក្ត
សឹងឥតការដូច្នេះឯង។
354 ឯរូបចោលនៅដី ជាចំណីក្អែកត្មាតខ្លែង វាចិកវាជញ្ជែង
ជាចំណីនៅក្នុងព្រៃ។
355 កាលអ្នុងឲ្យចោមចាប់ ចងស្នងខ្ជាប់បាននោះនៃ
ក្រាបដល់ក្សត្រជៀសជ័យ ឧទៃរាជរិះគិតឆាប់។
356 ស្ដេចត្រាស់ឲ្យអាមាត្រ ចរខ្មីឃ្មាតជាប្រញាប់
ទៅសុំកុំឲ្យកាប់ និងឲ្យទ្រព្យជារង្វាន់។
357 អាមាត្រចរចេញទៅ តាមដោយនៅក្សត្រសោភ័ន
អាមាត្រទៅមិនទាន់ គេក្ដួបកាប់គិតមុនស្រេច។
358 អាមាត្រដឹងដើមក្ដី វិលវឹងខ្មីចេញចរត្រាច់
មកទូលទាល់អង្គស្ដេច ដោយដំណើរនោះសព្វសាយ។
359 ស្ដេចស្ដាប់អាមាត្រទូល ក្សត្រឥតសូរសោយសោកស្ដាយ
ស្នងនោះព្រោះប្រាជ្ញប្រាយ គិតការថ្វាយពិតពុំឆ្គង។
360 ប្រាជ្ញាគាត់វៀងវៃ អាឈ្យាស្រែកិច្ចការចង
ពាក្យពេជល្បាចល្បិកល្បង ទាក់ណែងណងវៀងរាបទាប។



361 គាត់ចេះទាំងឆ្លាក់គូរ ក្បោះក្បាច់ក្បូរផងដរាប
សំដីពីរោះរាប ត្រូវព្រះទ័យមហាក្សត្រា។
362 [ហេតុនោះមហាក្សត្រថ្លៃ សព្វព្រះទ័យតែងករុណា
ស្ដេចសែនសោយសោកា រកអ្នកណាដូចគាត់គ្មាន។
363 ស្នងកែគាត់ក្សិណក្ស័យ សូន្យនៅព្រៃព្រីក្សស្មសាន្ត
បងប្អូនសាច់សន្ដាន វិលវឹងថ្កានភូមិបារាយណ៍។
364 គេចូលទៅប្ដឹងប្រាប់ អស់សាសព្វសូន្យនៅនាយ
ឲ្យកូនប្រពន្ធម្ដាយ ញាតិទាំងឡាយដឹងដើមដាក់។
365 គេចាប់ត្បិតស្នងកែ យួនឯងឯគិតសម្លាប់
ប្លង់ប្រើបំរើឆាប់ ឲ្យទៅសុំពុំទាន់ឡើយ។
366 នាងយូបានស្លែងស្ដាប់ ពាក្យគេប្រាប់ដូច្នោះហើយ
សឹងសោយសោកជាត្រើយ៉ ពិតពុំស្បើយពីទុក្ខា។
367 ផ្ទុកផ្ទើះទង្គិះគិត អួលអាណិតប្ដីអាត្មា
ក្សីកក្សួលក្ដួលក្ដៅផ្សារ ស្មើរមរណាជីវិតប្រាណ។
368 ដំណើរដំណែងភាព គិតវៀងរាបតាមដោយដាន
តំណាលកាលយួនបាន គិតសម្លាប់ស្នងនោះឯង។
369 សង្ខេបទុកត្រឹមនេះ និងរករិះរកចាយថែង
និយាយស្រាយតែង ពីសិលសង្ឃក្នុងរាជនោះ។

370 បទកាក្គតែង តំណើរដំណែង តំណាលកាលនោះ
នគរកើតហេតុ ភិនភេទក្រគ្រោះ មានសង្ឃមួយឈ្មោះ
ហៅអ្នកភិក្ខុកែរ។
371 ហើយមានមនុស្សម្នាក់ ចូលទៅពឹងពាក់ បួសជាសម្មែរ
នេននោះឈ្មោះកុយ ប្រថុយខ្លួនតែ តាមអ្នកភិក្ខុកែ
ឥតឯមានឃ្លាត។
372 តែងជាអ្នកថ្មី នាំនេនកុយដើរ គិតដោយសង្វាត
រករៀនសីលសែ សព្វថ្ងៃខ្មីឃ្មាត នេនកុយសង្វាត

[1] Les strophes 362, 363, 364, 365, 366, sont empruntées à la version imprimée *Rœang Roba khsat srok khmê*, vol. 1, pp. 41-42.

ចេះចាំជាក់ស្ពាត់។
373 ដើរដល់ស្រុកណា បាសកតិការ មូលមករកគាត់
ទោះមានបើឈើ ជម្ងឺតម្កាត កាន់ទ្រួយដល់មាត់
ជម្ងឺសះសាន្ត។
374 ទោះទាំងលោកិយ ចោលខ្យល់ថ្មីៗ សិងសះស្រាកស្រាន្ត
សារពើរោគា យាយីក្នុងប្រាណ សោតសិងសះសាន្ត ឥតឯអំពល់។
375 មួយសោតគាត់តែង សូតសែកសម្តែង សិលសាស្ត្រគ្រប់កល
សិងតែឆាប់ឆុត ប្រាកដឥតទាល់ មនុស្សផងខ្សៀវខ្សា
មូលមកឥតអឹក។
376 រស់រកភិក្ខុកែ រេនកុយបង្អែរ បង្ហូតឥតស្រាក គ្រប់ថ្ងៃគ្រប់ខែ
ហូរហែឥតអឹក ពេញចូលពីងពាក់ រកសិលសាស្ត្រសែយ។
377 ឮលេចខ្ចរខ្ចាយ ទៅស្រុកជិតឆ្ងាយ គ្រប់ខែត្តទីទៃ
សិងចូលមូលមក រកគាត់សព្វថ្ងៃ តាមតែប្រាស្រ័យ
រកអ្វីសិងបាន។
378 កាលនោះពុំស្ងាត់ ឮសេចខ្ចរខ្ចាត់ ដល់ក្សត្រប្រធាន
ទាំងអង្គបាហោ ដែលឈរនៅស្ថាន កំដរក្សត្រក្សាន្ត
សិងបានឮជាក់។
379 ថាកើតសីលសង្ឃ អ្នកភិក្ខុមួយអង្គ និងសម្នេ ម្នាក់
អស់រាស្ត្រទាំងឡាយ ខ្វល់ខ្វាយពិងពាក់ ចេញចូលគ្រឹកគ្រាក់
ឥតអឹកសព្វថ្ងៃ។
380 មន្ត្រីយោធារ កែនធ្វើរាជការ ពុំបានឡើយនៃ
រាស្ត្រអាងសិលសង្ឃ ប្រុងខ្លួនទីទៃ មេៗនោះនៃ មិនហ៊ានខិតខំ។
381 ស្តេចជ្រាបដូច្នេះ ទ្រង់គិតពិគ្រោះ និងនាហ្មឺនធំ
ទាំងអង្គបាហោ សិងមកជុំនុំ ប្រើមន្ត្រីធំ ទាំងពីរនោះហោង។
382 ប្រើទូនចៅហ្វារ សម្តេចចៅពញារ នរេនតុលផង
យកទាំងកៃព្រាល ពលពាលកែនកង ច្រើនក្រៃកន្លង
ទ្រហឹងអឹងអឹប។
383 ទាំងពលយួនផង លើកទៅប៉ុនប៉ង និងគិតចោមចាប់

¹ Il faut lire សាមនេរ qui désigne un jeune religieux.



ទៅដល់សីលកែរ ប្រែខ្ទៃតាំងទ័ព ទាំងឡាយគិតកាប់
យួនអស់ឥតសល់។
384 សម្តេចចៅពញា ទូនជរចៅហ្វា និងរិះរកកល តទ័ពពុំបាន
បទគ្មានពួកពល ចូលគេឥតសល់ ទាំងកៃរព្រាលផង។
385 នរេនតុលក្តី ទោះទាំងមន្ត្រី ខាងល្វងនោះហង
សឹងចូលសិលកែរ ខ្វរព្រៃប្រឡង កាប់យួនវិញហង
អស់ឥតគ្មានសល់។
386 សម្តេចចៅពញា ទូនជរចៅហ្វារ នឹងតាំងទ័ពទល់
នឹងគេពុំឈ្នះ លាក់លាជ័យដល់ ហ្លួងនិងអង្គយល់ ទូលជម្រាបទៅ។
387 តាមដោយរាជការ សព្វគ្រប់ប្រការ ប្រាកដនោះកូវ
ហ្លួងអង្គបានជ្រាប ដរាបស្ងៀមនៅ យូរបន្តិចទៅ បន្ទូលត្រាស់ថា។
388 ឲ្យហៅអស់ក្រុម ស្មៀនផងមកជុំ ទើបមានឱងការ
ឲ្យតែងបន្ទូល រំពេជម្ហ៊ីម្ហា ទើបមហាក្សត្រា ឲ្យចេញជាឆាប់។
389 ទើបអង្គអាមាត្យ ក្រាបលាព្រះបាទ ទៅដោយបង្គាប់
ទាំងយប់ទាំងថ្ងៃ រ៉ៃៗប្រញ៉ាប់ តាមទ្រង់បង្គាប់ ដល់ព្រៃនគរ។
390 ដល់ហើយចរចូល នាំព្រះបន្ទូល ក្សត្រក្សានភូធរ
ចូលដល់អង្គធំ ថ្នាញព្រៃនគរ ទើបអង្គសួរមក៍ មានបើហេតុអ្វី។
391 ទើបឯអាមាត្យ ហុចបន្ទូលស្អាត ទៅអង្គនោះខ្មី
អង្គឲ្យថីញាយ ស្ត្រស្រាយសេចក្តី សព្វគ្រប់អំពី កង្វល់ស្រុកខ្មែរ។
392 បទមានសិលសង្ឃ អភិក' មួយអង្គ នាមនោះឈ្មោះកែ
អង្គតាគុនតឹង ដំណឹងស្រុកខ្មែរ ដូច្នោះប្រុងប្រែ ប្រដាប់ជើងទឹក។
393 ទ័ពទូកចម្បាំង ពលពាលស្រិតស្រាំង ច្រើនក្រៃសន្ធឹក
ទង់ជ័យដេរដាស ពេញពាសពន្លឹក គ្រប់គ្រឿងជើងសឹក
ស្រេចហើយចរចេញ។
394 អស់អង្គបម្រើ ដែលតាគុនប្រើ មកច្បាំងនោះមិញ
ខឹងនឹងសិលកែ បទតែគាត់ចេញ កាប់យួននោះមិញ
មិនចូលស្តេចឡើយ។
395 លើកលែងបាភ្នំ សន្ទូរត្បូងឃ្មុំ ព្រៃវែងនោះហើយ

¹ Il faut lire ភិក្ខុ.

តាំងទ័ពគោកទឹក ពន្លឹកជាត្រើយ តទល់គ្នាហើយ
ឥតបានបង្អង់ ។

396 កាលនោះតាកែ បង្អក់ពលខ្មែរ ស្ទុះត្រសែកសិលសង្ស
ឲ្យមានតេជា រីតប្បាពលពង្ស រលាស់ទឹកត្រង់
ពលពាលទាំងឡាយ ។

397 ឲ្យឈ្នះសត្រូវ កុំឲ្យយួននៅ បាក់បែកខ្ចាត់ខ្ចាយ
បើយួននោះចាញ់ ឲ្យចេញជាឆ្ងាយ កុំឲ្យមករាយ
ដល់ពលខ្មែរឡើយ ។

398 បង្អក់រួចស្រេច តាំងទ័ពរំពេច ពិតពុំព្រងើយ
លើកចេញដេញយួន យួនបាញ់មកហើយ ពុំត្រូវខ្មែរឡើយ
ស្បើយធ្លាក់មិនដល់ ។

399 រីឯកែព្រាល ស្ទុះទៅកណ្ដាល និងនរេនតុល គាត់មានកំឡាំង
ខ្លាំងលើសអស់ពល គាត់ស្ទុះទៅដល់ ពលយួនទាំងឡាយ ។

400 ភិតភ័យភឹនភាំង តក់ស្លុតស្លាំងកាំង ទន់អស់អង្គារ
កែព្រាលគាត់កាប់ បាក់ទ័ពខ្ចាត់ខ្ចាយ ពលយួនទាំងឡាយ
លុះក្ស័យជន្មា ។

401 រង្គាររង្គាល ខ្ចាយឈាមប្រាសប្រាល ពាសពេញពសុធារ
ដូចគេកាប់ចិត ដួលដេកត្រៀបត្រា យួនយល់រអារ
បាក់បែកទ័ពទៅ ។

402 ទោះទាំងជើងទឹក ពលយួនភ្លាំងភ្លឹក ពុំអាចនិងនៅ
ខ្លាចទ័ពតាកែរ ពលខ្មែរដេញទៅ ពុំអាចនិងនៅ
ថយទៅភ្នំពេញ ។

403 ឯអស់ពលយួន ដែលដួលស្លាប់ខ្លួន ទាំងអស់នោះមិញ
ចោលទាំងគ្រឿងក្រោះ ប្រដាប់ពាសពេញ ក្នុងទូកនោះមិញ
យួនយកមិនទាន់ ។

404 ឯអង្គតាកែរ យល់ពលពួកខ្មែរ មានជ័យជាក់ស្បាន់
នាំកងទ័ពទៅ នៅកោះសូទិន គិតថាយួនមិន
ហ៊ានច្បាំងផងឡើយ ។

405 គិតធ្វើបុណ្យឯង ករក្រីកគក្រេង លេងសើចព្រងើយ
ពុំដឹងក្រគ្រោះ ខ្លួននោះតិចឡើយ ថាយើងម្លេះហើយ



ឥតទោសទុក្ខា ។

406 ឯអស់អ្នងយួន ចរចូលចង់ខ្លួន និងមហាក្សត្រា
ឲ្យចាប់សីលកែរ ខ្មែរក្រាំងឲ្យវា ពលស្ដេចទេព្ដា ខូចខាតច្រើនក្រៃ ។

407 បើស្ដេចមិនគិត ចាប់ខ្មាំងបាំងបិទ ទោសទាំងនោះន័យ
ផ្ទេរផ្ទុកលើមហា ក្សត្រាជៀសជ័យ និងទៅទូលន័យ
អង្គស្ដេចទេព្ដា ។

408 ស្ដេចស្ដាប់ពាក្យយួន អស់អ្នងផ្ទងខ្លួន ឲ្យដោយទោសា
មហាក្សត្រភិតភ័យ បាប្ញទ័យតកមា ប្រើទូនចៅហ្វារ
គិតកែនពលផង ។

409 យកចិនចាមជ្វារ នៅខ្មែរដែលជា អស់ឥតមានហ្មង
សម្ដេចចៅពញា ជិតាល្ងងផង ធ្វើជាមេកង ទ័ពទឹកលើកចេញ ។

410 នាម៉ឺនយួនផង ពលពាលកាយកង ច្រើនក្រៃពាសពេញ
ទាំងគោកទាំងទឹក ពន្លឹកចរចេញ ឯសិលកែមិន មិនដឹងខ្លួនឡើយ ។

411 និងលុះបានដែរ គេគិតឲ្យក្ស័យ អង្គឯងជាត្រើយ
ហេតុបាបបានធ្វើ អំពើគេហើយ ពិតពុំលេងឡើយ
លុះត្រូវវិងហោង ។

412 មួយសោតឯអង្គ បានបួសជាសង្ឃ សាងសីលលំដេញ
បែបង[1] ក្រមក្រិត្យ បន្ទាត់នោះមិញ សិល្បសាស្ត្រាចេញ
អស់ឥតសង្ស័យ ។

413 មិនមានពូកែរ នៅតែខ្លួនទេ ទុរយសតយជ័យ
ហេតុធ្វើអំពើ ពិតពុំប្រពៃយ ឯសិល្បសាស្ត្រសៃយ
សូនសោះឥតការ ។

414 កាលនោះទ័ពទឹក សន្ធាប់សំន្ធឹក ចោមជុំអាត្មា ពីទកោះសូទិន
មិនមានឃ្លាតឃ្លា ទើបទូនចៅហ្វារ បោះបាននិងនៅ ។

415 ឯអង្គកិក្ខកែរ បានយល់ពលរេ គេរោមជុំក្រៅ
អាងសិល្បសាស្ត្រសង្ឃ ក្នុងអង្គនោះនៅ សែកសំដែងទៅ
តាមដោយកលកិច្ច ។

416 បង្អក់ពួកពល ហើយបានទៅដល់ និងគេបន្តិច.

[1] Il faut lire បែរបង់ qui signifie "changer, abandonner".

ហេតុសាបសិលសង្ស      ពុំគង់កលកិច្ច  ចាញ់គេរំពេច
បាត់បែកខ្ចាត់ខ្ចាយ។
417 ឯអស់ពលយួន      នូវកងទ័ពទូន      ចាមជ្វាទាំងឡាយ
វាទោមចាប់កាប់  ស្លុតស្លាប់ខូចខាត      តោងទូកវាវាយ
កាប់ចាក់ធ្លាក់ចុះ។
418 ឯអង្គសិលកែវ      រត់រួចទៅតែ  ខ្លួនពួនចុងកោះ
គេហៅជ្រោយក្លាត      ស្បូវស្បាតច្រើនច្រុះ      គេបាញ់ចម្រុះ
ទៅត្រូវក្បិនក្បៀយ។
419 ឯយួនចាមជ្វា ពុំស្គាល់ជា សិលកែវនោះនៃ  ឃើញតែឯអង្គ
ព្រះសង្ឃដទៃ ចាក់កាប់ក្បិនក្បៀយ      ដួសន័យសិលកែវ។
420 ខូចខាតច្រើនណាស់      ទាំងសង្ឃគ្រហស្ថ  ពួកពលឯខ្មែរ
ខ្លះបានចូលក្នុង  កងទ័ពតាកែវ  ខ្លះខ្លួនគ្នាទេ  គេកាប់ស្លាប់ទៅ។
421 ទាំងសង្ឃគ្រហស្ថ   គេកាប់ច្រើនណាស់ ឈាមច្រាស់ច្រាលឆ្នេរ
ខ្លះសោតត្រសែត  អណ្តែតទឹកទៅ ក្រពើត្រីនៅ និងស៊ីមិនគ្រេក។
422 ត្រូវជួនជួបខែ      ភទ្របទនោះឯ      ភ្លៀងសោតសន្ទឹក
ប្រាំពីរទេវា  រាត្រីយប់ព្រឹក ពុំដែលដាច់ទឹក  ស្រកចុះនោះន័យ។
423 ពុំដែលនិងរាំង      តែតិចនិងខ្លាំង      ទាំងយប់ទាំងថ្ងៃ
ប្រាំពីរទិវា  រងាញើរដែរ      ពុំដែលឃើញថ្ងៃ  លេចភ្លឺងដល់ម្ល៉េះ។
424 ភ្លៀងអោរជោរជោគ      ស្រុកមិនស្រណុក      កើតហេតុភេទផង
ទឹកទន្លេធំ      ខែភ្ជុំនោះផង ធំលើសសព្វដង  ទៀងមកនោះឯង។
425 លេចស្រូវអង្ករ      លេចទីទួលល្អ លេចត្នោតលេចត្រែង
លេចត្មើងអន្លាម  លើរាមកំពែង      ឯក្រោយនោះឯង
ពុំទាន់ឡើគ្នា។
426 ឯអស់អ្នកយួន      នូវចៅហ្វាទូន      សម្តេចចៅពញា
បំបាក់ពលរេ  តាកែម្ចាស់នា  អស់ឥតសង្កា  នឹងសិល្បសាស្ត្រសែយ។
427 ឯនេនកុយនោះ      រត់រួចចេញស្មោះ      ទៅស្ថានភ្នាយក្រែ
ទៅទល់ហោរវង      ឥតក្រែងទោសភ័យ      នៅនោះសព្វថ្ងៃ
ជាសុកក្បែមក្សាន្ត។
428 ឯនរេនតុល      កែព្រាលវិលវល់      ពួននៅនាស្ថាន
អាយឯអ្នកឯង      តាក់តែងទាហាន  ចោមចាប់មិនបាន



ដូចដោយចិន្តា។
429 ទើបអស់អ្នកយួន  រកវិះគ្រប់ខ្លួន កិច្ចកលប្រាជ្ញា
ថាអង្គសម្តេច ចៅពញាចៅហ្វា ត្រង់និងរាជការ  ប្រាកដចិត្តល្អ។
430 គួរតែទៅដល់      ឲ្យអ្នកធំយល់  ថ្នាញព្រៃនគរ
ឲ្យអ្នកដឹងចិត្ត  គំនិតជាល្អ      អ្នកព្រៃនគរ  ក៏ឲ្យគ្រឿងស័ក្តិ។
431 សម្តេចចៅពញា      ទូនជរចៅហ្វា      ស្តាប់អស់អ្នកជាក់
ចូលចិត្តចិន្តា  ថាត្រូវស្មោះស្ម័គ្រ  ព្រមទាំងពីរនាក់  រៀបខ្លួនម្ពីម្នា។
432 ប្រុងប្រៀបប្រដាប់      គ្រប់គ្រងសំរាប់      ទូកទើបយាត្រា
អស់អ្នកផងខាន  ពុំបានលេលា  នៅចាំគិតការ  ឯក្រោយទៀតវិញ។
433 ប្រើតែអ្នកយួន      យកពលសំនួន      ឃុំនាំចចេញ
ទៅទៀតនិងដល់  មណ្ឌលថ្នាញវិញ  យួនហុំជុំវិញ  បង្គាប់ប្រាប់ថា។
434 ឥឡូវសម្តេច  ចៅពញាគិតម្តេច  ត្រូវនិងរាជការ
និងទៅហៅអ្នក      ក្នុងថ្នាញនោះជា  ខ្លួនទេនោះវា  ពុំសមសេចក្តី។
435 តាមដោយរាជការ      ច្បាប់យួនយើងថា      បើចេញមកពីរ
ចាប់សិកសត្រូវ  ច្នេះកូវគប្បី  ទទួលទោសក្តី  ទើបទៅហៅបាន។
436 សម្តេចចៅពញា      នូវទូនចៅហ្វា      ស្តាប់ដឹងដោយដាន
នឹងគិតប្រែប្រួល  រឹងត្អូញមិនហ៊ាន  ទទួលទោសបាន
ដូចដោយបង្គាប់។
437 ទើបអ្នកបំរើ  គិតស្រេចហើយដើរ      ចរចូលប្រញាប់
ហៅអ្នកតាគុន      ជាមុនស្រេចស្រាប់      ប្តឹងដោះទោរស័ព្ទ
សេចក្តីអស់នោះ។
438 [ឯអ្នកតាគុន  ដឹងហើយអរលេន  សើចឯងហាចុះ
ត្រូវនិងចិន្តា  អាត្មាឯងនោះ  អរអស់ពីពោះ  ពុំថ្លែងស្មោះស្មាន។
439 សម្តេចចៅពញា      នូវទូនចៅហ្វា      ទុកស្នេះនិន្ទា
លុះស្រេចសេចក្តី][1] ដោយន័យដើមដាន      ទើបទៅនិទាន
ដំណើរក្រោយវិញ។
440 និយាយឯអ្នក      ដែលបោះបង្អង់      ទ័ពទីភ្នំពេញ
គឺងតែងមហាក្សត្រ      ឲ្យចាត់ប្រើចេញ      រកកែវព្រាលវិញ
នរេនតុលផង។

---

[1] Ce passage ne figure pas dans la version imprimée *Rieang Roba khsat srok khmé*, vol. 1, p. 53.

441 ឯអង្គមហាក្សត្រ ព្រួយព្រះទ័យក្តាត់ ខ្លាចអ្វែងនោះហោង
ឲ្យជ្រើសមន្ត្រី ស្រដីឥតឆ្គង ប្រើទៅទន្ទង យកកែតុលមក។
442 ដំណើរនិទាន ពិតពីដើមដាន ដល់ស្តេចឲ្យរក
អ្នកមានប្រាជ្ញា គិតការមិនឆ្លក និងប្រើដើររក
យកកែការមកថ្វាយ។
443 រើសបានមន្ត្រី ចែងចេះស្រដី ពិរោះក្បោះក្បាយ
មែនមានប្រាជ្ញា វោហាប្រាចប្រាយ ធ្លាប់គិតការថ្វាយ
ព្រះបាទចក្រី។
444 ស្តេចផ្តាំដាក់ទុក ពាក្យពេជគ្រប់មុខ អាមាត្យមន្ត្រី
ទទួលបន្ទូល ឥស្សូរសិរិសី ស្ងួរេចសេចក្តី ជាខ្សែមួយហោង ៕

ចប់ខ្សែ១

445 បទបែប្រះប្រែចែងចង ពីខ្សែមួយហោង ភុជង្គលីលា។
446 ដំណាលកាលមហាក្សត្រា ត្រាស់ឲ្យអម្មារ
ចាកចេញចរត្រាច់។
447 ផ្ដែផ្តាំសុះសព្វសេចគ្រេច គ្រាន់គ្រប់ពាក្យពេចន
អស់ឥតសល់ការ។
448 អាមាត្រមន្ត្រីនោះណា ចងចាំចិន្តា គ្រាន់គ្រប់ពាក្យពេចន៍។
449 អាមាត្រក្រាបទាបស្តែងស្តេច បង្គំស្រោបស្រេច
ចរចុះចេញទៅ។
450 ដល់ស្ថានភិមានលំនៅ ផ្ដែផ្តាំកូនចៅ ញាតិផៅពង្សា។
451 ស្រេចចេញទៅទិសបូព៌ា កំឡិងអាត្មា ផ្សារជាអ្នកធំ។
452 ចេញទៅត្រូវខែត្តបាភ្នំ ព្រៃវែងត្បូងឃ្មុំ ទង្គំព្រៃជ្រៅ។
453 មន្ត្រីឃ្លាតឃ្លីចេញទៅ ទាល់ទីស្រុកក្រៅ នាំព្រះអាជ្ញា។
454 ទៅថ្លែងសម្ដែងសួរថា ហែអស់គ្រប់គ្នា ក្រែងនៅបានយល់។
455 កែរព្រាលនូវនរេនតុល ថាបើបានយល់ ចូលទៅប្រាប់ឆាប់។
456 បទខ្លាចព្រះរាជបង្គាប់ ត្រាស់ប្រើប្រញាប់ ឲ្យអញចេញមក។
457 ក្រែងគាត់ពួនពីទពីងជ្រក នៅណាឲ្យរក យកទៅថ្វាយឆាប់។



458 អស់អ្នកស្រុកក៏បានស្តាប់ ឆ្លើយវិញប្រញាប់
គ្មានទេលោកអាយ។
459 អាជ្ញាលេលាប្រញាយ ដើរទៅផ្លូវឆ្ងាយ ដល់ស្រុកស្រែកថា។
460 ហែអស់ស្រីប្រុសគ្រប់គ្នា បទព្រះអាជ្ញា ត្រាស់ប្រើឲ្យរក។
461 នែ៎ក្រែងនៅនេះ នៅវាំងមក[1] ឃើញមនុស្សចូលជ្រក
ពួនពីងនឹងនៅ។
462 អ្នកស្រុកស្ដាប់ហើយឆ្លើយទៅ ថាយើងខ្ញុំនៅ
អាយឥតមនុស្សថ្មី។
463 តែគ្នាយើងជាប្រក្រតី មិនមានមនុស្សថ្មី ចំឡែកគ្នាឡើយ។
464 អាជ្ញាថាលាព្រះហើយ បើគ្មានច្នោះហើយ និងប្រាប់មកថ្វី។
465 អាជ្ញាចូលសុំបាយស៊ី នៅស្បៀងចំណើ ហើយហួសម្នីម្នា។
466 ដល់ស្រុកមួយទៀតអាជ្ញា ស្រែចប្រាប់ទៅថា ទើយអស់អ្នកផង។
467 ចូលស្ដាប់អញប្រាប់ទៅហោង ចូរទៅរស់រ៉ង ព្រះបន្ទូលថ្លៃ។
468 អ្នកស្រុកខ្លាចអាជ្ញាក្រៃ ព្រួញប្រូបជើងដៃ ឱនក្រាបរាបទៅ។
469 អាជ្ញាឆ្លើយថានែនៅ អំបាលដែលនៅ
នេះក្រែងស្គាល់ផ្ទារ។
470 អាមាត្រព្រះបាទក្សត្រា ពីរនាក់នោះណា
ឈ្មោះកែរឈ្មោះតុល។
471 អ្នកស្រុកថាយើងមិនយល់ ឈ្មោះកែរឈ្មោះតុល
មិនយល់សូនសោះ។
472 អាជ្ញាថារលស់អស់ សួរទៅដូច្នោះ ដែលៗដូចគ្នា។
473 ច្នេះតើទៅនៅត្រង់ណា ព្រះហើយខ្ញុំលា
ខ្ញុំណើ្ហយណាយណាស់។
474 ទាល់តែព្រះបាទអង្គម្ចាស់ មានបន្ទូលត្រាស់ ប្រើលើសិរសា។
475 មន្ត្រីស្រដីពាក្យថា ដូច្នេះហើយណា អ្នកស្រុកចេញទៅ។
476 ដើរដល់មណ្ឌលព្រៃជ្រៅ កែរតុលគាត់នៅ
ទាបទៅស្រុកស្បៀង។
477 អាជ្ញាសួរទៅរៀងៗ ទៅទៀបស្រុកស្បៀង

[1] Ce vers comprend un pied supplémentaire. Dans la version imprimée *Rœang Roba khsat srok khmè*, on peut lire "ក្រែងចៅនោះនៅវៀងមក".

ឃើញនៅនោះហោង។

478 កែតុលចេញមកត្រសង ស្គាល់គ្នាស្រាប់ផង សួរសព្វសេចក្ដី។

479 រីឯអាមាត្យនោះខ្មី នានាំស្រដី កុំឲ្យអារម្ម។

480 បទមហាក្សត្រាឧត្តម គិតនិងអុងធំ សព្វគ្រប់អស់ហើយ។

481 អុងឯងលេងទោសជាត្រើយ ពុំយកទោសឡើប្រែ អស់រាស្ត្រស្រុកខ្មែរ។

482 គេគិតឲ្យយកទោសតែ តួរអង្គសិលៈកែរ កុំឲ្យយកផ្ដាស់។

483 អុងធំជុំនំថារាស្ត្រ ដូចស្មៅដើងក្រាស់ ទន់ទៅតាមខ្យល់។

484 ហេតុនោះពីគ្រោះថាពល ស្ដេចក្នុងមណ្ឌល ឲ្យលេងទោសចេញ។

485 កែតុលយល់អាមាត្រមិញ ប្រាយប្រាប់ឆ្មោះមិញ ចូលចិត្តជឿជាក់។

486 ត្រេកអរសាទរឈ្មោះស្មឹគ្រ មកទាំងពីរនាក់ និងអាមាត្រនោះ។

487 អាមាត្រសង្វាតប្លែកប្លេះ ចរចេញពីនោះ នាំកែតុលទៅ។

488 ដល់ស្ថានក្សត្រក្សាន្តចមចៅ ចូលក្រាបទូលទៅ ដោយនូវដំណើរ។

489 ព្រះមហាក្សត្រាប្រសើរ ជ្រាបដោយដំណើរ ស្ដេចអរឥតដល់។

490 ស្ដេចប្រើយកនរេនតុល កែព្រាលទៅដែរ ប្រគល់ឲ្យអុង។

491 យួនយល់ដល់តូចចិត្តចង់ ទើបឯងអស់អុង ប្រុងប្រៀបទទួល។

492 កែតុលយល់យួនស្រាកស្រួល ទឹកតែទទួល លាងឲ្យផឹកស៊ី។

493 ត្រេកអរសាទរទាំងពីរ ពុំដឹងជីវី ជីវិតក្សិនក្សៀយ។

494 យួនយល់កែតុលនោះនែ ពុំដឹងទោសពៃយ ក្សិនក្សៀយដូច្នេះ។

495 អុងគិតគំនិតពីគ្រោះ ប្រើអាជ្ញានេះ បំពោធកិច្ចកល។

496 ថាកែរនូវនរេនតុល អស់អុងយើងយល់ ថាចិត្តពិតត្រង់។

497 មានគេធំជ័យលើអង្គ ឲ្យចូលសិលេសង្ឃ ទៅតាមបង្គាប់។

498 មែនទេតុលកែរឯងប្រាប់ មកយើងនិងស្ដាប់ ដោយពាក្យពិតត្រង់។



499 នរេនតុលកែរព្រាលប្រុង ស្ដាប់ពាក្យអស់អុង ស្រដីដូច្នោះ។

500 ឆ្លើយទៅថាត្រូវចំពោះ ប្រសាសន៍អុងនោះ មែនមិនមុសា។

501 បទលោកសម្ដេចចៅពញា ទូនផរចៅហ្វារ គេថាឲ្យទៅ។

502 ខ្លួនជាទ័ពតូចដូចស្មៅ គេប្រើឲ្យទៅ ៗតាមបង្គាប់។

503 ឯអុងយួនប្រុងស្ដែងស្ដាប់ ថាអើឆ្មោះឆាប់ ទៅទល់ពាក្យគ្នា។

504 និងយកទោសតែចៅហ្វារ សម្ដេចចៅពញា អស់ឯងលេងចេញ។

505 គិតស្រេចអស់អុងនោះមិញ ឲ្យរាបទូកចេញ យកកែតុលទៅ។

506 លុះដល់មណ្ឌលទីក្រៅ ទន្លេចុះទៅ ទាបព្រៃនគរ។

507 អុងឲ្យហៅកែរតុលមក ដល់ហើយរេរ៉ គំនិតគិតថា។

508 ឥឡូវនិងទៅទល់គ្នា ខ្លួនគេនោះវា ពុំសមសេចក្ដី។

509 ធម្មតាខ្លួនជាមន្ត្រី និងតទល់ក្ដី ដោយច្បាប់យើងយួន។

510 បទឯងមានមន្ទិលខ្លួន និងចៅហ្វារទូន សម្ដេចចៅពញា។

511 និងទៅហៅអុងឲ្យជា ធ្វើក្ដីអាត្មា ទើបទៅហៅបាន។

512 ហើយឆ្លើយពាក្យពិតស្មោះស្មាន អុងជឿរចិត្តបាន ឲ្យដោះទោសចេញ។

513 នរេនតុលកែរព្រាលមិញ និងឆ្លាស់ឆ្លើយវិញ មិនហ៊ានស្ងៀមនៅ។

514 ទទួលទោសស្រេចទើបទៅ អុងតាគុននៅ ហៅពីចម្ងាយ។

515 អស់អុងដែលនៅពីអាយ ចូលទៅប្រញាយ ប្ដឹងដោយរាជការ។

516 តាគុនធំលន់នៅនា , ព្រៃនគរជា ថែមក្ដីវាទៀត។

517 ឃ្លាំងធំម្ជូនមាំបោះស្មៀត ដែកទាមថែមទៀត ប្រយ័ត្នបន្ថែ។

518 ហើយចាំនាំទៅស្រុកខ្មែរ ចងធ្លឹងបង្អែរ អាក្រាសហើយកាប់។

519 កុំឲ្យអស់ខ្មែររវាធ្លាប់ បបួលគ្នាកាប់ យួនស្លាប់ឥតការ។

520 យកទាំងសម្ដេចចៅពញា ទូនផរចៅហ្វារ នរេនតុលកែរ។

521 ព្រាលប្រាមគម្រាមស្រុកខ្មែរ កុំឲ្យធ្លាប់តែ គាចគិតក្បត់ស្ដេច។

522 អុងជាធំថាច្នេះស្រេច រករៀបរំពេច ឲ្យអុងតូចចេញ។

523 នាំអស់អ្នកទោសនោះមិញ មកឯភ្នំពេញ តាមអុងធំថា។

524 គិតចង់ជាប្រាំប្រការ បណ្ដើរដោយផ្សា ហើយកាប់រំពេច។
525 ព្រះមហាក្សត្រាស្ដេងស្ដេច ឲ្យប្រាប់ដូចម្ដេច គេពុំព្រមលេង។
526 ស្ដេចស្ដាយទ្រង់ព្រះកន្សែង សុំគេពុំលេង ឡើយលុះមរនា។

527 បទកាកគតិតែង ដំណើរដំណែង ដំណាលកាលគ្រា
ក្រោយអង្គឲ្យកាប់ សម្លាប់ចៅហ្វារ សម្ដេចចៅពញ្ញា
កែតូលនោះហោង។
528 ឯអង្គក្សត្រថ្លៃ ព្រះបាទឧទៃ រាជរិះគ្រប់គ្រង
រក្សាសីមា ប្រជារាស្ដ្រផង ជាសុកឥតហ្មង មន្ទិលទោសា។
529 ស្ដេចតាំងមន្ត្រី ចិញ្ចឹមជាថ្មី ជួសទូនមរនា
ចក្រីសួសឡើង គ្រងងារចៅហ្វារ ដែកជះលង់ជា ចក្រីវ៉ាងខ្ទី។
530 សោឃ្លោកជិតជា សម្ដេចចៅពញ្ញា ជួសសម្ដេចតី
តែងគិតរាជការ រក្សាបុរី ក្សត្រក្សាន្តធិបតី ឥតសូរសិរសោ។
531 និយាយឯអង្គ បាហោឈរក្នុង ក្រុងកម្ពុជា
ផ្ទាញខាងជើងវាំង ព្រះមហាក្សត្រា តែងតឿនរាជការ
លើក្សត្រភូធរ។
532 ដ្បិតអង្គតាគួន ជាធំមានបុណ្យ ផ្ទាញព្រៃនគរ
តែងចាត់បំរើ ប្រើឲ្យទៅមក ឯក្សត្រភូធរ បង្គាប់រាជការ។
533 កាត់ឈើក្ការហុប អស់ខែត្តផងគ្រប់ សឹងត្រូវដូចគ្នា
ឲ្យកាត់យកឈើ និងធ្វើរាជការ ថ្វាយស្ដេចទេព្ដា ដូចគ្នាទាំងអស់។
534 ឯមេកងការ កាត់ឈើនាម្ភ ឈ្មោះយោមរាជរស់
ឲ្យត្រូវកាត់ឈើ គគីទាំងអស់ ឯយោមរាជរស់
ចាំនៅហាន់ជ័យ។
535 ប្រើតែភ្នាក់ងារ ឲ្យឡើងត្រួតត្រា រាជការនោះនៃ
ឲ្យកាត់រំលំ ឈើធំក្នុងព្រៃ អូសដាក់ហាន់ជ័យ សព្វថ្ងៃឥតអើក។
536 កែនយកក្របី អូសឈើគគី ទាញទៅទុកដាក់
កំពង់ហាន់ជ័យ សព្វថ្ងៃឥតអើក ស្លាប់គ្រប់ដំណាក់

---

[1] Il faut lire ឡុង "Long".



នឿយណាស់ស្គមស្គាំង។
537 ស៊ីតែស្លឹកឈើ ផល្គុនចៃត្រដើរ ទឹកវ៉ែងរៅរាំង
រាងរាបចប់ផ្លូវ ឥតស្មៅគោកគាំង កង្វែរ ខែប្រាំង
ហែងស្ងួតហួតព្រៃ។
538 ក្របីស្លាប់អស់ ឲ្យអូសនិងមនុស្ស ទាញទៅសព្វថ្ងៃ
ដងដោយនូវនឹម ទាមទឹមទីទៃ ឲ្យអូសពីព្រៃ ពីផ្លូវដែលសល់។
539 ឯអង្គដោយកាយ កាន់ឈើវាត់វាយ ពីក្រោយរចល់
វាឡើងលើឈើ ហើយដើរមើលពល់ បើប្រឹងមិនដល់
មិនខ្លាត់ចំឡក។
540 ឲ្យកោងកំពិស ដូចគ្នាទាំងអស់ ទើបយួនវាយក
បើឯងមិនខំ វាយដំរបក ហើយស្រែកសំយក ជេរពោលដៀលថា។
541 ដំណើរដំណាល ដំណើរកេរ្តិ៍កាល កាប់ឈើរាជការ
កាលយួនវាប្រើ លើខ្មែរគ្រប់គ្នា គួរគិតអនិច្ចា អាត្មាទីទៃ។
542 ដំណើរឈើនេះ សុង្វែបទុកស្លេះ គ្រាន់តែដឹងន័យ
កាលយួនវាប្រើ អូសឈើហាន់ជ័យ ឲ្យក្មេងទីទៃ ដឹងដើមដូនតា។
543 និយាយឯអង្គ បាហោឈរក្នុង ក្រុងកម្ពុជា ស្ដេចគង់ភ្នំពេញ
ធ្វើផ្ទាញនៅនា ជើងវាំងព្រះមហា ក្សត្រាប្រធាន។
544 តែងទៀនរាជការ ព្រះមហាក្សត្រា ខ្ពបខ្លាចព្រួយប្រាណ
ទោះទាំងនាហ្មឺន ពង្សល្ហួងប៉ុន្មាន ឥតអ្នកណាហ៊ាន
ទទឹងទាស់ទេង។
545 តែលោកឈ្មោះម៉ា ដែលលោកធ្វើជា ព្រះអង្គ្រ នោះឯង
លោកមិនមានខ្លាច អំណាចយួនស្ដែង ព្រះអង្គម៉ាឯង
ប្រុងប្រៀបប្រញាប់។
546 ឯអង្គនោះណា តែងប្រើប្រាជ្ញា ដោយនូវសណ្ដាប់[2]
អង្គប្រើទាសា[3] ចុងងន់មកប្រាប់ ថាអង្គបង្គាប់
ស្បែកឬស្សីផ្ដៅ។

---

[1] Ce mot signifie "saison".
[2] Ce passage est omis dans l'édition imprimée *Rœang Roba khsat srok khmê*, vol. 1, p. 63.
[3] Du pali *dasa* qui veut dire "serviteur". Dans l'édition imprimée *Rœang Roba khsat srok khmê*, vol. 1, p. 63, le mot est noté ឞាសា.

547 នឹកឃើញស្មើណា អ្នងប្រើទាសា ថុងងន់[1]ឲ្យទៅ
បង្គាប់គ្រប់ការ ថាអ្នងឲ្យត្រូវ ឲ្យទានយកទៅ
ឥឡូវទាំងអស់។

548 ឯព្រះអង្គម៉ា តែងទុកចិត្តគ្នា រាជតេជះកាស់[2]
អ្នងគិតម្ដេចម្ដា ទោសាយកខុស រាជតេជះកាស
ខ្សិបខ្សបប្រាប់គ្នា។

549 ឯអស់ជុំនំ នៅអ្នងជាធំ សំរេចរាជការ ពុំដឹងគេគិត
គំនិតត្រូវគ្នា អ្នងគិតកិច្ចការ ម្ដេចៗដឹងដល់។

550 មានមួយថ្ងៃនោះ អ្នងឯងពីគ្រោះ និងអស់ពួកពល
ចង់ចាប់ព្រះអង្គ ឲ្យបានដោយកល ប្រាជ្ញាយោបល គំនិតអ្នងឯង។

551 ឲ្យជីករណ្ដៅ វង្វង់ជំរៅ ទ្រទ្រង់ដៃលែង ទទឹងពាហត្ថ
មាត់រណ្ដៅឯង យកក្ដារប្រវែង បន្ទុំត្បះទុក។

552 ហើយធ្វើរណ្ដៅ មួយទៀតទៀបនៅ ទីរោងនៅមុក
ជុំនំក្នុងថ្នាញ នោះមិញប្រុងទុក កន្ទេលគ្រប់មុខ កៅអីលើនោះ។

553 ទុកជាអម្រុង បង្ហូយព្រះអង្គ ម៉ាមកចំពោះ និងឲ្យឡើងទៅ
នៅកៅអីនោះ ឲ្យស្រុតធ្លាក់ចុះ ចាប់យកបានងាយ។

554 គិតស្រេចដូច្នេះ ប្រើថុងង្ហូននោះ ចេញទៅប្រញាប់
អញ្ជើញព្រះអង្គ ថាអ្នងឯនាយ ប្រើមកលោកអាយ
ឲ្យអញ្ជើញឆាប់។

555 ជុំនំរាជការ បទមានអាជ្ញា នាំប្រុតបង្អាន់ ពិតពីអ្នងធំ
ព្រែនគរប្រាប់ ឲ្យលោកទៅស្ដាប់ សំបុត្តអ្នងធំ។

556 ឯលោកព្រះអង្គ គិតហើយចូលក្នុង ផ្ទះហើយសំងំ
ផ្ដាំតែកូនក្អយ[3] ឲ្យថាលោកពុំ សូវជាសំងំ
ពុំដែលចេញក្រៅ។

557 បីប្អូនថ្ងៃហើយ ពុំដែលហៅស្បើយ ដល់តិចប្លេះនៅ
បើអស់កូនក្អយ ចូលជំរាបទៅ ខឹរខឹងហោហៅ
ដេញវាយសំពង។

[1] Mot vietnamien qui signifie "traducteur, interprète".
[2] Il faut lire កស់ [kàh].
[3] L'expression កូនក្អយ signifie "serviteur, client".



558 ឆ្ងួតគិតវិវក់ សព្វថ្ងៃមិនសុខ យកសម្បកខ្យង
ដោតជាចង្កោម ពាក់នៅកផង កូនក្អយសព្វដង
មិនហ៊ាននៅក្នុង។

559 ដូច្នេះអ្នកជា ថុងង្ហូនទាសា វិលទៅពិតអ្នង
ក្រែងគ្រាន់ស្រាកស្រាន បន្តិចបង្អង់ យើងចូលទៅក្នុង
ជំរាបលោកឲ្យ។

560 បំរើអ្នងទៅ ក្រោយនោះលោកហៅ អស់ទាំងកូនក្អយ
នៅអស់ព្រះពញា ប្រាប់ថាឯងឲ្យ ជ្រើសមនុស្សមួយរយ
ឲ្យទៅនិងអញ។

561 កាន់គ្រឿងគ្រប់ដៃ ដោយទូទីទៃ ប្រយ័ត្នដល់ថ្នាញ
បទអ្នងគេធ្វើ អំពើរនោះមិញ គេចង់ចាប់អញ
ក្នុងថ្នាញនោះជាក់។

562 ក្រោយនោះបន្តិច ពុំយូរឡើយលិច បំរើពីរអ្នក
មកជាអាជ្ញា ទៀនថាលោកភ្ញាក់ ឬនៅអស់អ្នក
ផ្ដឹងលោកឲ្យឆាប់។

563 បទអ្នងជាធំ លោកប្រើយើងខ្ញុំ មកជាប្រញាប់
ឲ្យអញ្ជើញទៅ ឥឡូវនោះឆាប់ កូនក្អយលោកប្រាប់
ថុងង្ហូនវិញថា។

564 កំពុងតែវក់ មិនបានស្វាងមុក កុំអាលេទាសា
តើងទៀនបង្គាប់ ប្រញាប់ពេកណា ចាំលោកស្វាងជា
ប្រលុបបន្តិច។

565 ទាសានោះនៅ អង្គុយពីក្រៅ តៀនទៅពុំភ្លេច
ថាអស់ជុំនំ គេទៅជុំស្រេច លោកតើគិតម្ដេច
អ្នងឲ្យតៀនឆាប់។

566 ទើបលោកព្រះអង្គ ចេញមកពីក្នុង ដល់ហើយបង្គាប់
កូនក្អយឲ្យថា និងទាសានោះ ថាចាំប្រដាប់ ខ្លួនស្រេចទើបទៅ។

567 ឲ្យអស់ទាសារ ជំរាបអ្នងថា លោកមកឥឡូវ ទើបអស់អាជ្ញា
បំបែកគ្នាទៅ ប្រើខ្លះឲ្យទៅ ពិតអ្នងដូចថា។

568 ទើបលោកព្រះអង្គ ឲ្យរៀបប្រៀបប្រុង ប្រដាប់ម្ចិម្ចា
ពិពន់ប្រលប់ សំឡប់មើលគ្នា មិនស្គាល់អាជ្ញា

តឿនទៀតលោកចេញ ។

569 ជាមួយបំរើ កូនក្មួយលោកដើរ ដង្ហែពាសពេញ
កាន់អស់គ្រឿងគ្រប់ ប្រដាប់ចរចេញ បំរើនោះមិញ
ជំរាបលោកថា ។

570 ម្តេចលោកគិតឲ្យ មនុស្សទៅតាមក្រោយ កាន់គ្រឿងសាស្ត្រា
គ្រប់ដៃរដូច្នេះ ច្រើនម្លេះគ្រៀបត្រា ក្រែងអ្នុងលោកថា
ចាប់ទោសចាប់ពៃរ្យ ។

571 និយាយតាមផ្លូវ តរាបរៀងទៅ ប្រដែងទីទៃ
លោកព្រះអង្គម៉ា ថាអ្នុងនោះនែ កាន់គ្រឿងគ្រប់ដៃ
យល់ជាមានការ ។

572 ទើបអង្គអញឯង ឲ្យគិតតាក់តែង កាន់គ្រឿងគ្រប់គ្នា
បើអ្នុងមានក្រ កម្រម្តេចម្ពា យកគ្រឿងពីណា
និងឲ្យជួយអ្នុង ។

573 និយាយតាមផ្លូវ ដរាបរៀងទៅ ទៀបដល់វំលុង
ចុងង្វនបាសារ ថាលោកនៅក្នុង ថ្នាញទៅហៅអ្នុង
ត្រង់ក្តនោះឯង ។

574 ឯលោកព្រះអង្គ ដឹងហើយបង្អង់ ដឹងដើមយល់ឆ្វេង
គេដឹករំលង់ បំផុងអង្គឯង លោកហៅមនុស្សតែង
ទុកចិត្តចូលទៅ ។

575 ហើយបង្គាប់ថា ឲ្យអស់ព្រះពញា កូនក្មួយចូលទៅ
ចាំទិមទ្វារថ្នាញ អង្គអញចូលទៅ ទាំងអស់ឲ្យនៅ
នៅតែពីរនាក់ ។

576 ផ្តាំស្រេចដូច្នេះ លោកលោតផ្លោតផ្លោះ
ហួសក្តារយួនដាក់ កូនក្មួយលោតតាម ទៅទាំងពីរនាក់
យួនយល់ឃើញដាក់ ចូលទៅដូច្នេះ ។

577 ឯយួនចាំទ្វារ អរវង់ម្នីម្នារ រួសរាំងទ្វារនោះ
ថាអ្នុងទន្ទឹង លោកបាត់ស្ងួនសោះ អញ្ជើញទៅចុះ
អ្នុងរុងចាំនៅ ។

578 ឯលោកព្រះអង្គ ចចូលដល់ក្នុង រោងជិតទៀបទៅ
អស់ទាំងទាសា ភ្នាក់ងាយួននៅ ថាឲ្យលោកទៅ



លើកៅអីនោះ ។

579 ឯលោកព្រះអង្គ ពុំទាន់ហៅអ្នុង ឲ្យអស់ពីពោះ
ដូចដោយសេណី មន្ត្រីទាំងនោះ ដល់ដាក់ខ្លួនចុះ
ប្រហោងស្ងៀមនៅ ។

580 អ្នុងឲ្យទាសារ ចុងង្វូននោះថា ឲ្យលោកឡើងទៅ
អង្គុយកៅអី ឲ្យធ្លាក់រណ្តៅ លោកដឹងមិនទៅ
ថាអណាស់ហើយ ។

581 ឯអ្នុងបាហោ តែងទៀនប្រាប់មក ញឹកៗជាត្រើយ រីឯព្រះអង្គ
ថាអ្នុងអរហើយ ពិតពុំឡើងឡើយ អង្គុយស្ងៀមនៅ ។

582 អ្នុងដឹងដូច្នេះ ប្រើទាសារនោះ មកប្រែប្រាប់ថា
ថាម្តេចព្រះអង្គ ដល់អ្នុងមិនហៅ ហើយកាន់គ្រឿងគ្រា
គ្រប់ដៃមកផង ។

583 ឯច្បាប់យើងយួន ឲ្យដង្ហែខ្លួន ចូលមកនេះឆ្លង
ហើយកាន់គ្រឿងគ្រប់ ប្រដាប់មកផង ប្រកួតប្រឡង
យកសក្តិអ្នកធំ ។

584 ឯព្រះអង្គម៉ា បានឆ្លើយវិញថា ខ្ញុំគិតអារម្ម
ប្រយ័តន្នរាជការ ជួយអ្នុងជាធំ ទើបឲ្យមនុស្សខ្ញុំ
កាន់គ្រឿងប្រដាប់ ។

585 ក្រែងអ្នុងមានក្រ ហើយបង្គាប់មក មានគ្រឿងគ្រប់ស្រាប់
ខ្ញុំគិតដូច្នេះ ហេតុនេះបង្គាប់ ឲ្យកាន់ប្រដាប់
គ្រឿងគ្រប់មកផង ។

586 កាលនោះឯអ្នុង ស្តាប់ពាក្យព្រះអង្គ ឆ្លាសឆ្លើយសារសង
អ្នុងអរសើចមក ចំអកឲ្យផង ក្អាកក្អាយសូរសង ទើបចុងង្វូនថា ។

587 អ្នុងស្រដីលេង និងព្រះអង្គឯង កុំអន់ចិន្តា ព្រះអង្គឮហើយ
ឆ្លាសឆ្លើយវិញថា ខ្ញុំអរហើយណា និងអ្នុងស្រាកស្រួល ។

588 កាលនោះឯអ្នុង ឲ្យគិតអម្រុង បាយទឹកទទួល
ទើបព្រះអង្គម៉ា ថាពោះមិនស្រួល មិនដែលទទួល
ទានច្រើនវេលា ។

589 បានតែម្តងៗ បើខ្ញុំរំលង កំណដ្ឋមិនថា កុំព្រួយអ្នុងឲ្យ
រកទៀបក្រយ៉ា ខ្ញុំអណាស់ណា និងចិតអ្នុងស្មោះ ។

590 អស់អ្នកទាសា ពិតអ្នងផងណា ចាខ្ញុំហើមពោះ កុំឲ្យរៀបថ្វី
ចំណីអស់នោះ ឲ្យតែពីគ្រោះ រាជការនឹងទៅ។

591 បទខ្ញុំមកឈ្មប ពីពុនព្រលប់ លុះអាគ្រាតជ្រៅ
អ្នងមិនឃើញថា រាជការស្ងៀមនៅ ខ្ញុំចង់លាទៅ
ឥឡូវនេះហើយ។

592 ឯអ្នងបាហោ ដឹងហើយខឹងម កុំអាលទៅឡើយ
ឯលោកព្រះអង្គ រង់នៅគិតហើយ អ្នងស្ងៀមព្រងើយ
លោកលាចេញទៅ។

593 ថុងង្វនបាសា តាមឃាត់រាំងរា ពីមុនមិននៅ ឯអស់ទាសា
ថាកុំអាលទៅ លោកពុំព្រមនៅ ចេញទៅក្រៅថ្នាញ។

594 ជួបនិងអស់មនុស្ស ព្រមគ្នាទាំងអស់ ទៅផ្ទះវិងវិញ
ប្រាប់អស់បរិពារ គ្នីគ្នានោះមិញ រៀបរូតស្រេចចេញ
ទៅបាត់ដំបង។

595 បទព្រហ្មគិតគាប់ ចចារចាប់ៗចែងចង
កាលក្រោយបន្តិចហោង រាជតេជះកសគិតការ។

596 គាត់គិតក្នុងចិន្តា ចង់បានជាងជាយោមរាជ
ហេតុការគិតមិនខ្លាច នៃយោមរាជហ៊ូវនោះឡើយ។

597 ប្រទូសប្រទាស់គ្នា តែពីងារនោះជាត្រើយ
ខឹខឹងពុំស្បើយឡើយ ហើយទៅទូលមហាក្សត្រា។

598 ឯអង្គមហាក្សត្រា ព្រួយព្រះទ័យក្របើថា
យោមរាជឥតទោសា និងហួតងារគេពុំខុស។

599 ទើបក្សត្រក្សាន្តឥសូរ មានបន្ទូលថាអាកស់
យោមរាជគេមិនខុស និងដម្លោះងារម្តេចបាន។

600 យល់ខុសនិងសណ្តាប់ ខុសទម្លាប់ពីបូរាណ
ចិញ្ចិមបុរាណស៊ីកបាន ទោសមិនមានហួតយកចេញ៕[1]

601 ដូច្នេះអាឯងយក ងារស្វូឃ្លោកនោះឯងវិញ
អញតាំងបន្ទូលចេញ ទៅពោធិសាត់នោះជាក្រែ។

[1] Cette strophe est omise dans la version imprimée *Ravang Roba khsat srok khmê*, vol. I, p. 71



602 រីឯរាជតេជះកស ចង់ឈ្នះតបទោសពៃយ
មិនបានដូចចិតមៃយ នឹយកំណើតកើតប៉ុនបង។

603 ពុំចូលចិត្តចិន្តា គឺមោះថាខ្លាចឆ្នាំឆ្នង
ពុំហ៊ានទូលទាស់ផង សងបន្ទូលមហាក្សត្រា។

604 ទទួលថ្វាយបង្គំ ក្សត្រឧត្តមដូចព្រះបារ ទ័យន័យមហាក្សត្រា
ធ្វើងារជាសូរឃ្លោកនោះ។

605 ទទួលបន្ទូលស្រេច រៀបរំពេចចេញស្មោះ
ទៅពោធិសាត់នោះ ទៅរក្សារាស្ត្រទាំងឡាយ។

606 កត់ត្រាបញ្ជីរាស្ត្រ ផងទាំងផ្លាស់ដែលជួញចាយ
ក្រវាញយកមកថ្វាយ ជាសួយសារមហាក្សត្រថ្លៃ។

607 ធ្វើងាជាសូឃ្លោក តែងនិងយកសួយសព្វថ្ងៃ
អស់រាស្ត្រផងភិតភ័យ ខ្លាចខ្លួនក្រែក្រាបរាបស្មោះ។

608 រីឯអង្គសូរឃ្លោក តែងនិងយករាស្ត្រទាំងនោះ
ប្រើប្រាស់ឥតមានមោះ មានមន្ទិលទោសទុក្ខា។

609 តែងនិងចរចេញចូល ក្រួញក្រាបទូលទាល់ក្សត្រា
ពុំដែលគេចវស្សា ជាគំរប់ឆ្នាំបីបួន។

610 កាលនោះឯអស់រាស្ត្រ ផងទាំងផ្លាស់ដែលជួបជួន
ថាញាត្តិថាសាច់ខ្លួន ពួនពិងបុនពីមុនមក។

611 ឃើញហើយអរឯងក្រែ ក្រាបលើកដៃសំពះយក
ហត្ថាប្រណម្យលោក យើងនឹងជ្រកពិងពុំបាន។

612 ធ្វើងារជាសូរឃ្លោក សុទ្ធតែសាច់សន្តាន
នៅអោយឥតសំរាន្ត គេប្រើបានឥតប្រណី។

613 ដរាបថ្លឹងស្មុះសព្វ ដំណើរគ្រប់អស់សេចក្តី
ដែលកើតហេតុអ្វីៗ ឲ្យប្រណីជួយគ្រប់មុក។

614 រីឯអង្គសូឃ្លោក ឃើញញាតិមកសារសុកទុក្ខ
ទៅជួយដោះគ្រប់មុខ មិនមានបានដូចចិន្តា។

615 ខឹងចិត្តបតអស់ញាតិ គេប្រមាតមិនយល់គ្នា
ទៅទូលមហាក្សត្រា សូមធ្វើងារឯក្នុងវិញ។

616 ឯអង្គមហាក្សត្រា ឮទូលថាដូច្នេះមិញ
មិនព្រមយកងារចេញ ប្រែវិលវិញត្រាតែបាន។

617 រីឯអង្គសូរឃ្លោក កសគិតយកសាច់សន្តាន
ដែលពីងបុណ្យប៉ុន្មាន ទៅទីស្ថានពោធិសត្វ។
618 បបួលដូចចិន្តា ប្រុងប្រាថ្នាហើយចែងចាត់
បំរើដើរកិតជាប់ ត្រូវពោធិសត្វទៅសៀមរស់។
619 ឯអង្គមហាក្សត្រា បានជ្រាបថាសូឃ្លោកកស
ចាត់ត្រូវយកទៅរស់ ស្តេចទ្រង់ខ្វាលញីរអស់អង្គ។
620 ស្តេចឲ្យអស់សេនា កែនមនុស្សមនាជាអម្រុង
ត្រាស់ប្រើចក្រីល្មុង លើកពលពុងកងទ័ពទៅ។
621 ឯពលមួយម៉ឺនប្លាយ កែនពីអាយគ្រប់ខែត្តក្រៅ
បញ្ជូនបញ្ចូលទៅ ទុកឈរនៅពោធិសាត់។
622 ឈររាំងរក្សាខេត្រ ឃើញកើតហេតុហើយប្រយ័ត្ន
ទិមព្រមពោធិសត្វ ក្រែងគេចាត់ត្រូវទៀតទៅ។
623 ចក្រីល្មុងជាធំ មេកងជុំឈរចាំនៅ
ពុំហ៊ានលើកទ័ពទៅ តាមត្រូវនៅស្រុកសៀមឡើយ។
624 ឈរយូរយល់ជាក់ចាំ ដល់ដើមឆ្នាំភ្លៀងណាស់ហើយ
មិនមានទ័ពសៀមឡើយ ហើយបន្ថយខ្មែរមកវិញ។
625 ស្តេចតាំងសូឃ្លោកទៅ ឲ្យឈរនៅខែត្តនោះមិញ
រាស្ត្ររតចូលមកវិញ បៀបនិងពេញពោធិសត្វ។
626 រីឯអង្គចក្រី នូវមន្ត្រីដែលចាត់ ចាំខែត្តពោធិសាត់
វិលវិញថ្វាត់ថ្វាយបង្គំ។
627 លុះយូរបន្តិចទៅ ស្តេចឲ្យហៅមន្ត្រីធំ
ទាំងអស់មកជុំនុំ និងជាន់ឥដ្ឋករកំផែង។
628 ជំនុំអស់ក្រមការ ចាត់ការងារទៅតាក់តែង
គិតកែនកំឡាំងឯង ករកំផែងឥដ្ឋថ្វាត់ថ្វាយ។
629 ឲ្យយកតាមបញ្ជី ពល់គ្រួបទីខេត្រទាំងឡាយ
បានប្រាំមួយម៉ឺនប្លាយ ដាក់មេនាយកាន់ជាន់ឥដ្ឋ។
630 រីឯអស់ជុំនុំ ផងតូចធំក៏រិះគិត កែនបាវបានមកជិត
ឲ្យជាន់ឥដ្ឋឯងនោះមិញ។
631 ជាន់បានដុតអិដ្ឋឆ្អិន ស្រេចគ្រប់គ្រាន់នាំចរចេញ
ឲ្យមេការក៏កំផែង។



632 នាហ្មឺនមានមុកងារ ជាមេការគិតតាក់តែង
ជាជាងករកំផែង ភ្នំពេញឯងពុំទាន់ស្រេច។
633 គាប់កាលកើតជាភេទ ភាភិនភេទនគរស្តេច
គ្រោះក្រជាសម្រេច ឲ្យអង្គស្តេចចាកចេញឆ្ងាយ។
634 ជាហេតុភេទក្រគ្រោះ ផ្ទៃក្រោមនោះនិងអន្តរាយ
ព្រះម្ចាស់ទេព្វក្លល់ខ្វាយ គិតឧបាយដោយប្រាជ្ញា។
635 ព្រោះហេតុចង់យង់យល់ ទីមណ្ឌលអាត្មា
យុលញាតិសាច់ពង្សា ព្រះអង្គម៉ាជាបងឯង។
636 ព្រះអង្គម៉ាទៅសៀមបាត់ ស្ងាត់ស្ងៀមទីចំបែង
រញ្ជកនិកយលឆ្វេង គិតតាក់តែងលបល្បចត្រា។
637 ប្រាសាទទាំង៥នោះ ហើយបានបោះនាំរាជសារ
ទៅក្នុងក្រុងមហា ទេពនគរជាសុខស្វស្តី។
638 ក្នុងរាជសារថា ពឹងសំភារបុណ្យបរមី បទយួនយក្សតិរថី
វាកំចោកភោគ្គវិវាទ។
639 សូមពលពុទ្ធិចៅ លើកទាព្យទៅជួយរិងថ្វាត់
ដេញយួនព្រួនព្រាយព្រាត់ បាក់បែកបាត់ពីនគរ។
640 ព្រះចៅយុទ្ធារបាន ជ្រាបដើមដានដោយអក្សរ
ទើបស្តេចទ្រង់ត្រេកអរ ឲ្យជំនុំជុំពលផង។
641 ត្រាស់ប្រើលោកចៅយុន ធំលើសលុនជាមេកង
ល្វងពីព្រះអង្គផង ជាមេកងចុះដើងទឹក។
642 រីឯលោកចៅយុន ធំលើសលន់ជាស្តេចសឹក
ដើងគោកពលពន្លឹក លើកកកើកពោធិសាត្វវិញ។
643 ដើងទឹកពញាក្លាហោម[1] ធំចេញព្រមពលពាសពេង
ដើរផ្លូវកំពតវិញ មានសំពៅកប៉ាលផង។
644 ដំណើរដំណែងកាព្វ គិតរៀងរៀបរាប់មេកង
ខាងសៀមស្លេះសិនហោង ចាប់ចែងចងខាងខ្មែរវិញ។
645 និទានក្សត្រតែឯអង្គ ក្សត្រដែលគង់ទីភ្នំពេញ
ជាម្ចាស់ខ្មែរនោះមិញ មិនមានជ្រាបក្នុងកាយា។

---

[1] Il faut lire ពញាក្រឡាហោម [poñéa krâlahaom], chef de l'armée fluviale ou la marine.

646 ថាអង្គអគ្គមហេសី តែងសេចក្ដីផងទាំងឆ្ងាយ
ទៅយោងសៀមពីនាយ ឲ្យមកជួយអង្គដូច្នេះ ។

647 បទកាកគិត ដំណើរដំណរ ដំណាលកាលនោះ ជាកាលភ្នាំខ្មែរ
ឲ្យតែក្រគ្រោះ នគរកាលនោះ ពុំសូវសុកសាន្ត ។

648 គាប់កាលឆ្នាំម្សាញ់ សករាជនោះមិញ កន្លងទៅបាន
២៣០០ចិតសិប៥[1] ហេតុកាលក្នុងស្ថាន នគរពុំសុក ។

649 ឆ្នាំម្សាញ់បញ្ចស័ក សៀមមកគគឹក គគិកគគុកពាស
ពេញភូមិស្ថាន គិមានស្រែស្រុក រាស្ត្រវេងអុកលុក
ពុំសុខសប្បាយ ។

650 ផ្អើលភ្ញាក់ទីទៃ ភ័នភាំងភិតភ័យ ញ័ររអស់អង្គកាយ
ពីស្រុកស្រែក្រៅ រៀងទៅបន្ទាយ រំជួលសព្វសាយ
ផុតផែនពសុធារ ។

651 មេកងគេនោះ ដោយន័យនាមឈ្មោះ ហៅពញារាជ្ជា
មួយទៀតចសែន នរេនយោធារ មួយនោះឈ្មោះពញា
លុក្ខានសុវាន់ ។

652 អណ្ដាប់មេពី ព្រះពិទូវិធី ជាមេកងពាន់ បាឡាត់ចុងកាល
រៀងរាល់ប្រកាន់ ត្រួតលើកកំណាន់ នាយរយដោយប៉ែក ។

653 មានមេកងខ្មែរ ក្រុមមឿងសឹងតែ ធំឡងឯងឯក
ដោយឆ្វេងដោយស្ដាំ ប្រចាំដោយបែ្បក តាមងារតាមប៉ែក
ក្រុមមឿងនោះន័យ ។

654 និងរាប់រាយឈ្មោះ ឧបមាជំពោះ តាមងារទីទៃ
ពុំសូវស្គាល់ជាក់ តាមអ្នកនេះនៃ ងារច្រើនពេកក្រៃ
ពលច្រើនម៉ឺនឮយ ។

655 យុនរាតជាធំ មេកងផងជុំ ជុំនំជាពាក្យ សំរេចបែកផ្លូវ
ត្រូវកំពុងស្វាយ ចាត់មេចាត់នាយ មេកងស្រួចមុក ។

656 ឧកញ្ញានគរ ដែរដោមឿងម៉រ ម៉ានពលគគុក
បាឡាត់ឯកផង ខ្មែរជងចុងស្រុក ជាទ័ពស្រួចមុក
គគុកច្រើនក្រៃ ។

[1] Il faut corriger en deux mille trois cent soixante dix-sept pour avoir l'année du Serpent cinquième de la décade



657 ជីវិតសង្គ្រាម ក្ដួយពារិចិនចាម ខ្មែរលាវងាង
សៀងពួងផងព្រៅ តាងូវពុតនៃ ក្នុនជ្រាយច្រើនក្រៃ
លាវលាយរដ្ដែ ។

658 សង្កះគូវខាន សូរិនចូលជាន់ ដល់ព្រំស្រុកខ្មែរ
ទៅឡើងចង្រ្កែង ភិតឯងខ្លាចគេ រត់ចូលមកឯ ដេរជោប៉ោឆាប់ ។

659 ដល់ហើយជំរាប ពិតហើយសូភាព ពិតពីកងទាំព
គេនៅបោះដឹង ដំណឹងសាសព្វ ពុំបានទូលទាស់
រត់ចូលភ្នំពេញ ។

660 ចូលទូលទាល់ស្ដេច ដឹងដើមសេចក្រេច ដំណើរនោះមិញ
ត្រាយឲ្យឧកញ្ញា យោមរាជដូងចេញ នារិន្ទនងមិញ
ស្រីអគ្គរាជភោគ ។

661 នាម៉ឺនលាចេញ ពិតពីភ្នំពេញ មកគិតកែនយក
មនុស្សខែត្តបារាយ ប្រញាប់រិះរក តាំងទ័ពលើកមក
ទៅទុលនឹងគេ ។

662 ឯលោកឧកញ្ញា លុងសេន្នាងញ៉ា រូតចោលខែត្តទេ
ពុំហានទល់ទ័ព ប្រញាប់រិះរក រត់តែខ្លួនទេ ទៅឯបន្ទាយ ។

663 បានឯឧកញ្ញា ដូងសេន្នាងញ៉ា គ្រងងារនោះអាយ
បាឡាត់សូរផង គ្រប់ខែត្តបារាយ សូរនោះនៅអាយ
ហៅសូរក្រអេះ ។

www.ameKhmer.org

664 ជួបនិងយោមរាជ គិតគប់ពុំខ្លាច ធ្វេធ្វេសប្រហែស
អាងឧកញ្ញាសូរ ស្ដីធូក្រអេះ លោកកុំប្រហែស ទៅទល់ទ័ពគេ ។

665 កាលនោះយមរាជ មេកងឯងអាច លើកចេញទៅឯ
ត្រពាំងមាន់យំ ជួបជុំនិងគេ មេកងឯងឯង
អោយរាស្ត្របាក់បែក ។

666 ពលបិប្អូនរយ ដើងរើងដោយរោយ ហៅហានចំឡែក
ពលគេលុបលុន ពេកពុនអាណែក គេឃើញគេស្រែក
ប្រាប់មកមិនក្រែង ។

667 ថាទើយអស់គ្នា ច្បាំងនិងនណា នោះហើយម្ចាស់ឯង
លោកមកសោយរាជ គួរខ្លាចកោតក្រែង ច្បាំងនិងម្ចាស់ឯង
ដូច្នេះមិនសម ។

668 ពលតិចជើងរើង ហ៊ានបាញ់កាំភ្លើង ទៅគេៗពុំ
គិតខ្លាចអង្គឯង លេងភ្លេងរងំ បាំងក្លស្សលំយម ចូលមកមិនខ្លាច។
669 អេកងមិនយល គេស្ដីឲ្យឆ្ងល់ ថាម្ចាស់ឯងអាច
ស្ដេចមកប្រាថ្នា រក្សាសោយរាជ្យ គួនគិតកោតខ្លាច
មូរទូងជ័យចុះ។
670 ចងគ្រឿងសាស្ត្រា កាំភ្លើងធ្នូស្នា លំពែងដាវនោះ
ចូលថ្វាបេបង្គំ ប្រណមសុំចុះ ឲ្យប្រោសទោសនោះ និងនៅជាខ្ញុំ។
671 គេបញ្ឆោតឯង ប្រាថ្នាពុំឆ្វេង ខ្លះភ័យស្រែកយំ
ទ្រហឹងអឹងកង រំពងរងំ នៅវាលមាន់យំ មិនគិតគេខ្មាស់។
672 មេកងចូលគេ គេឲ្យអស់មេ គិតកែនរស់រាស្ត្រ ពីកំពុងស្វាយ
បារាយហើយល្ហាស រទេះអស់រាស្ត្រ ឲ្យដឹកជូនគេ។
673 ចូលជាន់ជើងព្រែក កំពុងសៀមនៃ ដល់មាត់ទន្លេ
ពលរេរតញ្ញាត សង្វាតទ្រព្យគេ ត្រើយអាយទន្លេ
អស់ឥតមានប្រុង។
674 ស្រេចហើយអស់មេ បំបែកពលរេ ដំរីសេះផង
ចែកទៅពីរផ្លូវ និងទៅគិតឆ្លង ខ្លះពាមជីកង ខ្លះឆ្លងត្លុកជ្រៅ។
675 ឆ្លងអស់គ្រប់គ្នា មេកងធំជា ឲ្យលើកចេញទៅ
ដល់ព្រែកទ្រមាក់[1] សម្រាកនិតនៅ ពលផងចេញទៅ
រាតត្បាតអ្នកស្រុក។
676 ពពាលពេញពាស់ កំចោករោគរាស្ត្រ រំដួលទៅទុក
ឯអស់កងទ័ព បង្គាប់អ្នកស្រុក ចាប់ទោសទាន់ទុក
ថាខុសរវើទ្រព្យ។
677 កងទ័ពទាំងឡាយ តែងធ្វើឧបាយ កលគិតបង្គាប់
ចាប់ទោសអ្នកស្រុក ឲ្យឆុកបង់ទ្រព្យ ហួលព្រែកប្រដាប់
មាសប្រាក់រងំ។
678 តែងដើរយកទ្រព្យ នោះអស់កងទ័ព ទោះតូចទោះធំ
ដរាបរៀងទៅ តាមផ្លូវសន្ធំ លុះដល់បាភ្នំ រងំគ្រប់ស្រុក។
679 មានកាលកងទ័ព ទៅតឹងបង្គាប់ ធ្វើទោសទានទុក្ខ
មានការេគ្នាឯង តែងនិងឃើញមុក ផ្ដែមផ្ដួមធ្វើទុក្ខ

[1] Il s'agit de l'actuel village de Prêk Trômeak.



ធ្វើទោសបានភ័យ។
680 កោរក្បាលជាសៀម ចូលទៅនៅសៀម ហាក់អ្នកដទៃ
មិនហ៊ានស្ដីខ្មែរ ថាតែអារ៉ៃ តឹងតែងឲ្យភ័យ
បង់ទ្រព្យគ្រប់ស្រុក។
681 អស់រាស្ត្រទាំងឡាយ កើតក្ដៅក្រហាយ រំជួលជាទុក្ខ
ទាស់តែខ្លាចបុណ្យ គេជាន់ចាប់ស្រុក ខឹងចិត្តជាអ្នក
ស្ទើរទប់ពុំបាន។
682 និយាយកងទ័ព ផ្លូវនេះឲ្យស្ដាប់ ដឹងដោយដើមដាន
តិចៗប៉ុណ្ណេះ និងស្លេះឈ្មុបខាន ទើបទៅនិទាន
ផ្លូវពោធិសត្វវិញ។

683 បទពុំនោលនៅចែងចេញ មេកងធំមិញ បឌិនដែជះជាញជ័យ។
684 ខ្មែរហៅចៅយុនភូយៃ សៀមលាវច្រើនក្រៃ
គ្រប់ម៉ឺនទីទៃក្លបខ្លាច។
685 ជាទ័ពកូននៅឯងអាច ឲ្យនគររាជ ជាទ័ពមុកមានដេស្ដា។
686 ដំរីធំៗឱទា ច្រើនក្រៃមហិមា ជាទ័ពស្រួចស្រេចមកមុន។
687 នាហ្មឺនខ្មែរមួយធំលន់ ចូលទៅពិងបុណ្យ
ព្រះឫទ្ធិចៅជាម្ចាស់។
688 នាមឈ្មោះសួរឃ្លោកកស្ប[1] ជាមុកបង្ហស់
ជាអ្នកនាំផ្លូវត្រូវត្រង់។
689 និយាយល្បងពីព្រះអង្គ ទ័ពទីកស្ដេចគង់ ទីនាំងអង្គអឹមអង្គដួង។
690 អង្កែត្បែសបានហែរល្បង មន្ត្រីទាំងពួង
ហែរល្បងពាសពេញទន្លេ។
691 ព្រះអង្គម៉ាមុកមុនគេ ដើរតាមទន្លេ មកដល់កំពង់ឆ្នាំងស្មោះ។
692 អស់រាស្ត្រភ្ញាក់ផ្អើលកាលនោះ ឃើញទ័ពច្រើនប្រុះ
ភិតភ័យរន្ធត់តកមា។
693 មេកងទ័ពស្រួចស្រែកថា អស់រាស្ត្រប្រជា កុំឲ្យភ្ញាក់ផ្អើលទីទៃ។
694 ល្បងម្ចាស់ស្ដេចមកនេះនៃ ជាទេកុំភ័យ

[1] Il manque un pied dans ce vers.

ស្ដេចមកសោយរាជរក្សា ។
695 អាសូរអស់រាស្ត្រប្រជា ឲ្យប្រាមប្រាប់គ្នា
កុំឲ្យភ្ញាក់ផ្អើលភិតភ្ញារ ។
696 ឯមេគយកំពង់ឆ្នាំង រូតរត់ស្លេកស្លាំង រលារលាំងចៅរៅ ។
697 ចូលដល់ភ្នំពេញឡើងទៅ ទូលស្ដេចដោយនូវ
ដំណើរដើមដូចបានយល់ ។
698 ស្ដេចស្ដាប់សារសព្ទឥតឆ្ងល់ ព្រួយព្រះទ័យសល់
ឲ្យហៅពួកពលយោធារ ។
699 មន្ត្រីសេណីសេនា មកមិត្រៀបត្រា
ចៅហ្វាវក្រហោមយោមរាជ ។
700 ចៅហ្វាវសួសសោតងងអាច គុណគិតការរាជ
ភូមិភពមណ្ឌលផ្ទៃក្រោម ។
701 បង្គាប់ចក្រីក្រហោម យោមរាជវាំងព្រហ្ម
ឲ្យតាំងទ័ពលើកចេញទៅ ។
702 ចក្រីល្វង[1] ទាំងវាំងម៉ៅ ឲ្យលើកទ័ពទៅ
ជើងគោកកែនយករាស្ត្រផង ។
703 ដរាបរៀងទៅជាម្ដង អស់ឥតមានហ្មង
ទៅទល់តទ័ពចៅយួន ។
704 សូរឃ្លោកកស្បកាត់ទៅមុន មុកលោកចៅយួន
នគររាជមុនបន្ទាប់ ។
705 ដីរសេះសិងឃ្មើងខ្ជាប់ ពលពាលសស្រាត់
ជាទ័ពស្រួចស្រាលសង្វាង ។
706 ចក្រីល្វងវាំងនិងងោង[2] យល់ពលគេជាង
គេរោមចាក់ពទពីមុក ។
707 ពិតពុំហ៊ានខំសម្រុក ពលគេគគុក
បែមុកមករក្រោយរហើង ។
708 ប្រើខាវទៅទូលម្ចាស់យើង ទ័ពនោះចចើង
និងចូលជល់យល់មិនបាន ។

[1] Il faut lire Long au lieu de Lung.
[2] Il s'agit probablement du Veang Prum



709 ស្ដេចស្ដាប់អាមាត្រទូលថ្កាន ព្រះទ័យពុំក្សាន្ត
ឲ្យរៀបទីនាំងថ្មីម្នា ។
710 ថ្លែងឯសម្ដេចចៅហ្វា ប្រើលោកឧកញ៉ា
ក្រឡាហោមគីងឯងចេញ ។
711 យោមរាជហូវពីនោះវិញ តាំងទ័ពទឹកចេញ
ដំណើរទ័ពគោកព្រមគ្នា ។
712 ទៅទល់យល់ពលត្រៀបត្រា ទ័ពព្រះអង្គម៉ា
មកមិរដេរដាស់ទន្លេ ។
713 ពលឯងយល់តិចលើសគេ ពុំហ៊ានទល់ទេ
ចំងាយដប់ស្រែចាញ់ថយ ។
714 ហើយប្រើបំរើមកក្រោយ ទូលស្ដេចដូចដោយ
ដំណើរមុនមានមកស្រាប់ ។
715 ព្រះបាទឧទ័យស្ដេចស្ដាប់ អាមាត្រទូលប្រាប់
ថាទ័ពនោះខ្លាំងមហិមារ ។
716 ស្ដេចទ្រង់សង្វេកអនិច្ចារ រៀបអង្គម្ចីម្ចារ
នាំម្ចាស់ក្រាបទាបចរចេញ ។
717 នាំបុត្របីអង្គមិញ ចុះចែវចរចេញ
ត្រង់ត្រូវទៅយួនស្មោះស្មាន ។
718 ឯអស់នាម៉ឺនគ្រប់ប្រាណ ធំតូចប៉ុន្មាន
សឹងចេញចែវតាមជាក្រោយ ។
719 ខ្លះតាមស្ដេចទៅបន្ទប់ ខ្លះចេញជាក្រោយ
បែកដោយស្រុកទេសទីទៃ ។
720 ឯទ័ពសៀមមកនោះនៃ រាស្ត្រផ្អើលភិតភ័យ
គេប្រាមគេហាមខានវិញ ។
721 ល្ងងស្ដេចពីរព្រះអង្គមិញ ចូលមកភ្នំពេញ
ឡើងគង់ដំណាក់និតនៅ ។
722 ទើបទ័ពជើងគោកដល់ទៅ ចៅយួននោះនៅ
ហៅទូលព្រះស្រីស្រេចស្រាប់ ។

723 និយាយថែងចាយងទ័ព   ក្រឡាហោមនាប់[1]
ដើងទឹកកំពតមកដល់។
724 វាយទ័ពយួននៅកោះត្រល់   ច្បាំងបីថ្ងៃយល់
យួនទប់ពុំបានបែកបាក់។
725 រត់ចេញទៅនៅសំណាក់   ចូលចតពឹងពាក់
បន្ទាយថ្នាញកោះក្របី។
726 សៀមបាញ់ថ្នាញយួននោះខ្ទី   ថ្នាញកោះក្របី
និងទ្រាំពុំបានកាលនោះ។
727 បែកបាក់ខ្វាត់ខ្វាយធ្លាយធ្លុះ   រត់ចេញពីនោះ
ទៅពឹងសំណាក់ភ្នំស្វាម។
728 ទ័ពញាក្រឡាហោមតាម   ទៅដល់ភ្នំស្វាម
ភ្នំនោះនៅក្នុងខែត្តទ្រាំង។
729 ឯអ្នងដែលនៅតតាំង   ក្រឡាហោមច្បាំង
អ្នងនោះឈ្មោះអ្នងញ្ញាញប៊ុញ។
730 ច្បាំងបានប្រាំថ្ងៃមិនចេញ   ក្រឡាហោមមិញ
ឲ្យបាញនិងគ្រាប់ច្រវាក់។
731 ត្រូវដាច់កណ្ដាលខ្លួនធ្លាក់   ពីក្បាលហើយដាក់
យួនយល់និងនៅមិនបាន។
732 រតចេញចុះចាកទីស្ថាន   ភ្នំនោះស្មោះស្មាន
បានដល់ទៅព្រៃនគរ។
733 អស់ត្រូវយួនខ្មែររិះវរ   ភិតខ្លាចភ័យម
ទៅព្រៃនគរពឹងពាក់។
734 ឯអ្នងមាត់ជ្រូកធ្មើលភ្ញាក់   ខ្លាចគ្រាប់ច្រវាក់
ដាច់ពាក់កណ្ដាលខ្លួនច្នេះ។
735 ពុំបានតតាំងច្បាំងសោះ   សឹងតែរត់ចុះ
ទៅនៅពឹងព្រៃនគរ។
736 ទោះទាំងត្រូវនៅល្វងហោរ   ផ្សារដែកធ្មើលនោរ
រជៅរដើបចុះទៅ។

[1] Dans la version imprimée *Rœang Roba khsat srok khmè*, vol. II, p. 85, le nom du Krâlahaom est ឆាប់ [chhap].



737 ឯពញាក្រឡាហោមនៅ   កងទ័ពដែលទៅ
ទោះនៅមាត់ជ្រូកនោះនិង
738 ប្រើឲ្យបំរើរីលរឹង  បកសំបុត្រនិង   បំរើមកដល់ភ្នំពេញ។
739 ឲ្យល្វងលោកចៅយុ់នវិញ ,  លើកកងទ័ពចេញ
ភ្នំពេញទៅជួបជុំគ្នា។
740 នៅពាមមាត់ជ្រូកធ្វើការ   កុំឲ្យយួនវា   រិះរើគំនិតគិតវិញ។
741 ឯល្វងលោកចៅយុនវិញ   លើកកងទ័ពចេញ
ចាកពីភ្នំពេញប្រញាប់។
742 បានដល់មាត់ជ្រូកនោះទ័ព   ពលពាលអឹងអាប់
ទាំងទ័ពទឹកគោកជុំវិញ។
743 និយាយទៅឯអ្នងថាញ  វិញេ[1]នោះវិញ  ផវេទៅអ្នងតូចធំ។
744 សឹងតែគុណគិតជុំនំ   និងគ្នាជួបជុំ
ថាស្រុកយើងកើតអន្ទករ។
745 ព្រោះតែស្ដេចខ្មែររតម   សៀមតាមរិកវរ
និងខូចនគរពុំលេង។
746 បើច្នេះយើងគិតតាក់តែង   ចាប់ស្ដេចនេះឯង
ឲ្យគេទើបគេវិលវិញ។
747 ល្វងស្ដេចជ្រាបដូច្នេះមិញ  ទៅឯអ្នងថាញ
វិញេហើយប្រាប់ទៅថា។
748 ឲ្យជួយឈើឆ្អាលកាលគ្រា   នេះដេញសេនា
អាសារសៀមចេញវិញបាន។
749 និងបើកស្រុកខ្មែរប៉ុន្មាន   ឲ្យអ្នងរិះធ្យាន
តាក់តែងតាមចិត្តគិតម្ដេច។
750 អ្នងបាញវិញេស្ដាប់ស្ដេច  ដឹងដូច្នេះស្រេច  ក៏ព្រមចូលចិត្តចិន្តា។
751 ហើយអ្នងបាញវិញេថា  បើច្នេះក្សត្រា  ធ្វើព្រះបន្ទូលឲ្យឆាប់។
752 ឲ្យអស់វាស្ដេបាស់គិតកាប់   ពួកពលកងទ័ព
សៀមឆាប់កុំឲ្យនៅឡើយ។
753 ស្ដេចស្ដាប់ដឹងដូច្នេះហើយ   ពិតពុំយូរឡើយ

[1] Dans la version imprimée *Rœang Roba khsat srok khmè*, vol. II, p. 87, le général s'appelle Thanh Vigni.

ហើយតែងបន្ទូលប្រើចេញ ។
754 ព្រាមប្រាប់អស់រាស្ត្រនោះមិញ គ្រប់ខែត្តឲ្យដេញ
កងទ័ពទឹកគោកទាំងឆ្ងាយ ។
755 ស្រេចហើយអុងឲ្យរៀបហាយ ពលរៀបប្រញាយ
ប្រញាប់គ្រាប់រំសេវផង ។
756 ហាយធំចំបាំងប្អូនហង កាំភ្លើងធំផង ប្រាំបីដាក់ក្បាលកន្សែ ។
757 កាំភ្លើងបន្ទាប់ច្រើនក្រៃ ទាំងកាំភ្លើងដែរ
ដាក់ទូកទីទៃពាស់ពេញ ។
758 បាហោគ្រាប់បែកនោះមិញ គ្រប់គ្រឿងហើយចេញ
កងទ័ពពីព្រៃនគរ ។
759 និយាយឯទ័ពសៀមមក៍ រៀបទូលវិះវរ ចុះមកប្រញាប់ម្ដីម្នា ។
760 ទៅដល់ទន្លេវាលប្រា ប្រទះទ័ពគ្នា ក៏បាញ់ទៅមកស្មើដែរ ។
761 អុងថាញវិញ្ញោនោះនៃ ប្រាជ្ញារៀងវ័យ
អធ្យាស្រ័យយល់កលសឹក ។
762 មើលយល់ពលសៀមពន្លឹក ទាំងគោកទាំងទឹក
សន្ធាប់សន្ធឹកលោបលន់ ។
763 គ្រឿងគ្រប់ប្រដាប់ពេកពន់ យល់យើងនិងធន់
ទល់ទុបតតាំងមិនបាន ។
764 បើច្នេះរិះគិតប្រាសប្រាណ ថយរកទីស្ថាន
និងបានបញ្ឆោតវាវិញ ។
765 គិតស្រេចពុំយូរអុងថាញ វិញ្ញោឲ្យបាញ់
កាំភ្លើងថយទ័ពនោះឯង ។
766 រត់ចូលក្នុងថ្នាញកោះទេន ទ័ពសៀមពុំលេង
សំរុកកន្លក់ដល់ដេញ ។
767 លើកពទបន្ទាយជុំវិញ រីឯអុងថាញ
វិញ្ញោក៏ប្រុងប្រៀបប្រាណេ ។
768 សំងំស្ងាត់មាត់មិនមាន ឲ្យដឹងដើមដាន ដំណើរគំនិតស្ងុខុម ។
769 ឯទ័ពសៀមសឹងចោមជុំ យល់យួនសំងំ
ដូច្នេះក៏អរឯងក្រៃ ។
770 ចូលកោះចំរូងទីទៃ ខ្លះយកឈើព្រៃ



ចុកញាត់មាត់កាំភ្លើងនោះ ។
771 ខ្លះកើបយកដីច្រកចុះ គ្រប់កាំភ្លើងនោះ
សស្ទុកបុកស្អិនណែនក្រៃ ។
772 ខ្លះពានបន្ទាយទីទៃ យួនយល់ហើយន័យ
ក៏ចោលបាហោគ្រាប់បែក ។
773 ត្រូវពលសៀមស្លាប់អានេក មេកងទ័ពស្រេក
ឲ្យចូលចោមជិតភ្លើងវិញ ។
774 រីឯគំនិតអុងថាញ វិញ្ញោនោះមិញ
ឲ្យទូងភេរីបីបទ ។
775 ពលឆ្លើយយះហះប្រាកដ ព្រមគ្នាបីបទ
ក៏បាញ់កាំភ្លើងទាំងគ្រប ។
776 ចេញមកត្រូវពលសៀមសព្វ ក្រៅបន្ទាយគ្រប់
ក៏ស្លាប់វិនាសក្រាសក្រៃ ។
777 ខ្លះរស់[1] ភ័នភាំងភិតភ័យ បាក់ទ័ពនោះនៃ
និងនៅមិនបានរួតរត់ ។
778 ទាំងពលទាំងនាយរន្ធត់ ចោលអស់សំពត់
គ្រឿងគ្រប់ប្រដាប់គ្រឿបគ្រា ។
779 យួនយល់ពលសៀមមរណា អាងឯមហិមា
ក៏លើកទ័ពតាមដោយក្រោយ ។
780 ស្លែះទុកនៅនេះក្បិនដោយ ដំណើរឯក្រោយ
សិមសារស្រដីវិលវិញ ។
781 និយាយកាលទ័ពសៀមចាញ់ សូរឃ្លោកកស្បមិញ
លាលោកចៅយុនចេញទៅ ។
782 ចាត់គ្រូរសាច់ញាតិដែលនៅ នាភូមិឈ្មោះហៅ
ភូមិរាម្សអន្លើកនោះមិញ ។
783 នាំយកមកឯភ្នំពេញ ក្រោយនោះទៀតវិញ
ព្រះអង្គម៉ាលាចៅយុន ។
784 ស្រូតរូតលើកមកជាមុន បទលោកចៅយុន

[1] Il faut lire រត់ "courir" au lieu de រស់ "vivre"

ប្រើរើកំផែងភ្នំពេញ ។
785 ឯពញាក្រឡាហោមមិញ លាចៅឃុនចេញ
ទៅផ្លូវកំពតនោះនៃ ។
786 ទើបលោកចៅឃុនភូយ៉ៀ បែកចេញទីទៃ
ទៅនៅភ្នំពេញ ។
787 ឲ្យរើសអស់ឥដ្ឋកំផែង ចោលចេញឥតក្រែង
ឥតមានញញើតកោតខ្លាច ។
788 ឯទ័ពញួនគរាជ ឥតភ្លឹកឥតខ្លាច
ឥតភ័យឥតភិតអារម្ម ។
789 មានដំរីសេះធំៗ លេងភ្លេងរងំ
ពលជុំចោមជិតត្រៀបត្រា ។
790 ដើរទៅត្រូវពើបពានពារ លើទ័ពឧកញា
ស៊ុកពលមួយពាន់ប្រាំរយ ។
791 គាត់បានតតាំងច្បាំងឲ្យ បាញ់គេដេញដោយ
ទៅពានលើគ្រួរដែលពួន ។
792 គ្រួរច្រើនជុំខេត្តទាំងបួន គេចាប់សំនួន
បានគ្រួរនោះជាងពាន់ប្លាយ ។
793 គេកាប់សម្លាប់ចងវាយ ប្រុសៗពុំស្តាយ
ទុកតែស្រីៗរញ្ជង់ ។
794 លើកទ័ពចេញទៅត្រូវត្រង់ ត្រពាំងបើងស្រង
ក្នុងខេត្តសំរោងទងស្រោះ ។
795 នគររាជចោលនៅនោះ ងចាប់ជុំពោះ
ខាងត្រើយឯកើតវិញទៀត ។
796 បត់រាស្ត្រខេត្រនោះចង្អៀត កងទ័ពល្បបល្បៀត
សង្កត់យកទ្រព្យច្រើនណាស់ ។
797 លុះឮថាស្តេចឲ្យបះ រាស្ត្រវែងអរណាស់
បបួលគ្នាបះឥតសល់ ។
798 បាភ្នំព្រៃវែងរៀងដល់ រមាសហែកយល់
តែពលសៀមសឹងពាសពេញ ។
799 ខ្មែរខ្វល់បបួលគ្នាដេញ ទ័ពសៀមមិញ



ពុំដឹងខ្លួនឡើយលុះស្លាប់ ។
800 អស់លោកចៅឃុនមេទ័ព ធ្វើសំបុត្រប្រាប់
ទៅផ្លូវបាភ្នំព្រៃវែង ។
801 ពីកាលពុំទានច្បាំងទែង កាលនោះសៀមឯង
ច្បាំងឈ្នះយួនយល់ដើងកា ។
802 ទើបត្រាស់សំបុត្រទៅថា ដើងទឹកដើងការ
ឲ្យខំម្ទីម្នាលើកទ័ព ។
803 យួនរាជដាមេកងទ័ព លើកឡើងប្រញាប់
ទៅដល់ភូមិស្មោងនោះខ្វី ។
804 វេលាល្ងមគោក្របី ចូលក្រោលប្រក្រតី
ស្រាប់តែឃើញពួកកងទ័ព ។
805 វារត់ចូលមកប្តឹងប្រាប់ ថាខ្មែរបះកាប់
កងទ័ពសៀមបានច្រើនក្រៃ ។
806 ទាំងលុខោនសូវីន្ទនោះនៃ ខ្មែរលុកក្បិនក្បែយ
នៅផ្លូវវាលម្មមនោះឯង ។
807 មេទ័ពបានស្តាប់ជាក់ស្តែង ក្រេវក្រោធពុំលែង
ឲ្យសម្លាប់លាវប្រាំនាក់ ។
808 បទរត់ចោលគ្នាផ្អើលភ្ញាក់ ខ្មែរខ្ជិនពីរនាក់
នៅផ្ទះភូមិស្មោងនោះផង ។
809 សម្លាប់ស្រេចហើយវិលផ្គង ភូមិពាក់សន្ទោង
បោះទ័ពឲ្យធ្វើបន្ទាយ ។
810 ស្រាប់តែឃើញខ្មែរទាំងឡាយ លើកកងទ័ពពីរអាយ
ទៅតាមនឹងច្បាំងកាលនោះ ។
811 ពញារាជឲ្យចាប់ខ្មែរចុះ កងទ័ពផងនោះ
សាមសិបទៅកាប់ឥតសល់ ។
812 ស្រេចហើយលើកទ័ពមកដល់ ពោបង្សូរយល់
តែខ្មោចសៀមខ្មែរសម្លាប់ ។
813 មកពីនោះជួបកងទ័ព ចសែនសួប្រាប់
ថាខ្មែរបះកាប់ដូចគ្នា ។
814 លើកចេញពីនោះវេលា ព្រលប់មើលគ្នា

មិនស្គាល់ដល់មាត់ទន្លេ ។
815 ឲ្យកាប់ឫស្សីសឹងតែ ចងក្បួនបង្វែរ
យប់នោះលុះព្រឹកឆ្លងបាន ។
816 ទុកស្លេះនៅនេះនិទាន តពីដើមដាន
ដែលបានស្រដីមកនោះ ។

817 បទព្រហ្មគិតកាប ចាយចែងចាប់ចេញចំពោះ
ពាក្យពេជ្យពីមុននោះ លោកមេទ័ពបង្គាប់ថា ។
818 ប្រើរើសតតកំដែង ចោលចេញវិញតតសង្កា
តំណាក់វាំងក្តីណា ដុតផ្ទះផ្សាររស់តតសល់ ។
819 ឯរស់គ្រួចិនខ្មែរ សោតសឹងតែភ័យរចល់
ចុះទូករកកិច្ចកល គិតមិនយល់នឹងទៅព្រា ។
820 រីលោកចៅឃុនធំ គិតជុំនំនឹងភ្នាក់ងារ
គិតគាគ្រួគ្រប់គ្នា យកទៅជាខ្ញុំឲ្យបាន ។
821 មេទ័ពបង្គាប់ផ្ទោះ សេនានោះប្រុងប្រៀបប្រាណ
ចុះទូកចម្បាំងបាន ពួកទាហានក្រាស់ក្រោយក្រែ ។
822 គ្រួរក្រាសពេញទន្លេ សោតសឹងតែភ្ញាក់ភិតភ័យ
នឹងចេញទៅទីទៅ ខ្លាចក្រោយក្រែគ្រៀងសើកសព្វ ។
823 ខំចែវទូកទៅមុខ ចិត្តពុំសុខសឹងថែថប់ គេកាលរាល់គ្រួគ្រប់
ទូកគេខ្ទបទាំងសង្ខាង ។
824 គ្រួរក្រប៊េរិះរេ ទិទន្លេនោះនឹងវាំង
នឹងចៀសចេញទៅខាង ឲ្យរបួសវាំងគេពុំបាន ។
825 គិតគ្នាភ្លៀងលើគោក ស្រេចហើយយកភ្លើងគ្រប់ប្រាណ
អុចទូកឯងនោះបាន ចេញចាកស្ពានចូលព្រឹកព្រៃ ។
826 ព្រាត់កូនព្រាត់ប្រពន្ធ ចោលទ្រព្យធនឥតសង្ស័យ
ហេតុចិត្តគិតភិតភ័យ ខ្លាចខ្លួនក្ស័យក្សិនមរនា ។
827 ឯរស់ទូកគ្រួរគ្រាប់ ភ្លើងភ្លើកាសព្វសុះទូកក្ពារ
ខ្ទូចហេងបាត់ទ្រព្យា ក្នុងគន្លាកាលនោះណាស់ ។
828 សម្បត្តិពេញទាំងទូក នោះនឹងយកពុំរហ័ស



ហេតុខ្លាចគេនោះណាស់ នឹងវាតគាស់ទាំងទូកទៅ ។
829 ឲ្យរួចពិតពុំបាន ត្បិតទាហានគេក្រាស់ក្រៅ
គេបាញ់កាំភ្លើងទៅ ខ្ទេងប្រសព្វខ្ទប់នឹងគ្នា ។
830 ខំដឹកដៃកូនចៅ នោះឡើងទៅព្រៃព្រឹក្សា
ពួនពឹងពាក់អាត្មា ឲ្យរួចគ្រោះកាលនោះណី ។
831 មេទ័ពកៀគ្រួរនោះ នាមងារឈ្មោះហៅអព្វេ
ត្បែសមួយនោះនាមនៃ ជាព្រះអង្គដើមឈ្មោះម៉ា ។
832 គិតកៀគ្រួរយកទៅ ទីលំនៅនាយនោះណា
ពុំបានបទទូកក្តារ ដុតវិនាសអស់អន្តរាយ ។
833 ខឹងចិត្តឯងទីទៃ ទាំងអព្វេត្បែសនៅនាយ
ព្រះអង្គយើងនៅអាយ ក៏គិតស្តាយដែរដូចគេ ។
834 ទូកគ្រួរក្រាស់ដេរដាស នៅពេសពាសពោះទន្លេ
បើគិតទៅឲ្យថែរ វាប្រហែលស្មើម៉ឺនបាន ។
835 ខំចាប់យកគ្រួទៅ ទីលំនៅដោយប្រមាណ
ប្រហែលពីរពាន់បាន ទាំងកូនចៅរាប់រស់រាយ ។
836 ដំណើរលោកចៅឃុន ធំមានបុណ្យលើសសម្ពាយ
ឲ្យផាត់គ្រួទៅនាយ នឹងចែងចាយចោលពុំនោះ ។
837 ទើបនឹងនិយាយត ឯនគររាជដំពោះ
ចាប់ឈប់បឹងស្រងនោះ នៅក្នុងខែត្រសំរោងទង ។
838 មកក្រោយលោកចៅឃុន ចាប់គ្រួរមុនរស់តតហ្មង
នគររាជគិតឆ្លង ជ្រោយចង្វាររត្រូវព្រៃកដើងព្រៃ ។
839 ឯរស់រាស្ត្រទាំងឡាយ រត់ប្រញាយទៅទីទៃ
ទៅរកពួនក្នុងព្រៃ ពឹងប្រាស្រ័យកម្លាំងកាយ ។
840 កំពង់សៀមដើងព្រៃ សឹងភិតភ័យពុំសប្បាយ
រៀងរាល់ទាល់បារាយណ៍ កំពង់ស្វាយដែលដូចគ្នា ។
841 រីឯខេត្តបារាយណ៍ រត់ប្រញាយឡើងចំការ ព្រៃធំជុំជិតគ្នា
ខ្លះនៅនាក្បាលទឹកហង្ស ។
842 មានកាលមួយថ្ងៃនោះ ក្មេងវាដោះមាត់បំពង់

[1] Les trois strophes 822, 823 et 824 sont empruntées à la version imprimée *Rœang Roba khsat srok khmè*, vol. II, p. 95.

នឹងដងទឹកក្បាលហង្ស ឮឃ្មុំៗថាស្គរទ័ព ។
843 ភ្ញាក់ផ្អើលឡើងឆោឡោ រត់រចៅភ័យស្ទើរស្លាប់
កូនចៅហៅប្រញាប់ ថានែទ័ពគេមកដល់ហើយ ។
844 ខ្លះស៊ីបាយនឹងមាត់ ខ្លះទើបញាត់បាយនៅឡើយ
ខ្លះបានស៊ីរួចហើយ ដោយដំណើរនោះទីទៃ ។
845 លុះឮថាទ័ពដល់ រត់រចល់កាំងភិតភ័យ រកហៅគ្នាទីទៃ
ពាសពេញព្រៃព្រាត់កូនចៅ ។
846 ខ្លះបានជួបជុំគ្នា ពុំឃូរយាវែកទូលទៅ ខ្លះចាំជុំកូនចៅ
ស្រេចទើបទៅតាមជាក្រោយ ។
847 ខ្លះខ្លួនទាល់ក្រក្រៃ មានកូនខ្ចីប្តីឯងឲ្យ ប្រពន្ធបីកូនក្រោយ
ទូលបង្វិចតិចទេហោង ។
848 ឯប្តីរែកអង្ករ ឆ្នាំងសម្លរឆ្នាំងបាយផង
រែកធ្ងន់ពន់កន្លង ទន់ទាំងខ្នងទ្រាំគ្រោះគ្រា ។
849 ខ្លះមានកូនតូចស្ទើរ នឹងបណ្តើរពុំទាន់ឡោះ
ដាល់លើកញើចុះ លើករែកត្រោះចចេញទៅ ។
850 ឯកូនកុមារនោះ រែកដូង្គោះអរចៅរៅ ហេតុក្មេងពុំដឹងជ្រៅ
ថាជាទៅលេងសប្បាយ ។
851 ឯអង្គអាពុកធ្ងន់ ទ្រាំត្រិនត្រូនទ្រូងស្ទើធ្លាយ
ខំរែកបែកញើសខ្វាយ ពោះតែស្តាយសាច់សង្សា ។
852 ឯកូនគិតពុំជ្រៅ ពុំដឹងខ្ចីធ្ងន់ឡើយណា ដាក់អង្រែកចុះពីស្មា
កូននោះណាយំទធាក់ ។
853 ថាចង់ជិះកញ្ជើ ឲ្យរែកដើរកុំឲ្យដាក់ អាពុកខឹងកន្ត្រាក់
ដាវលើកយាថាអាឯង ។
854 អញកាប់ចោលបង្ហៀត ទៅឲ្យត្មាតវាប្រជែង
កូនខូចដូច្នេះឯង តើនឹងលេងទុកវាថ្វី ។
855 កូនយល់អាពុកខឹង បាត់មាត់ឈឹងស្ងៀមនៅខ្មី ពុំយំពុំស្រដី
ថាអ្វីៗឡើយស្ងៀមសោះ ។
856 ឯអស់គ្រួរនោះនៃ ដើរដោយព្រៃសំសាន្តគ្រោះ
វង្វេងវិលវុលចុះ មកជំពោះគិតពីយប់ ។
857 ប្រពន្ធប្រាប់ទៅប្តី ថានែវុំដែលយើងឈប់



ដាក់គិតកាលពីយប់ នោះឯងមិញអញចាំដាក់ ។
858 វង្វេងវុលចុះឡើង អន់អស់ជើងហើយឈប់ដាក់
គ្នាច្រើនជ្រួលគ្រឹកគ្រាក់ ឈប់ដល់ដាក់ដុះជួបជុំ ។
859 ស្រេចហើយបណ្តឹងគ្នា សាកសួរសាគិតជុំនំ
នណាឮស្គរធំ ថាទ័ពជុំដល់ដូច្នេះ ។
860 ដន្តិងសាកសួរសព្វ អស់គ្រួរគ្រប់ទៅជំពោះ
លើក្មេងដែលវាគោះ បំពង់នោះអស់សង្ស័យ ។
861 សើចសួក្អាកក្អាយ សុកសប្បាយឥតទុកភ័យ
ធ្វើស្រុបនៅទីទៃ តាំងពីថ្ងៃនេះឥតហ្មង ។
862 ឈប់នៅនាទីនោះ នឹងដូច្នេះហើយកេនកង
ឧកញ៉ាព្រហ្មជាស្នង គិតកេនកងរាស្ត្រទីទៃ ។
863 ប្រពន្ធគាត់ឈ្មោះម៉ា[1] នឹតនៅនាភូមិទ្រាលនៃ
មានព្រហ្មមួយដទៃ ធ្វើជាងារក្រឡាពាស ។
864 តែងទៅជួបជុំគ្នា គិតរាជការរក្សារាស្ត្រ
ព្រហ្មជាក្រឡាពាស ប្រពន្ធពីរឥតឆ្គង ។
865 ប្រពន្ធមួយឈ្មោះម៉ា មួយឈ្មោះជាតូចវិញហោង
គាត់សង់ផ្ទះនៅផង ភូមិទន្លេវាលវិញដាក់ ។
866 ឧកញ៉ាព្រហ្មទាំងពីរ នៅស្និទ្ធស្នេថៃរាស្ត្រវាក្យ
សត្រូវគ្រប់ជាងជាក់ ពឹងពំនាក់អស់អង្គប្រាណ ។
867 រវាតរវាំងគ្រប់ ផ្លូវស្រុះសព្វសឹងកដាន
ប្រយ័ត្នក្រៃងមោះមាន សិកសត្រូវទៅដល់គ្រួរ ។
868 តែងទៅមកសព្វថ្ងៃ ពួនពឹងព្រៃសព្វគ្រួបត្តូរ
តែងទៅមករកសួរ ស្ងៀមផាត់គ្រួឬជាទេ ។
869 មានខាវល្បាតបំរើ គិតចាត់ប្រើទៅសួរគេ
គ្រប់គ្រួរទាល់ទន្លេ នោះឯងគេប្រាប់វិញនៃ ។
870 ថាយើងឲ្យបំរើ ទៅសួរសើរដល់ជើងព្រៃ

[1] Ce vers a été introduite par erreur par le copiste. Le même vers se trouve dans la strophe 865. Dans la version imprimée, *Ræang Roba khsat srok khmé*, vol. II, p. 99, les quatre vers de la strophe 863 sont les suivants: នឹត្យនៅនាភូមិទ្រាល ផាទីវាលនោះឯងនៃ ចេះកិច្ចការច្រើនក្រៃ
ធ្វើងារជាក្រឡាពាស ។

ថាមានមេធំក្រៃ ឈ្មោះហៅពញ្ញានគរាជ ។
871 ដំរីច្រើនធំៗ ភ្លេងរងំមកមិនខ្លាច ឯពញ្ញានគររាជ
ពលគេច្រើនមួយហ្មឺនប្លាយ ។
872 គេដើរដល់ជើងព្រៃ ពីរបីថ្ងៃដល់បារាយណ៍
គេផាត់គ្រូវពីនាយ យកមកអោយបានច្រើនណាស់ ។
873 ខាវល្បាតបានដឹងហើយ ពុំលង់ឡើយវិលរហ័ស
ហេតុដឹងដំណឹងច្បាស់ ភិតភ័យណាស់ស្រូតម្នីម្នា ។
874 មកដល់ឧកញ្ញាព្រហ្ម ប្រាប់ដោយដំណើររាជការ
គ្រូវផងភិតភ្ញាត់ណា ប្រាមប្រាប់គ្នាឲ្យប្រញាប់ ។
875 យកគ្រូវឡើងទៅទុក ព្រៃជិតស្តុកស្ងៀមស្ងប់ស្ងាត់
ប្រើប្រុសចេញវង្កាត់ ផ្លូវស្រឡៅនូវផ្លូវដារ ។
876 ឯពញ្ញានគររាជ ឫទ្ធិអំណាចតូចសិហា ឥតភ្ញើកសើកសោះសោរ
ដល់ភូមិណាអូជអស់ផេង ។
877 អស់ល្បាតបានដើរដល់ ទ្រាលយុងយល់ឃើញតែផ្សែង
ស្រឡៅតានោះឯង អូជអស់ផេងហើយហួសទៅ ។
878 អស់ល្បាតខាងឯយើង យល់អូជភ្លើងតាស្រឡៅ
មិនហ៊ានដើរដោយផ្លូវ ពុំទួននៅដោយដងព្រៃ ។
879 លឡប់លលិបឡ ដកដែកចេញទីទៃ មើលមកពីក្នុងព្រៃ
ភ្នែកតែងរំពៃភ័យផ្សុក ។
880 ភ្លះបានមានចិត្តនោះ ខំទម្លុះទៅដល់ព្រៃ
តាមដានដែលដើរទាក់ ទ័ពដំរីសេះរទេះ ។
881 ល្អិតល្អន់ល្អានជាធ្លា ដោយមាគ៌ាគិតរមិះ
នឹងគ្នាថាទ័ពនេះ តើវាទៅនៅត្រឹមណា ។
882 អ្នកខ្លះឆ្លើយទៅវិញ ថាឯអញគិតទៅថា
ទ័ពនេះយល់ជាវា បោះនៅនាភូមិប្រាសាទ ។
883 បទអូរដ្បិតមានអូរក្បាលទឹក ហួរគគិកស្មៅលាស់ស្អាត
យល់ជានៅប្រហោទ នោះពុំឃ្លាតនៅនោះឯង ។
884 គិតស្រេចដើរព្រាងព្រៃ ភ្នែករំពៃគិតយល់ឆ្វេង
ប្រកល្អកស្រុកទីឯង តែងនិងដើរដឹងមុនស្រាប់ ។
885 លុះលបទៅយង់យល់ អស់ពួកពលសៀមបោះទ័ព



ពលទីមីខ្លាន់ខ្លាប់ ដំរីសេះគោក្របី ។
886 ស្រេចហើយវិលវិងមក ឯអស់ពួកគ្រូវឯងឃ្មី
ប្រាប់ប្រាយរាយសំដី សម្តែងពីពួកទ័ពនោះ ។
887 ព្រហ្មពីរមេគ្រូវស្តាប់ អស់សារសព្វពាក្យដូច្នេះ
ចាត់ប្រើបំរើចុះ គិតគយឃ្លាំចាំគ្រប់ផ្លូវ ។
888 ដំណើរអស់គ្រូវនេះ ឈប់ទុកស្លេះនឹងនិតនៅ
និទានតែងទៀតទៅ ឯនគរាជកាលនោះ ។
889 នៅនឹងនិងអង្គខាន ឈប់សំរាន្តជើងពលស្មោះ
មួយយប់ចេញចំពោះ ពីទីនោះចរចេញទៅ ។
890 ដិរង់កំពង់ស្វាយ ពីបារាយណ៍រាងតាមផ្លូវ
លុះបានឆ្លងស្ទឹងហៅ ត្នោតជុំទៅអាសន្ទុក ។
891 ដំរីច្រើនដេរដាស់ ដើរពេញពាសសព្វគគុក
តាមផ្លូវទៅឯមុក ហួសសន្ទុកឯលិចភ្នំ ។
892 កាលនោះឯឧកញ្ញា រាមនៅនាកំពង់ធំ
គិតកែនមនុស្សមកជុំ ចាំបន្ទាយនោះនឹងនៅ ។
893 ហើយឲ្យមានគយល្បាត តែងសង្វាតចាំមើលផ្លូវ
នគរាជលើកទៅ ឲ្យមកទល់បរល់ឃើញច្បាស់ ។
894 ដំរីគ្រឿងសឹកសព្វ ពលគេបុកលើសច្រើនណាស់
ពុំហានទល់ទ័ពទាស់ រត់ចូលអស់ក្នុងបន្ទាយ ។
895 ឯពញ្ញានគរាជ មើលមិនខ្លាចឃើញពីនាយ
ឲ្យទាក់ព័ទបន្ទាយ និងទម្លាយចេញពុំបាន ។
896 ដំរីគេធំៗ ចារចោមជុំជិតសព្វស្ថាន
និងចេញពិតពុំបាន បទទាហានគេសុះសល់ ។
897 និទាននេះទៀងទេ ពីតពីខ្សែមួយមកដល់
នគរាជលើកពល ព័ទបន្ទាយកំពង់ធំ ។
898 ដំណើរដំណែងកាព្យ គិតរៀងរាបជាបន្សំ
កាលព័ទបន្ទាយជុំ ជាខ្សែពីរពិតបន្ទាប់ ។

ចប់ខ្សែពីរ

## ខ្សែ ៣

899 បទកាកគតិ ដំណើរដំណារ ដំណាលរៀបរាប់
ពីពីរខ្សែទៅ ដោយនូវសន្តាប់ សំដែងសារសព្វ
សេចក្តីកាលនោះ ។

900 ពញ្ញានគររាជ វិងឫទ្ធិអំណាច ឯងអាចពិគ្រោះ
ឲ្យអស់សេណា យោធារច្រើនច្រុះ រកយកឈើនោះ
ជុំពាមមកខ្ញី ។

901 ពាក់ក្បាលបន្ទាយ យកព្រាតបន្លាយ ទាក់កដំរី
ឲ្យទាញបន្ទាយ ធ្លាក់ធ្លាយចេញខ្ចី ពុំអាចដើម្បី
និងនៅបានឡើយ ។

902 កាលនោះឯពល ដេជោរាម្ទយល់ បន្ទាយធ្លាយហើយ
ភិតភ័យរន្ធត់ រួតរត់ជាត្រើយ ពិតពុំរួចឡើយ
គេចោមជិតក្រៃ ។

903 ដេជោរាម្ទមាន សេនាមួយប្រាណ នាមឈ្មោះហ្មើននៃយ
ដាវវែងខ្នងក្រាស់ កម្រាស់មេដៃ កំឡាំងហ្មើននៃយ
ខ្លោះខ្លាំងពេកពិត ។

904 ពលនគររាជ មើលមកមិនខ្លាច ចូលចោមជុំជិត
នៃយលើកដាវឯក គ្រវែងគ្រវាត់កាប់ដូចគេកាត់
បិបួនអ្នកម្តង ។

905 ពលសៀមរអា នាមនោះសេនា បើកមុខនោះហោង
ឯដេជោរាម្ទ រួតតាមក្រោយខ្នង គ្រូនក្រាបគេផង
ជ្រកជ្រួនពួនព្រៃ ។

906 ទើបឯសេនា នាមដើមរៀចថា ហៅឈ្មោះហ្មើននៃយ
កាប់សារវិលក្រោយ ឲ្យពលទីទៃ រួតចេញចូលព្រៃ
ពឹងពួនអាត្មា ។

907 ជួយយកពលឯង ឲ្យរួចចូលត្រែង ពុំបានមរណា
ដំរីចូលចោម ជំជិតអាត្មា នៃញុះពានពារ ទៅដល់ដំរី ។

908 ពញ្ញានគររាជ គិតកាប់មិនខ្លាច ខ្លួនក្សំយជីវិត
កាប់ខ្សែប្រទាក់ ដែកដាក់ដំរី ពុំដាច់ដូចក្តី ប៉ុនប៉ងប្រាថ្នា ។



909 អន់អស់កំឡាំង ហើយណាស់ទុនទាំង ជើងដៃកាយា
គេចាប់ចងបាន បំរេចម្តេចម្តា ពុំក្សំយជន្មា
បំផ្លោងទឹកទៅ ។

910 ឯអស់ពលទ័ព ភាំងឡាយស្លូតស្លាប់ ដេរដាស់ដោយស្មៅ
ខ្លះរួតរួចបាន ដល់ស្ថានព្រៃជ្រៅ ជ្រកជ្រួនពួននៅ
ឲ្យគង់ជីវិត ។

911 ពលសៀមនោះនៅ ចោមជំពីក្រោយ ក្រាស់ក្រៃបកិត
ដូចគេលើកសត្វ បង្កាត់ជុំវិញ ប្រហារជីវិត មមីរៀបត្រា ។

912 ឯរស់និងស្លាប់ ប្រមានបើរាប់ ប្រហែលស្មើគ្នា
ពលពួនដោយត្រែង លំពែងផ្លាញផ្លា ខ្លះក្នុងគុង្គារ
មរណាច្រើនក្រៃ ។

913 ពញ្ញានគររាជ វិងរឹតអំណាច តេជោជាញជ័យ
បង្កិនកងទ័ព ខ្មែរស្លាប់នោះនៃ ស្រេចហើយវៃៗ
លើកកងទ័ពទៅ ។

914 នគររាជនោះ សង្វេបទុកស្មេះ ប៉ុន្នេះនឹងនៅ
ទើបនឹងនិយាយ ចែងចាយតទៅ គ្រប់គ្រូវដែលនៅ
ក្នុងព្រៃនោះវិញ ។

915 លំបាកព្រួយប្រាណ ទ្រាំអត់ទ្រាំឃ្លាន ជាទុក្ខអំនិញ
ក្នុងចិត្តថាឱក អផ្សុកចង់ចេញ មកនៅស្រុកវិញ
ទាល់តែត្បិតខ្លាច ។

916 ក្រុមគ្រូវទាំងឡាយ ចុះឡើងខ្វល់ខ្វាយ
ចេញព្រឹកវិលល្ងាច រិះរកអាហារ ភោគ្គារទាំងខ្លាច
ក្រែងទ័ពញ្ញារាជ សៀមនៅឯក្រោយ ។

917 គិតបំបែកគ្នា គយល្បាតមាគ៌ា ពិតពុំឲ្យធ្លោយ
ខ្លះគិតកាប់ស៊ី ក្របីគោឲ្យ តែបានតូចដោយ ចិត្តចង់ភោគ្គារ ។

918 ពុំគិតភារខ្មាំង វារាចងចាំ ឬបបានអាត្មា
ទ្រព្យគេទ្រព្យឯង ឥតក្រែងចិន្តា លួចលាក់ទ្រព្យគ្នា
ឯងឥតសំចៃ ។

919 អ្នកខ្សត់ជាមាន សម្បត្តិធនធាន ទុកទើក្នុងព្រៃ
ខ្លះយកទៅលាក់ ដាក់ទុកសំចៃ ខ្លះលួចវិញវៃ

លាក់ព្រៃឯទៀត។
920 កើតទុកភិតភ័យ ចោលផ្ទះទីទៃ ទាំងម្ហោះឯងមិញ
នៅតែលោភកាច ពុំអាចចោលចេញ ចង់បានលំដេញ
ពិតពុំរសាយ។
921 ពុំគិតខ្លួនស្លាប់ ចាក់ចោលរស់ទ្រព្យ ឯងរស់អន្តរាយ
ចាកចេញចោលស្រុក អាពុកនៅម្តាយ ពុំគិតពុំស្តាយ
ជីវិតអាត្មា។
922 នៅតែចង់បាន រស់ទ្រព្យធន់ធាន និងយកទៅណា
ថប់តែទ្រព្យឯង ក្រែងគិតរក្សា ពុំទាន់ម្តេចវា
ចង់បានទ្រព្យគេ។
923 កាលនោះរស់ល្បាត ឮថាពញារាជ បានឆ្លងទន្លេ
មកដល់កំពង់ សៀមក្នុងខែត្តគេ ពីរបីថ្ងៃទេ
មកដល់បារាយ។
924 រស់គ្រួរទីទៃ ភ្ញាក់ផ្អើលភិតភ័យ ញីររស់អង្គកាយ
ប្រុងប្រាន់ប្រយ័ត្ន វង្វាត់សព្វសាយ គ្រប់ផ្លូវទាំងឡាយ
ដើរសើរសៀវព្រៃ។
925 កាលនោះឮលេច ឮរស់ពាកពេច អ្នកជងទីទៃ
ថាពញារាជដល់ ពួកពលច្រើនក្រៃ គេឆ្លងដើងព្រៃ
ស្អែកដល់បារាយ។
926 ឯឧកញ្ញាព្រំឬ ជាមេគ្រួធំ ចាត់ចែងខូលខ្វាយ
ឲ្យគយល្បាតទៅ គ្រប់ផ្លូវទាំងឡាយ ទំពសៀមឬសឆ្ងាយ
ទើបវិលវិងវិញ។
927 កាលខ្មែរពុំសុក សៀមលើកជាន់ស្រុក មាកសិក[1]ឆ្នាំម្សាញ់
លុះដល់ខែបុស្ស បាស់កាប់សៀមវិញ មាយធំត្រូវចេញ
ចោលស្រុករុកព្រៃ។
928 ដល់ខែផល្គុន ទំពលោកចៅឃុន ថយទៅវិញន័យ
ឯរស់មេទំព គ្រប់ផ្លូវទីទៃ តាមឃុនភូយ៉ៃ រស់ឥតមានហ្វង។
929 គ្រួរខ្មែរទាំងឡាយ សិងសុកសប្បាយ ឥតទុក្ខភ័យផង

[1] Il faut lire មិគ្គសិរ [mikasé], le premier mois de l'année.



គ្រួរឡើងចម្ការ គិតគ្នាអីង្គង យើងនៅនោះហោង
លំបាកពេកណាស់។
930 ព្រៃចំការលើ ទឹករីងហើយតើ ស្មៅសោតមិនលាស់
នឹងឲ្យក្របី គោស៊ីស្គមណាស់ វាលក្រោមស្មៅលាស់
ក្របីស៊ីបាន។
931 ហើយរស់អាហារ ត្រីសាច់ក្តីណា មិនរត់មិនឃ្លាន
គ្រប់គ្រួរវិះគិត គំនិតគ្រប់ប្រាណ ព្រមគ្នាស្មោះស្មាន
មិនមានថាអ្វី។
932 គិតស្រេចដូច្នេះ ព្រមគ្នាស្រេចស្រុះ ទាំងប្រុសទាំងស្រី
តាមឡើនកូនចៅ រកហៅគ្នីគ្នា ដឹកគោក្របី រទេះទឹមនៅ។
933 រស់គ្រួរគ្រប់គ្នា ចេញព្រៃចម្ការ កាត់មករកផ្លូវ
គដិកគគឹក សន្ធឹកក្រែក្រោយ បរបែមុខទៅ
តាមផ្លូវវាលក្រោម។
934 អរឯងរស់គ្នា សប្បាយចិន្តា ក្មេងចាស់ព្រិសព្រម
ត្រិចត្រាច់ត្រង់ទៅ តាមផ្លូវវាលក្រោម ហុយដីទ្រលោម
ដោមដល់វេហាស៍។
935 និងមើលទៅវាល សព្វសត្វត្រអាល ស៊ីស្មៅត្រៀបត្រា
លេលោះត្រសង ស្រើបស្រងកាលគ្នា តាមដោយហ្វូងវា
ឥតឯអំពល់។
936 រស់គ្រួរទាំងឡាយ ស្រុកជិតស្រុកឆ្ងាយ
ទៅតាមដោយកល ដោយចិត្តគ្រួបស្រុក ឥតទុកអំពល់
ទៅតាមដោយយល់ បឹងបួរទីទៃ។
937 បរបានដល់ទៅ ទីទឹកមានស្មៅ មានវាលមានព្រៃ
មានទីដែលដាក់ ដំណាក់នោះន័យ គ្រប់ទូទីទៃ ចតឈប់និន្ទ្រា។
938 ខ្លះរកនេសាទ ត្រីសាច់សង្វាត ពីរកភោគ្គា
គ្រប់ទូរទាំងឡាយ សប្បាយចិន្តា វិះរកអាហារ
ត្រីសាច់សឹងបាន។
939 រស់គ្រួរទាំងនោះ សង្វេបទុកស្លេះ និងនាំនិទាន
ទៅឯព្រះមហា ក្សត្រាប្រធាន កាលក្រោយឃ្លួនបាន
ដេញសៀមរស់ទៅ។

940 ទើបឯអ្នងថាញ វិញ៊ីនោះមិញ ទុកស្ដេចឲ្យនៅ
គុងសៀមក្នុងថ្នាញ ថាញវិញ៊ីទៅ គិតដេញសត្រូវ
ទ័ពសៀមទាំងឡាយ។
941 ចាត់ប្រើមន្ត្រី យោមរាជចក្រី ចចេញប្រញាប់
ទៅកែនកងទ័ព ប្រញាប់ខ្វល់ខ្វាយ ត្រូបផ្លូវទាំងឡាយ
លើកតាមសៀមទៅ។
942 ដល់ព្រំស្រុកខ្មែរ កងទ័ពឯងឯង អាយនោះនិងនៅ
ហើយមានបំរើរ សំបុត្រប្ដឹងទៅ ថាញ់វិញ៊ីនៅ
បន្ទាយភ្នំពេញ។
943 ដល់ដេញទ័ពសៀម ថយទៅនៅស្ញៀម ក្នុងឆ្នាំម្សាញ់
ខែចេត្រចូលឆ្នាំ មមិមកវិញ រីឯអ្នងបាញ់ នោះនៅត្រួតត្រា។
944 កាលនោះស្រុកយួន នគរជួបជួន អង្គស្ដេចទេព្វា
ប្រើអ្នងថាំមតាន ជាយជនមកថា ខាំមាងអាជ្ញា
ល្ហងមកស្រុកខ្មែរ។
945 មកយកអ្នងថាញ វិញ៊ីនោះមិញ ទៅដល់ស្រុកហ្វេ
ទើបស្ដេចទេព្វា ស្លូរសាជូនថៃ រាជ្កាស្រុកខ្មែរ
ឥតឯចន្លោះ។
946 ទើបឯអ្នងបាញ់ វិញ៊ីនោះមិញ ទូលទៅសព្វសារ
ពីកាលកងទ័ព ជាប់ជាន់ស្រុកនោះ ឥតឯចន្លោះ
ទូលសព្វសេចក្ដី។
947 ទើបស្ដេចទេព្វា ពិចារណាថា ឯបាញ់វិញ៊ី
នេះមានគុនគាប់ ដេញទ័ពសៀមពី ស្រុកខ្មែរទៅទី
នគរវិញបាន។
948 ទើបស្ដេចទេព្វា ឲ្យអស់ទ្រព្យា សម្បត្តិធុនធាន
យសស័ក្តិជាធំ ឧត្តមថ្កើងថ្កាន ស្រេចហើយស្ដេចមាន
បន្ទូលត្រាស់ថា។
949 ឲ្យអ្នងធំៗ រិះគិតជំនុំ ពិគ្រោះទោសា កាលបាញវិញ៊ី
គិតក្បត់ក្សត្រា សម្លាប់សេនា នូវអស់ពល់រេ។
950 មុនសៀមឆ្នាំម្សាញ់ នោះឯងអ្នងបាញ់ ចូលនិងជវេ
គិតក្បត់ម្ចាស់ឯង តាក់តែងពលរេ ទើបស្ដេចប្រើគេ



សម្លាប់វិញបាន៕
951 ទើបស្ដេចទេព្វា មានបន្ទូលថា ឲ្យអ្នងថាំមដាន
ធ្វើជាទៀងគុន ធំពុនប្រមាន នាំស្ដេចយើងបាន
វិលវិញមកស្រុក។
952 ហើយស្ដេចទេព្វា ឲ្យអ្នងមួយជា ខាំមាងថុងតុក
ប្រើមកកំដរ ស្រករៀបស្រុក ឲ្យអ្នងថុងតុក ជាអាជ្ញាល្ហង។
953 ស្ដេចត្រាស់បង្គាប់ អ្នងពីរបានស្ដាប់ បន្ទូលទាំងពួង
ក្រេញក្រាបហៅហោ លុះលានាំល្ហង ពលពាលទាំងប្អូន
ដង្ហែវិលវិញ។

954 បទពុំនោលនេះថែងចេញ ឯអង្គក្សត្រមិញ
ព្រះបាទឧទៃរាជា។
955 ស្ដេចបានដល់ស្ថានក្សត្រា ទតទៅធ្លីធ្លរ
អាសារអាសោចស្ងួនសោះ។
956 ស្ដេចទ្រង់ព្រះកន្សែងស្រណោះ អាល័យអាលោះ
ស្រណោះស្រណោកសោកស្ដាយ។
957 កំផែងទាំងអស់អន្តរាយ ដំណាក់ទាំងឡាយ
ខ្ទាត់ខ្ទាយរើរាយអស់ផង។
958 ដំណាក់ដំណាំក្នុងកំផែង ផ្កាចោលចេញផង
រលីងអស់ឥតមានសល់។
959 ទោះទាំងផ្ទះផ្សារចប់ថ្នល់ ដុតអស់ឥតសល់
មណ្ឌលមន្ទីរកេរិកោះ។
960 ស្ដេចគង់ទ្រង់គិតពិគ្រោះ អាល័យអាលោះ
ស្រណោះមន្ទីរកិរម្យ។
961 ទើបស្ដេចគុនគិតជុំនំ និងអ្នងជាធំថា
ភ្នំពេញពុំសប្បាយ។
962 ដ្បិតបាក់បែកខ្ទាត់ខ្ទាយ ទើបក្សត្រពន្រាយ
ឲ្យធ្វើបន្ទាយទៀតខ្មី។
963 កាលនោះព្រះបាទចក្រី ប្រើធ្វើជាថ្មី

ដីពោព្រះបាទវិងវិញ ។

964 ឯអ្នងនោះនៅភ្នំពេញ រៀបធ្វើកើបិញ
មានចាញមានផ[1] ដោយកាយ ។

965 ហើយប្រើរៀបធ្វើបន្ទាយ ទ្វារស្រុកសព្វហោយ
ដោយកាយកើបិញចេញទៅ ។

966 ទៀងគុនធំលុននិតនៅ ប្រើអ្នងតូចទៅ
ធ្វើការរក្សារទ្វារស្រុក ។

967 យើងពុំពាន្ទាចោលទុក និទានទៅមុក
ខាងខេត្តកំពង់ស្វាយស្មោះ ។

968 ដ្បិតម្ចាស់ត្រាស់ប្រើចំពោះ នារិននង់នេះ
និងវាំងនាមដើមឈ្មោះទំម ។

969 ទៅឈរនិងអ្នងបន្សំ រិះគិតជុំនំ រាជ្ការរក្សាទ្វារស្រុក ។

970 ប្រយ័ត្នរាជការដោយមុក ពោធិសត្វសំបុក
សោតសិងតែមានបន្ទាយ ។

971 អ្នងធំឈរកំពង់ស្វាយ ឲ្យរើសកកាយ
បារាយជើងព្រៃនោះផង ។

972 កំពង់សៀមទាំងស្ទឹងត្រង់ ច្រើនក្រែកន្លង
ឲ្យរៀបអន្ទាប់ដោយកាយ ។

973 កោយកាន់កើរគប់សព្វសាយ ដោយត្រួតជានាយ
លើកោយកាន់កើរហាសិប ។

974 ផ[2]ត្រួតលើដោយបន្ទាយ ផ[3]នោះឡើងស្តាប់
ឯចាញនោះវិញវិងខ្មី ។

975 ចាញលើងនារិន្ទ្រាធិបតី នារិន្ទមន្ត្រី
ឡើងវាំងអ្នងអានភូវឯង ។

976 អ្នងឲ្យបង្គាប់តាក់តែង ទៅស្មោងចក្រែង
សិងមានបន្ទាយសាយសព្វ ។

977 ខេត្តក្នុងកំពង់ស្វាយគ្រប់ បន្ទាយសាយសព្វ

---

[1] Il faut lire ផ្ញ [pho], du vietnamien *phó* qui signifie "capitaine de régiment".

[2] Il faut lire ផ្ញ [phó], mot vietnamien *phó* qui signifie "capitaine de régiment"

[3] *Idem.*



សឹងមានកើបិញដូចគ្នា ។

978 នេះបទព្រហ្មគិត និងថ្លែងពិតពីរាជការ
កាលយួនត្រង់សេម៉ា កម្ពុជារាជមណ្ឌល ។

979 កាលនោះឯងឯអ្នង ឈរកំពុងធំសោតសល់
សិងប្រើកើពួកពល ពុំឲ្យសល់ដល់មួយគ្មាន ។

980 ខ្លះប្រើធ្វើបន្ទាយ ជីកកកាយដីគ្រប់ប្រាណ
ខ្លះប្រើធ្វើស្រែបាន ស្រូវយកទៅទុកក្នុងឃ្លាំង ។

981 ខ្លះប្រើធ្វើចំរូង ជីករណ្តូងដោយកំឡាំង
ការឈើប្រើឲ្យចាំង ដោយកំឡាំងពួកទីទៃ ។

982 ប្រើកើរខេត្តទាំងប្រាំ ជាចំណាំនៅសព្វថ្ងៃ
ពៅក្លាយស្រុកទីទៃ តែងបញ្ជូនចូលទៅខ្មី ។

983 ឯអ្នងអានភូប្រើ សព្វអំពើពុំប្រណី នាហ្មឺនមុខមន្ត្រី
តូចធំក្តីសិងប្របប្រាណ ។

984 ពុំដែលអ្នកណានិង ហ៊ានរួសរឹងដល់មួយគ្មាន
ខ្លាចយួនព្រួនប្របប្រាណ ពិតពុំហ៊ានឲ្យអាក់ចិត្ត ។

985 អ្នងឲ្យអស់កើរកាយ ធ្វើបន្ទាយតាមកំណិត[1]
ឲ្យល្អឲ្យជាប់ជិត ចាក់ចំរូងចំរុះក្រៅ ។

986 ស្រេចទើបឲ្យអស់កើរ ជីកដីធ្វើជារន្តៅ ជាស្រះស្រឡូងជ្រៅ
ឲ្យទឹកនៅក្នុងបន្ទាយ ។

987 ហើយឲ្យអស់ផចាញ ប្រើកើរបិញផងទាំងឡាយ
រៀនច្បាំងក្រៅបន្ទាយ តាមដោយកាយកាន់កំឡាំង ។

988 បង្គាប់អស់កាយកើរ កាត់យកឈើអស់សំរាំង
ធ្វើជាកាំភ្លើងច្បាំង ហើយបំរៀនបំរៀនប្រាប់ ។

989 ឲ្យលោតជាគូនស្រែយ ប្រើដងវែជាប្រញាប់
ប្រើកើបើពុំឆាប់ កាយវាយខ្វាប់ទៅទីទៃ ។

990 ទះគូតលោតវិលវក់ ធាក់រនុកកាំភ្លើងដៃ វិលទះស្មាទីទៃ
ដៃលើកឡើងជិរង់ស្មោះ ។

---

[1] Il faut lire គំនិត [kumnœt] qui signifie "idée, volonté".

**991** មាត់កើប្រើស្រែកថា ពុំព្រមគ្នាទៅកាលនោះ
ឲ្យឮឲ្យចំពោះ តាមបង្គាប់អុងជាធំ។
**992** ឯមនុស្សអ្នកកំផ្លែង ថាជាល្បែងពុំបារម្ភ ឲ្យតែគេវាយដំ
ដូចឆ្កែឆ្មាគោក្របី។
**993** ដំណើរនេះនិទាន ទុកស្នេះខានពុំស្រដី និទានទៅក្សត្រី
បុត្របួនអង្គគង់នោះវិញ។
**994** ក្រោយអុងឲ្យបង្គាប់ រៀបរន្ទាប់ធ្វើកើបិញ
ក្សត្រជាបិតាមិញ មានអាពាធពន់ពេកក្រៃ។
**995** នឹងទល់ទប់ពុំបាន ពិតពុំក្បាន់ក្សត្រក្សិនក្ស័យ
ជីពជន្មជាតិប្រល័យ លុះសម្រេចផ្ដាច់ជន្មា។
**996** ទើបបុត្រទាំងប្អូន[1]អង្គ គិតអំរូងសព្វបិតា
មុខមន្ត្រីត្រៀបត្រា គិតឲ្យជាព្រះសពស្ដេច។
**997** ឲ្យធ្វើមេរុមណ្ឌប លើកព្រះសពសងស្ការស្រេច
ធ្វើបុណ្យមិនមានដាច់ សូមសំរេចផ្ដាច់វេរា។

**998** បទកាកគតិតែង ដំណើរដំណែង ដំណាលកាលគ្រា
ក្រោយក្សត្រក្សិនក្ស័យ[2] ប្រល័យជន្មា អុងទៀងគុនជា
ធំធាត់ធិបត្តី។
**999** នគរនាម្នា ក្រុងកម្ពុជា រមរាជបូរី មានតែអុងឯង
តាក់តែងអ្វីៗ អុងឲ្យក្សត្រី គ្រប់គ្រងរាជា។
**1000** សករាជគ្រប់គ្រាន កន្លងពីរពាន់ បីរយគន្នា
ចិតសិបប្រាំពីរ បង្វែររាជា ឲ្យបុត្រពុំងារ គ្រប់គ្រងធានីយ។
**1001** ព្រះវរបិតា សោយវិលាល័យ លុះជីវិតក្នុង ឆ្នាំមមែ
បង្វែធានីយ ឲ្យអង្គបុត្រី គ្រងរាជជាស្ដេច។
**1002** អស់មុកមន្ត្រី ប្រជារាស្ត្រក្ដី ចុះឡើងពុំដាច់
គិតគាល់ក្សត្រី អង្គម្ចាស់ជាស្ដេច បង្គំពុំភ្លេច ពុំលុះទេវា។

1 Il faut lire បិ "trois".

2 Les strophes 984, 985, 986, 987, 988, 989, 990, 991, 992 et 993 sont empruntées à la version imprimée *Rœang robat khsat srok khmê*, vol. II, pp. 115-116.



**1003** កាលនោះទៀងគុន គិតការទម្ងន់ ក្នុងដែនពសុធារ
តាមចិតចិន្ដា ពុំពីចារណា រកទោសឲ្យយល់។
**1004** ឲ្យចាប់រិបជាន់ ធ្វើទោសទុកទាន់ ពន្លឹកអស់កល់
កូនចៅធុនធាន ពុំមានសេសសល ធ្វើទុក្ខទោសដល់
សំរេចជន្មា។
**1005** ហើយអុងទៀងគុន ចិញ្ចឹមឲ្យបុណ្យ បរយុក[1]ជាប់ជា
តេជោគ្រប់គ្រង រាស្ត្រផងនៅនា កំពង់ស្វាយជា
ធំចាត់ធិបតី។
**1006** ហើយចិញ្ចឹមស្នង តេជោមួយផង នាមនោះឈ្មោះអី
ឲ្យធ្វើជាស្នង បាញផងស្រដី រាជការអ្វីៗ នៅកំពុងស្វាយ។
**1007** យូរបន្តិចទៅ អុងទៀងគុននៅ តែងត្រូតសព្វសាយ
ឲ្យចាប់នាហ្មឺន មន្ត្រីទាំងឡាយ ក្នុងដីបន្ទាយ
ធ្វើទោសទាល់ក្ស័យ។
**1008** រាស្ត្រផងទាំងឡាយ ស្រដីនិយាយ និងគ្នាទីទៃ
ថាឲ្យយើងនេះ ម្លោះហើយក្រក្រៃ ឥតបើប្រាស្រ័យ
ពឹងពាក់អ្នកណា។
**1009** រាស្ត្រផងភិតភ័យ គ្រូបគ្នាទីទៃ ពុំចេញចរចាត់
ហេតុបទបុនយួន ខ្លាចខ្លួនគ្រប់គ្នា ខ្លាចត្រូវទោសា
អាត្មាទីទៃ។
**1010** ឯអុងទៀងគុន ធ្វើទោសទម្ងន់ នគរនោះនឹយ
តែងឲ្យត្រូតត្រា រាជការសព្វថ្ងៃ នាហ្មឺនទីទៃ
ស្ញើរគ្រូនគ្រប់គ្នា។
**1011** កាលនោះទៀងគុន ជាធំលើសលន់ លើផ្ផែពសុធា
ប្រើអុងអានភូវ កំពង់ធំជា ឲ្យជ្រើសសេនា
ចាប់តេជោចាប។
**1012** មកធ្វើក្ដីស្លាប់ ពុំបានប្រាមប្រាប ទោសគ្នាសូភាព
ពុំពិចារណា ទោសរាជរះប អុងឲ្យធ្វើឃ្លាប
រោលបានក្សិណក្ស័យ។

1 Il faut lire បវរនាយក [bâvânéayuak].

**1013** កាលនោះអស់រាស្ត្រ ប្រជាទាំងផ្លាស់ ភ័នភាំងភិតភ័យ
រំជួលសព្វសាយ កើតកាយទីទៃ រូតរកជ្រកព្រៃ
ពុំស្តាប់ផចាញ់។

**1014** ឯលោកឧកញ្ញា នងនរិន្ទ្រា ធិបតីនោះមិញ
នៅលោកស្នងអី គ្រងងាររជាបាញ់ អ្នងអានភូមិញ
រកកល់ចងចាប់។

**1015** លោកទាំងពីរនោះ ដឹងខ្លួនដូច្នេះ ពុំចូលចិត្តស្តាប
កែនកងសេនា យោធាប្រញាប់ ស្រេចហើយកែនទ័ព
កាប់យួនទាំងឡាយ។

**1016** កាប់ស្រុកកណ្តាល ដល់ស្នោងរៀងរាល់ សព្វគ្រប់បន្ទាយ
អស់ឥតសំណល់ មកដល់បារាយ រាស្ត្រផងទាំងឡាយ
ភៀងជាន់ដើងព្រៃ។

**1017** កាលនោះឯអ្នង ទៀងគុននៅក្នុង ភ្នំពេញនោះន័យ
យល់អស់រាស្ត្រផង រើងកងច្រើនក្រៃ ចូលជាន់ដើងព្រៃ
ភិតភ័យខ្មីឃ្មាត។

**1018** អ្នងឲ្យកែនកង ទ័ពយួនខ្មែរផង ពីពោះព្រះបាទ
បាភ្នំសន្ទូរ លើកមកខ្មីឃ្មាត ឲ្យតាមសង្វាត
ទូលទ័ពចាប់ខ្មាំង។

**1019** នាហ្មឺនធំៗ ពីរឥតជុំនំ ចេញកែនកំឡាំង
លើកឡើងជាទ័ព ប្រញាប់ចាប់ខ្មាំង ភិតភ័យភ័នភាំង
ខ្លាចអ្នងបង្គាប់។

**1020** នាម៉ឺនយួនខ្មែរ ពលពាលបង្អែរ ច្រើនក្រៃខ្លានខ្លាប់
កាំភ្លើងលំពែង ដាវវែងសស្រាប ឲ្យអ្នងឲ្យលើកទ័ព
ទាំងឡាយច្រើនផ្លូវ។

**1021** ឯលោកឧកញ្ញា នាមនរិន្ទ្រា ផ្ទះភូមិស្រឡៅ
យលយួនលើកទ័ព សស្រាបច្រើនផ្លូវ ពុំអាចនិងនៅ
ទប់ទ័ពគេបាន។

**1022** ភិតភ័យភ័នភាំង ចាត់គ្រូវខ្មែរក្មាំង ដែលបាស់ប៉ុន្មាន
រៀបរទេះឆាប់ ប្រញាប់គ្រប់ប្រាណ ចរចេញចាកស្ថាន
រូតរត់ម្ចីម្នា។



**1023** អស់ទ្រព្យទាំងឡាយ ដាក់ចោលរាត់រាយ ឥតឯគន្នា
រទេះបាក់ភ្លៅ ចោលនៅមាគ៌ា ខ្លះក្របីវា ពុំរួចទីទៃ។

**1024** ចោលទ្រព្យទាំងឡាយ ពុំសូវសោកស្តាយ
ដោយសារភិតភ័យ ខៀនព្រៃប្រាក់មាស តុចាសច្រើនក្រៃ
ចោលឥតសង្ស័យ រួចតែអាត្មា។

**1025** រទេះបាក់ភ្លៅ ក្របីនោះនៅ ប្រឆាកទ្រព្យា
ខ្លះខ្លួនកំសត់ អន់អុតរត្លា រែកពុននិងស្នា ទូលទៅទីទៃ។

**1026** ឆ្នាំរត់នោះណា ឈ្មោះឆ្នាំរកា រកាកភិតភ័យ
ចោលទ្រព្យទាំងឡាយ ខ្ចាត់ខ្ចាយទីទៃ សព្វផ្លូវសព្វព្រៃ
ឥតឯគន្នា។

www.amelkhmer.org

**1027** បទប្រែប្រះប្រែងចងជា ភុជង្គលីលា តំណើរពិតពី។

**1028** ឧកញ្ញានរិន្ទ្រាធិបតី ជុំទាវទេវី នាំបុត្រយាត្រា។

**1029** ត្រេចត្រង់កំលុងព្រឹក្សា ដើរដោយមាគ៌ា តំណាក់រៀងទៅ។

**1030** កាលចេញពីស្រុកស្រឡៅ ដំណាក់មួយហៅ ត្រពាំងស្រងែ។

**1031** នាំគ្រូវជាផ្លូវបង្អែរ ពិតពីស្រងែ ទៅដល់ច្នេះស្រេច។

**1032** មានអូរទឹកហូរតិចៗ ឆ្លងយាត្រាត្រេច ទៅដល់ត្រពាំងញរ។

**1033** ឈ្មោះបើសគ្រូវអស់កំឡាំង វាវោយដើងតាំង កូននៅទីទៃ។

**1034** យប់ដាក់ដំណាក់នោះនែ វាលហើយមានព្រៃ
ស្រោងៗស្រណោះ។

**1035** ផ្ញើករាំងត្រពាំងបើសនោះ ខ្ពង់ត្បែងច្រើនច្រុះ
របះព្រៃព្រេច។

**1036** ចេញទៅតាមផ្លូវបន្តិច ហួសពីល្បាស់ព្រេច
លុកលបវាលក្រៅ។

**1037** ដើរវាលកណ្តាលថ្ងៃក្តៅ ពីនោះទៀតទៅ
ទាល់ស្ទឹងដំរែក។

**1038** ស្ទឹងនោះពីគ្រោះខែត្តចែក ចំហៀងស្ទឹងបែក
បានមកបារាយ។

**1039** ចំហៀងស្ទឹងនៅខាងនាយ បានកំពង់ស្វាយ ពីព្រៃងអតីតា។

1040 ឆ្លងស្ទឹងនោះនិងយាត្រា តិចទៅក្រយា
គោកខ្លាងគេនៅ។

1041 ហួសស្រុកឯមុកទៀតទៅ ដល់អូរឆ្នៀងនៅ
អាស្រ័យ៥យប់។.

1042 គ្រូវផងរើង្កងចតឈប់ ទ្រាំថ្ងៃទ្រាំយប់
ចេញចរយាត្រា។

1043 ខ្លះរេកខ្លះទូលគ្រប់គ្នា ខ្លះមានរូត្លា បរបានដល់ទៅ។

1044 អូរផ្អែងនោះឯងមិនជ្រៅ ទឹកតិចកាត់នៅ
គ្រាន់តែភោក្តា។

1045 ពីនោះទៀតស្ទោះយាត្រា ត្រូវព្រៃព្រឹក្សា
សោតសឹងព្រៃក្រាស់។

1046 ព្រៃនោះនាមឈ្មោះជាក់ប្លាស់ ព្រៃជងរនាស់
ពីព្រេងអតីតា។

1047 សរសើរដំណើរព្រឹក្សា ដុះជិតក្តិតណា ដុះដោយជ្រលង។

1048 ស្មៅស្វាបលាយលេចផ្លូវភ្លង ពោនពួជដូនដង
អន្លាលក្រួចក្រាយ។

1049 ព្រឹងព្រះជន្លួសសព្វសាយ រទោះរលាយ ទន្លាប់ទន្លោ។

1050 វាររវាយដកពាយដកពា ក្រវាន់ទ្រៀលស្វា
សាវម៉ៅផ្អៀកផ្អៅ។

1051 ល្វាដីស្រឡីស្រឡៅ ទ្រៀតត្រាចតត្រៅ
ប្រេចក្រជ្ជយផ្ចឹករាំង។

1052 ខ្លែងគុងនាឆ្នងត្រីលត្រាំង ក្រញូងបែនបាំង
ក្រកោរកែវកោត។

1053 ពានាទាសាផងសោត ហិចហើរលេងលោត
លើមែកព្រឹក្សា។

1054 សរសើរដំណើរអម្រឹគ្គ ដោយជងអធ្វារ ព្រៃព្រឹក្សទូទី។

1055 សត្វផងរើង្កងរកស៊ី ស្រេចផងកាលញី ឆីស្មៅល្បាស់ព្រេច។

1056 ដំណើរគ្រូវដើរលើសលេច ព្រៃនោះបន្តិច
ទៅដល់វាលធំ។

1057 វាលនោះមានអស់ដើមខ្ចំ អស់គ្រូវចតជុំ ជាមួយផងគ្នា។



1058 តោកយាកលំបាកមហិមា មិនមានអាហារ
ភោជភាជន៍ចំណី។

1059 អត់ក្រអង្ករទាំងត្រី បរិភោគប្រក្រតី
ដោយសារអត់ឃ្លាន។

1060 ជីកជាសរបាសពុំបាន ហូបពឹងពុំមាន បបួលគ្នាទៅ។

1061 រកចុងសោមក្នុងព្រៃជ្រៅ ចុងផ្កាវចុងផ្តោល ធ្វើជាសំឡរ។

1062 គ្មានត្រីប្រហុកតរបា នឹងបង់សំឡ សោតសឹងពុំបាន។

1063 បរិភោគទៅតាមដោយឃ្លាន និងលេបពុំបាន
អង្គុយស្ងៀមនៅ។

1064 គ្រូវក្រលំបាកដោយផ្លូវ ដរាបរៀងទៅ មុកឲ្យអនិច្ចា។

1065 បទកាកគតិទៀង រៀបរាប់រាល់រៀង តាមដោយមាត៌ា
កាលមូលចតឈប់ មួប់ខ្ញុំភ្ជុំគ្នា ស្រេចហើយលេលា
ពីនោះទៀតទៅ។

1066 បានដល់ដំណាក់ ស្វាចទូកហើយដាក់ រទេះហើយនិងនៅ
ប្រាំដន្តប់ថ្ងៃ ប្រាស្រៃចេញទៅ ត្រពាំងព្រីងនៅ
បានបីយប់ស្ទោះ។

1067 ទឹពឃ្សូនដល់ដេញ ម្ទឹម្ទារត់ចេញ ពិតពីទីនោះ
ទាំងយប់ទាំងថ្ងៃ ភិតភ័យកាលនោះ រូតរត់ទៅស្ទោះ
ដល់ស្ទឹងតូចឈ្មុប។

1068 សំរាកសំរាន ជើងចតខំខាន បានតែមួយយប់
លំបាកអត់ឃ្លាន មិនមានទាំងគ្រប់ ហើយកាលក្នុងយប់
នោះភ្លៀងខ្លាំងក្រៃ។

1069 និងដើរពុំបាន លំបាកព្រួយប្រាណ ហើយណាស់ល្វិតល្វៃ
ផ្លៀងផ្គរដល់ព្រឹក រលឹកទីទៃ ម្នាក់ៗវែៗ រូតរត់តទៅ។

1070 ដល់ព្រៃអារ៉ង យប់នោះហើយហោង ពុំបានឈប់នៅ
ខ្លាចទឹពឃ្សូនដេញ ដើរចេញទៀតទៅ ទាំងយប់ដល់ហៅ
ឈ្មោះព្រៃទូកខ្ពស។

1071 ពុំបានឈរឈប់ ទាំងថ្ងៃទាំងយប់ ទាំងស្រីទាំងប្រុស

ខិតខំសង្វាត ខ្ទីឃ្លាតទាំងអស់ ចេញពីធ្លកខ្ពស់
ដល់ឈ្មោះព្រៃជាំម។

1072 ព្រៃនោះមានទឹក ចាកឈ្លើងពន្លឹក ច្រើនក្រៃក្នុងជាំ
ហើយមនុស្សដើរដល់ រចលមកខ្លាំង រកាកក្នុងជាំ ទំរាំរួចចេញ។

1073 ពីនោះទៀតទៅ ដល់ព្រៃឈ្មោះហៅ សំឱងក្រញូងមិញ
ពីនោះទៀតទៅ ព្រៃប្រាកស្រែលេច ពីនោះទៀតវិញ
កំពង់ស្រណុក។

1074 រួចចូលព្រៃស្លង ដើរចេញពីក្នុង ព្រៃនោះទៅមុក
បន្តិចទៀតដល់ មណ្ឌលស្រែស្រុក គ្រួចគ្រួរបានសុខ
ធ្វើបុណ្យសប្បាយ។

1075 ដល់នោះស្រុកញិក ចូលសុំរអិក រអែតប្រញ្ញាយ
ចូលសុំអង្ករ មិនក្របានឆ្ងាយ ត្រីសាច់មាំងឆ្ងាយ
បាៈបរិភោគក្ការ។

1076 មួយស្រុកត្រកួន កួនជ្រូកដោយខ្លួន ទីទៃពីគ្នា
ចូលដល់ស្រុកត្លាស របាសសោះសា ខែត្តនោះនាម្មា
ទន្លេរពៅ។

1077 បរបៀតបានដល់ គ្រប់គ្រួររចល់ ចូលចតជិតនៅ
ពីងស្រុកឧកញ្ញា ដេជោមើននៅ ទន្លេរពៅ
នៅសុកសប្បាយ។

1078 យូរបន្តិចទៅ ព្រះពុទ្ធិចៅ ជ្រួតជ្រាបសព្វសាយ
ស្តេចទ្រង់មេត្តា ប្រើខាប្លូងឆាយ នាំទ្រព្យទាំងឡាយ
ចែកចាយគ្រប់គ្រួរ។

1079 ស្តេចទ្រង់ករុណា ប្រទានថ្នាំស្លា អង្ករស្រូវសព្វ
អំបិលប្រហុក ស៊ីចុកស្កុលស្កប់ មិនមានថែថប់
ព្រួយប្រាណជាទុក្ខ។

1080 រីឯគ្រួរគ្រប់ ពុំបានចេញចប់ ដំណើរទៅមុក
ទើបថែងនិយាយ ថែងចាយឯស្រុក ខ្មែរមិញមិនសុក
កាលក្រោយគ្រួរចេញ។

1081 អុងឲ្យលើកទ័ព ទាំងឡាយខ្នាន់ខ្នាប់ មីរមករកដេញ
ខ្មាំងខ្មែរដែលបាស់ កាប់យួននោះមិញ ទ័ពច្រើនពាស់ពេញ



ភពផែនពសុធា។

1082 នាម៉ឺនមន្ត្រី សក្តដប់ប្រាំបី ចក្រីចៅហ្វារ
ក្រហោមយោមរាជ ខ្លាចអុងគ្រប់គ្នា លើកទ័ពទៀបត្រា
ពាស់ពេញព្រៃគួយ។

1083 ខែត្តកំពង់ស្វាយ ពលទ័ពទាំងឡាយ ពុំសល់ស្រុកមួយ
រុករកក្នុងព្រៃ ច្រើនក្រៃរំជួយ ស្ទះសព្វព្រៃគួយ
ឥតឯងកំបាំង។

1084 ពុំឃើញខ្មាំងខ្មែរ ទៅចាប់បានឯ អ្នកដែលភិតភាំង
ភិតភ័យលាក់ពួន លាក់ខ្លួនកំបាំង អាងឯងមិនខ្លាំង
មិនបានរត់ទៅ។

1085 ឯអស់កងទ័ព ឃើញហើយចោមចាប់ យកមនុស្សដែលនៅ
ដោក់ខ្នោះឃ្នាងតោក នាំយកចូលទៅ ជូនអុងឲ្យត្រូវ
គាប់គួរអាត្មា។

1086 អុងឲ្យធ្វើទោស ទុកទ្រុងទាំងអស់ ឥតឯគុន្នា
ទាំងតូចទាំងធំ ផ្សែផ្សំផងគ្នា ប្រមានយកជា
រំលងពាន់បាន។

1087 ទទួលទុក្ខទោស ស្មើធ្លាក់នរក លំបាកអត់ឃ្លាន
ទ្រុងនោះនៅលើ ធ្វើការគ្រប់ប្រាន ជុះនោមលើបាន
តាមចិត្តទីទៃ។

1088 អ្នកទោសក្នុងទ្រុង លំបាកលុះលន់ ទាល់តែក្សិនក្សិយ
និងចាប់ចារថែង សំដែងទោសពៃ ឲ្យអស់ទោសនិយ
អ្នកខ្លាំងពុំបាន។

1089 គ្រាន់តែតិចៗ ឲ្យបានដឹងកិច្ច ដឹងដោយដើមដាន
កាលខ្មែរខ្មាំងបាស់ ទោសណាស់ពុំខ្សាន កុំឲ្យក្មេងមាន
ចិត្តចង់ចូលខ្មាំង។

1090 បើបានបាស់ហើយ កុំនៅនេះឡើយ ក្រែងពុំកំបាំង
ឲ្យចរចេញទៅ ស្រុកក្រៅខ្មែរខ្មាំង ទើបពួនកំបាំង
រួចរុតទីទៃ។

1091 និយាយឯអុង ទៀងគុនធំក្នុង ស្រុកខ្មែរនោះនិយ
ធ្វើទុក្ខអស់ខ្មាំង ផងទាំងទីទៃ ដូចឈើដូចព្រៃ

ឱ្យិណក្ស័យមរណា ។

**1092** ឯអស់មេៗ នាម៉ឺនក្រាំងខ្មែរ អ្នុងឲ្យសេនា យួនយកទៅធ្វើ
អំពើទោសា រោលអាលអាត្មា ដង្កាប់ទាញសាច់ ។

**1093** បញ្ចុងឃីតចេញ កាំបិតមុតមិញ អារកាត់បណ្ដាច់
ហើយយកអំបិល ម្ទេសមកស្រេច ប្រឡាក់សព្វសាច់
ញ័រអស់អង្គាយ ។

**1094** ឈើហើយនិងស្រែក ព្រាត់កៀបស្នើរបែក បំពង់កផ្លាយ
ចំពាមពីមាត់ សឹងព្រាត់សព្វសាយ ខ្ទាន់ឃ្នាបក្បាលវាយ
លៀនភ្នែកទល់ចេញ ។

**1095** ឧស់ឱអនិច្ចា ទោសប្រាំប្រការ ប្រាកដ្ឋច្នេះមិញ
មិនគួចរចាត់ ទោសាថែងចេញ ខ្លាចខ្លួនឯងវិញ
ក្នុងនាលោកិយ ។

**1096** ទោសទៅបរលោក បើបាបមានមក ថ្លស់ធ្លាក់អវចីយ
ជារយពាន់គុន ទោសណាស់ពុំក្សាន្ត កុំឲ្យក្មេងមាន
ចិត្តចង់ចូលខ្ទាំង ។

**1097** ឯអ្នុងឲ្យធ្វើ ទោសនេះពុំស្មើ និងស្ថាននរក់
តែអ្នុងឲ្យធ្វើ អំពើទោសទុក ទាំងឡាយគ្រូបមុក
មិនគួរថែងចាយ ។

**1098** គឺមោះតែថា យកទុកអាត្មា ប្រយ័ត្នអង្គាយ
កាលអ្នុងឲ្យធ្វើ អំពើទាំងឡាយ ខ្លះចាក់ចង់វាយ
ស្វោររោលអស់ក្តី ។

**1099** ឯក្មេងតូចៗ កាប់ត្បូតអាំងដូច អ្នកផងអាំងត្រី
ខ្លះទាញសន្ទីរ ឲ្យតឹងទាំងបី ក្បាលមូលមកខ្ចី
ធ្វើជាជើងក្រាន ។

**1100** ហើយគិតយកភ្លើង បង្កាត់នោះឡើង យកដែកបានស្វោរ
កូនក្មេងមានទោស ទាំងអស់ប៉ុន្មាន ខ្លះដឹកដីបាន
ធ្វើជារណ្តៅ ។

**1101** ទម្លាក់អ្នកទោស ក្នុងនោះទាំងអស់ ហើយលុបដីទៅ
យកភ្លើងបង្កាត់ ពីមាត់រណ្តៅ ភ្លើងឆេះប្រាលឆ្នៅ
ល្ហះល្ហោចជាផែះ ។



**1102** កាលអ្នុងឡើងគុន ធ្វើទោសទម្ងន់ នគរយើងនេះ
តាមចិត្តចិន្តា ប្រាជ្ញាចំណេះ ស្រេចហើយរមិះ
រៀបស្រុកវិងវិញ ។

**1103** ឲ្យរៀបកើរកាយ នៅគ្រប់បន្ទាយ ដូចដើមនោះមិញ
ស្លៀកពាក់ខោអាវ ហាវហៅពាស់ពេញ ឯសាសន៍ខ្មែរមិញ
មិនមានសូនសោះ ។

**1104** ខ្លះចូលតែខ្លួន ស្លៀកពាក់ដូចយួន ខ្លាចបុណ្យគេស្មោះ
ខ្លះចូលទាំងចិត្ត គំនិតក្នុងពោះ ឯសាសន៍ឯងនោះ
មិនមានសង្ស័យ ។

**1105** វីអ្នុងឡើងគុន ប្រាជ្ញាធំលន់ លោពលេបអស់ផ្ទៃ
ក្រោមក្រម្ភារា ដូចមហានាគនៃ លេបលបពស់ផ្សៃ
ជិពាក់ករឡើយ ។

**1106** ឡើងគុនសព្វថ្ងៃ ចិត្តចង់គ្រង់ផ្ទៃ ក្រោមនេះឯងហើយ
បំបាក់នាម៉ឺន មន្ត្រីជាត្រើយ បានដូចចិត្តហើយ ឥតឯសង្ការ ។

**1107** ឡើងគុនគិតយល់ តាមដោយយោបល់ គំនិតប្រាជ្ញា
ថាល្វង់ពីរពង្ស ស្តេចគង់នៅនា ឯក្រុងទេពមហា
នគររាជស្ថាន ។

**1108** ជញ្ជីងគុនគិត រិះរកគំនិត ធ្វើម្ដេចឲ្យបាន
ឲ្យមូលមកអាយ ឧបាយរិះធ្យាន កម្រយកបាន
ដូចដោយចិន្តា ។

**1109** បទពំនោលនៅចរចា ឯក្រុងទេពមហា នគរបូរីរាជស្ថាន ។

**1110** ជាហេតុបទបុណ្យបូរាណ ក្រុងកម្ពុជាមាន
បូរាណបូរីថ្កើងថ្កាន ។

**1111** ឡើងគុនកាចលង់ចចើង កាច់កិនស្រុកយើង
មិនបានបទបុណ្យសាស្នា ។

**1112** ជាហេតុចែដន្យទេព្តា ព្រះចៅយុធ្យា
ទ្រង់ព្រះករុណាអង្គល្វង់ ។

**1113** ថាចៅអង្គអិមអង្គឌួង បង់ស្រុកទាំងពួង

មកនៅនិងអញយួរហើយ ។
1114 មិនមានប្រយោជន៍អ្វីឡើយ យល់ថាឥតត្រើយ
សូន្យសោះអាសារឥតការ ។
1115 ពុំសូវសុកចិតចិន្តា បើច្នេះគួរនា តែអង្គអញគិតឲ្យចេញ ។
1116 ទៅនៅស្រុកក្រៅនោះវិញ ឯទៅទៀបអញ
នៅមិញមិនសូវសប្បាយ ។
1117 គិតស្រេចគំនិតយល់ឆ្ងាយ ទើបក្សត្រពន្រាយណ៍
ឲ្យតែងបន្ទូលទៅខ្មី ។
1118 ត្រាស់ប្រើខាល្វងទាំងពីរ រៀបស្រុកដោយទី
ឲ្យល្វងទាំងពីរស្ដេចគ្រង ។
1119 សឹងមានអាករគ្រប់អង្គ គេគិតអាស្រ្វង
ចេញចូលចុះឡើងគាល់ហ្មៅ ។
1120 ល្វងម្ចាស់អង្គឌួងស្ដេចនៅ ស្វាយចិក[1] ប្រែហៅ
ថាមឿងមង្គល់បូរីយ ។
1121 ចៅហ្វាយស្រុកទាំងប្រកដី ចុះឡើងឃ្មាតខ្មី
គាល់ក្សត្រធិបតីឥតអឹក ។
1122 ឯល្វងអង្គអិមវៀមរ័ក្ខ ស្ដេចគង់ដំណាក់ នៅបាត់ដំបងវិញខ្មី ។
1123 សឹងមានខែត្តឡើងប្រក្រតី ចេញចូលដោយទី
គ្រប់ល្វងទាំងពីរអង្គារ ។
1124 កាលក្រោយព្រះរាមរាជា អង្គចន្ទក្សត្រា
សុគតរលត់ទៅខ្មី ។
1125 អង្គទៀងគុនធំនោះក្ដី ឲ្យរាជបុត្រី អង្គម៉ីគ្រងរាជជាស្ដេច ។
1126 យួរយល់បីបួនឆ្នាំស្រេច ឯពីពង្សស្ដេច
ក៏ប្រែចេញចរមកក្រៅ ។
1127 ឮលេចពាក្យពេចដល់ទៅ ទៀងគុនដែលនៅ
ភ្នំពេញនោះមិញអសល់[2] ។
1128 វាគិតគំនិតយុងយល និងធ្វើកិច្ចកល
យោបលបញ្ឆោតស្ដេចមក ។

[1] Il faut lire ស្វាយចេក [svay chék].

[2] Il faut lire អរសល់ [â sâl] "très heureux".



1129 ស្រុកខ្មែរនិងប្រែរិះរក ធ្វើសំបុត្របក
ថាមកច្បាំងផងចាប់បាន ។
1130 គិតយល់កិច្ចកលគ្រប់ប្រាណ ប្រើយួនដែលបាន
ចេះខ្មែរនឹងប្រែប្រែទៅ ។
1131 ទៀងគុនធំលុនឲ្យហៅ បាសាខ្វារ[1] នៅ
ទាសាររចេរចាឲ្យឆាប់ ។
1132 ទាសារទាំងពីរបានស្ដាប់ រៀបខ្លួនប្រញាប់
មកតាមបង្គាប់អង្គឯង ។
1133 អង្គយល់មកដល់ដាក់ស្ដែង បង្គាប់ថាអែង
ចេះខ្មែរប្រែភាសាអាត្មា ។
1134 កោក្បាលជាសៀមម្ទីម្ភ្រា ស្លៀកពាក់ម្ដេចម្ដា
ដូចផ្កាអ្នកស្រុកនេនោយ ។
1135 ហើយចូលប្លែមប្លមលលាយ និងគេអ្នកនាយ
និយាយឲ្យបានចូលដល់ ។
1136 ទៀងគុនធំលន់គិតយល់ បង្គាប់កិច្ចកល
យោបល់ប្រាជ្ញាឲ្យថា ។
1137 យួនពីរបានដឹងកិច្ចការ ជាអ្នកទាសា
ប្រាជ្ញាចែងចេះបកប្រែ ។
1138 ចេះទាំងអក្សរសាសខ្មែរ ចេះបកចេះប្រែ
ពាក្យខ្មែរពាក្យសៀមយួនផង ។
1139 ផ្ដាំស្រេចពាក្យពេជប្ដូរផ្គង់ ចរចេញទៅហោង
ដល់បាត់ដំបងស្ដេចគុង ។
1140 ចូលដល់មណ្ឌល់ទីក្នុង អង្គអិមស្ដេចគុង
តម្រង់ចូលថ្វាយបង្គំ ។
1141 ទាសាចៀវថាអញខ្ញុំ មកថ្វាយបង្គំ
សូមអញ្ជើញស្ដេចចេញទៅ ។
1142 ដ្បិតព្រះវៀមរ័កចោមចៅ ស្ដេចសុគត់ទៅ
នៅតែព្រះភគនិយា ។

[1] Il faut lire បាសាខាវ [basa khav] "traducteur, messager".

1143 អង្គឲ្យគ្រប់គ្រងរាជា ជួសព្រះបិតា
យើញថានឹងសូន្យស្លាត់បាត់។
1144 អង្គឲ្យអញ្ជើញមហាក្សត្រ ទៅគ្រងសម្បត្តិ
រាស្ត្ររដ្ឋត្រកូលពង្សា។
1145 អង្គឲ្យអភិសេកក្សត្រា គ្រប់គ្រងរាជា
និងលាល្វងទៅស្រុកវិញ។
1146 ឯល្វងអង្គអិមនោះមិញ ស្ដេចស្ដាប់ពាក្យពេញ
ព្រះទ័យអរក្រៃកន្លង។
1147 ថាពាក្យពិតពេកឥតហ្មង ព្រះទ័យចូលផង
ផ្លូវផ្គងកំម្មិតគិតស្រេច។
1148 ទាសារពីរលាអង្គស្ដេច ចាកចេញចរត្រាច់
ទៅដល់មង្គល់បូរី
1149 ក្រាបទូលដូចដើមសេចក្ដី ពាក្យពេចអ្វីៗ
ដូចបាននិទានមកស្រាប់។
1150 អង្គឧងល្វងឮសារសព្ទ ពាក្យទាសារប្រាប់
ក្រាបទូលពុំចូលចិន្ដា។
1151 ថាឲ្យអាចៀវអាខ្វារ ពាក្យអង្គឯងថា
ឲ្យអញទៅគ្រងរាជនោះ។
1152 ពាក្យភូតបញ្ឆោតទេសោះ មិនមែនដូច្នោះ
ពាក្យនេះពាក្យភូតអញទេ។
1153 ទាសារពីរស្ដាប់ស្ដេចជេរ ពុំដឹងបើរេ
រិះគិតទូលពិតម្ដេចបាន។
1154 ក្រងក្រាបលាចុះស្មោះស្មាន ចរចេញចាកស្ថាន
ពុំហ៊ាននៅនាក្រៃងឆ្គង។
1155 ឯល្វងអង្គអិមជាបង ចិន្ដាទំនង ប៉ងមកកាច់កិនអានុជា។
1156 ទូលទៅព្រះចៅយុធ្យា ថាព្រះអនុជា
គិតក្បត់នឹងរត់ចូលយួន។
1157 ឯអង្គអានុជនឹងនួន ពិតពុំដឹងខ្លួន
ជួនគ្រោះនិងត្រូវទោសារ។
1158 កាលនោះព្រះចៅយុធ្យា ពុំជ្រាបកិច្ចការ



ប្រើខាល្វងមកយកទៅ។
1159 ធ្វើទោសតាមខុសពុំត្រូវ ហេតុស្ដេចពុំជ្រៅ
ពុំជ្រាបនូវអស់កិច្ចកល។
1160 ក្រោយនោះល្វងអង្គអិមយល់ ដំណើរយោបល់
បញ្ឆោតបាឡាត់ព្រះនរិន។
1161 ថាលាទៅថតកចិន ឯវត្តភ្នៀតមួយភ្លែតសិន
សិមវិលវិងវិញជាឆាប់។
1162 គេដឹងដំណើរល្វងប្រាប់ មុន្និលទោសស្រាប់
គេកែនប្រញាប់ម្នីម្នា។
1163 ឲ្យចាំនៅពាមបាក់ព្រា ព្រះនរិនឲ្យឆាប់
យួនយកមកសួររាជការ។
1164 ជួបនិងគេចាំជិតផ្លូវ គេឃាត់ស្ដេចទៅ
វិលទៅដំណាក់នោះនៃ។
1165 យូរយល់ប្រមានដប់ថ្ងៃ ស្ដេចព្រួយព្រះទ័យ
វិយគិតគំនិតយល់ឆាប់។
1166 ស្ដេចមានព្រះបន្ទូលប្រាប់ ព្រះនរិនឲ្យចាប់
យួនយកមកសួររាជការ។
1167 ដ្បិតព្រះពុទ្ធិចៅផ្ដាំថា ឲ្យខំគិតការ
រក្សាផ្ទៃក្រោមរាស្ត្ររាក់។
1168 ឲ្យចាប់យួនយកបានម្នាក់ មកសួរឲ្យជាក់
ឲ្យយល់កិច្ចកល់ផ្ទៃក្រោម។
1169 ព្រះនរិនស្ដាប់ស្ដេចត្រាស់ព្រម ត្រឹមត្រូវឥតល្មម
ទាំងល្វងកុំញាននោះផង។
1170 ព្រះភូនម៉ាគិតកែនកង យករអស់រាស្ត្រផង
ពីរបាត់ដំបងបីរយ។
1171 ទុកតែបាឡាត់មួយឲ្យ ចាំខែត្តឯងក្រោយ
រក្សាស្រុកឲ្យសុកសាន្ត។
1172 ព្រះនរិននូវល្វងកុំញាន ព្រះភូនម៉ាបាន
ចេញទៅដឹកផ្លូវពីយប់។

1173 ដល់ភ្នំតាផ្ដិ[1] ហើយឈប់ ក្រោយនោះលុះយប់
លួងខ្ចប់បាឡាត់ចាប់បាន។
1174 ហើយផាត់ត្រូវគ្រប់គ្រឹះស្ថាន ក្នុងខែត្តប៉ុន្មាន
យកទោសស្មើរអស់ពីស្រុក។
1175 ផាតត្រូវចរចុះទូកដុក ស្ដេចចេញឆ្ពោះមុក
មកស្រុកខ្មែរដើមដូនតា។
1176 ហើយចាត់ប្រើអស់សេនា នាហ្មឺនព្រះពញា
មហាត្លឹកផាតត្រូវជើងគោក។
1177 ពីបាត់ដំបងយកមក ប្រះទេះនិងលោក
ព្រះនរិនព្រះភុនម៉ាផង។
1178 នៅភ្នំតាផ្ដិ[2] នោះហោង អស់មហាត្លឹកផង
ប្រាប់ថាប្រពន្ធអស់លោក។
1179 លួងគិតឲ្យផាត់យកមក[3] បើច្នេះអស់លោក
នឹងគិតដូចម្ដេចគិតចុះ។
1180 ព្រះនរិន្ទស្ដាប់ពាក្យអស់នោះ ក្ដៅក្លួលក្នុងពោះ
ល្វេះល្វោចស្ទើរបែកឱរា។
1181 ខំតែឆ្លើយទៅវិញថា បើច្នេះអស់គ្នា
ស៊ីស្លានិយាយរមិះ។
1182 អង្គអញនិងនៅៗនេះ ធ្វើម្ដេចដូច្នេះ
អញទៅតាមលួងស្ដេចដែល។
1183 មហាត្លិកលួងយល់ប្រហែល ចូលជាគ្នាក្រៃល
អរងងអង្គុយឈប់ស្មោះ។
1184 និយាយភ្លេចខ្លួនកាលនោះ ព្រះនរិនឯងស្មោះ
ដោះភ្លើងហើយស្រែកប្រាប់ថា។
1185 ពះក្មេងកនយើងគ្រប់គ្នា កាប់អស់សេនា
មហាត្លិកលួងចេញកុំទុក។
1186 ព្រះពញាគ្នាគេគគ្រុក ចូលចោមក្រោយមុក

---

1 Il faut lire ធិបតី [thipadey].

2 *Idem.*

3 Ce passage est omis par l'éditeur de la version imprimée *Rœang robat khsat srok khmê*, vol. II, p. 136.



សំរុកខ្ចប់កាប់ឥតសល់។
1187 ស្លាប់អស់ទាំងនាយទាំងពល់ ព្រះនរិនឯងយល់
កងគៀរកងត្រូវរឹងរឹយ។
1188 កាលនោះព្រះនរិនឯងចេញ យកទូកងមិញ
មកតាមទាល់ពាមព្រះស្ទឹង។
1189 ពុំទាន់លួងភ្លើយខេរខឹង គុនគិតរំពឹង
វិលវិងទៅស្រុកឯងស្មោះ។
1190 និយាយឯទៀងគុននោះ វាដឹងចំពោះ
ថាស្ដេចចូលស្មោះមកដល់។
1191 ពោធិសាត់វាគិតប្រើពល យួនខ្មែររចល់
ទៅដល់គៀរមកប្រញាប់។
1192 បានដល់ភ្នំពេញបង្គាប់ ប្រោះយុតការខ្ចាប់
មុកជ្រោយចង្វារនោះនៅ។
1193 វានាំលួងភ្លើងៗទៅ ដល់អ្នុងហើយហៅ
សួរទៅរាជការគ្រប់មុក។
1194 ហើយវាចាត់គ្នាដាក់ទូក ឲ្យនាំទៅស្រុក
យួនទុកទីព្រៃនគរ។
1195 លួងគិតដូច្នេះអង្វរ ថាខ្ញុំចង់ចរ
សួរក្មួយត្រើយពោធិព្រះបាត។
1196 បំណាច់មកដល់សាច់ញាត្ត ខិតខំសង្វាត
ខ្មីឃ្មាតមកដល់កេរកោះ។
1197 រីឯអ្នុងភ្លើងគុននោះ វាដឹងដូច្នេះ វាខឹងគំរោះជេរថា។
1198 ឲ្យពលសុកលយោធា ធ្វើទោសក្សត្រា
ហើយវានាំយកទៅស្មោះ។
1199 ដល់ថ្នាញព្រៃនគរនោះ ប្រកាន់ប្រកេះ
ស្ដេចនោះក្នុងថ្នាញនិងនៅ។
1200 ស្រេចហើយវាគិតឲ្យហៅ នាម៉ឺនបីទៅ
ហៅហើយជុំនំរាជការ។
1201 ឲ្យធ្វើសំបុត្តបោះត្រា ថាអង្គអិមជា
ខ្មាំងច្បាំងចាប់បានក្នុងទ័ព។

1202 គិតស្រេចហើយបោះត្រាខ្ទាប់ ទើបប្រើប្រញាប់
ឲ្យចូលទូលស្ដេចទេព្ដា ។

1203 តាមដោយដំណើរអក្ខរា ទើបស្ដេចទេព្ដា
ឲ្យសារសូត្រស្រាយថ្វាយស្ដេច ។
1204 ចើលាយសូត្រស្រាយថ្វាយស្ដេច រីឯអង្គស្ដេច
ស្ដាប់ហើយទើបទូលត្រាស់ថា ។
1205 ឲ្យអស់អាមាត្យម្ទីម្នា មកយកក្សត្រា
អង្គអិមបាឡាត់នោះផង ។
1206 ចូលទៅដល់ស្ដេចដូចប៉ង បន្ទូលនោះផង
ថាអើរអង្គអិមឥឡូវ ។
1207 បទអុងទៀងគុនឈ្មោះលៅ ដែលអញប្រើទៅ
ឲ្យទៅរក្សាស្រុកខ្មែរ ។
1208 គេបកសំបុត្រមកហ្វែរ និងនាហ្មឺនខ្មែរ
ចៅហ្វាវក្រហោមយោមរាជ ។
1209 គេថាអង្គអិមឯងកាច តាំងទ័ពមិនខ្លាច
អាជ្ញាច្បាំងនិងគេចាប់បាន ។
1210 បើច្នេះចំណាំអង្គប្រាន ច្បាំងគេចាប់បាន
ឬមានប្រការថាម្ដេច ។
1211 ឯល្វងអង្គអិមស្ដេចស្ដាប់ ទើបទូលរំពេច
ថាខ្ញុំពុំបានច្បាំងទេ ។
1212 ខ្ញុំនិករញូកមកឯ នគរស្រុកខ្មែរ
គិតកែរចាបគយម្ហូយផង ។
1213 បាឡាត់រាស្ត្របាត់ដំបង ឲ្យខ្ញុំយកមកផង
ចងជាបន្ទាល់ទោសា ។
1214 រីឯអង្គស្ដេចទេព្ដា មិនមានសង្ការ ដើរចូលចិន្តាស្មោះស្មាន ។
1215 ទើបប្រើបំរើមកថ្កាន អុងភ្លើងគុនបាន
យកអស់នាម៉ឺនបីទៅ ។
1216 ក្នុងឆ្នាំជូតទោស័កនៅ ខែជល្គុនទៅ
បានដល់ស្រុកហ្វេរដូចថា ។



1217 ទើបឯអង្គស្ដេចទេព្ដា បន្ទឹងសួរថា
ចៅហ្វាវក្រហោមយោមរាជ ។
1218 ឯងស្មោះបោះត្រាកតគៀច ថាអង្គអិមកាច
គេច្បាំងហើយចាប់យកបាន ។
1219 ឥឡូវអង្គអិមស្មោះស្មាន ឆ្លើយថាពុំបាន
មកច្បាំងដូចថានោះទេ ។
1220 ហេតុបទរញូកស្រុកខ្មែរ ជាកិច្ចកោះគេ
គេរូតចូលមកចិត្តឯង ។
1221 ចូលឆ្លើយដោយត្រង់កុំក្រែង តាមចំណាំឯង
ដូចម្ដេចក៏ថាទៅចុះ ។
1222 នាម៉ឺនបីឆ្លើយវិងស្មោះ ថាល្វងកាលនោះ
និងបានមកច្បាំងក៏ទេ ។
1223 ខ្លាចបុណ្យទៀងគុនគិតកែ សំបុត្របកប្រែ
ដូច្នេះឲ្យបោះត្រាតាម ។
1224 ទើបស្ដេចទេព្ដាគំរាម ជេថាឯងតាម
ព្រោះខ្លាចបុណ្យនេះពុំត្រូវ ។
1225 គិតកាចស្ដេចម្ចាស់ឯងកូវ ដូច្នេះមិនត្រូវ
យកទៅប្រែហ្វាសចោលក្នុងកោះ ។
1226 ស្ដេចមានបន្ទូលដូច្នេះ ឲ្យនាំចេញស្មោះ
ប្រែហ្វាសកោះត្រឡាចនោះឯង ។
1227 ហើយស្ដេចឲ្យដោះទោសលេង ល្វងអង្គអិមឯង
មកគុងក្នុងថ្នាញស្ដេចនោះ ។

1228 បទកាគិតតែង ដំណើរដំណែង ដំណាលកាលនោះ
កាលបុណ្យឡើងគុន កាចប៉ុនពីគ្រោះ ចាប់ស្ដេចយើងនោះ
បញ្ជូនចាកស្ថាន ។
1229 ចាប់លោកចៅហ្វា សម្ដេចចៅពញា ក្រឡាហោមបាន
ថ្វាយស្ដេចទេព្ដារ យូរជាប្រមាន ដប់ថ្ងៃទើបបាន
បំរើប្រើទៅ ។

1230 ទូលល្បងក្សត្រី ព្រះនាមអង្គមី អង្គប៉ែននោះនៅ
ព្រះរៀមអនុជ ទាំងប្អូនអង្គទៅ ដល់ថ្នាញហើយហៅ
ឃាត់នៅនោះខ្ជាប់។

1231 អស់រូបក្សត្រី ទាំងប្អូនពិសី ពីសេសស្រៀបស្រាប់
ខ្លាចទៀងគុនឯង វាតែងបង្គាប់ ថាឲ្យទៅផ្ទាប់
មិនឲ្យទៅឆ្ងាយ។

1232 ក្រោយនោះទៀតវា តក[1]ត្រាហូតងារ នាម៉ឺនទាំងឡាយ
ហូតគ្រឿងដកមនុស្ស ចេញអស់អន្តរាយ ធ្វើឲ្យធ្លល់ឆ្ងាយ
គោកគាំងគំនិត។

1233 វាធ្វើពុំទាន់ វាធ្វើឲ្យភាន់ ឲ្យឯងទុកចិត្ត ពុំដឹងបទវា
វាធ្វើឲ្យស្និត វានិងបំផ្លាត់ បំផ្លាញនគរា។

1234 លុះថ្ងៃប្រាំបី កើតកបរស្មី ភទ្របុតមាសា វារិះប្រញាប់
បង្គាប់ពលវា រៀបទូកម្ទីម្ទា និងនាំស្ដេចទៅ។

1235 អាសូរក្សត្រថ្លៃ ពុំជ្រាបព្រះទ័យ ជាយួនឃោឃៅ
បំណងនាំស្ដេច ត្រេចត្រង់នាំទៅ លុះលង់លំនៅ
នគរយួននោះ។

1236 ឯក្សត្រប្អូនអង្គ ពុំដឹងចាកបង់ មន្ទីទៅឆ្ងាយ
រីឯអ្នងឯង វាតែងកួល់ខ្វាយ ប្រើយួនយើងអាយ
ជាអ្នកបាសា។

1237 ចូលគាល់អាប់ក្រែ អញ្ជើញក្សត្រថ្លៃ ចុះទូកម្ទីម្ទា
លុះស្ដេចទៅដល់ មណ្ឌលស្ថានវា វាឃុំរាជា បំបែកទីទៃ។

1238 ឯអង្គល្អងម្ចាស់ ព្រះរៀមច្បងច្បាស់ វាឃុំខ្ជាប់ក្រែ
ឃាត់ទុកក្នុងថ្នាញ ផ្ទាលផ្ទាញទោសពៃយ លុងលុះក្សិណក្ស័យ
ជីវិតមរណា។

1239 ក្សត្រីអង្គមី វានាំត្រេចត្រង់ ទៅស្ដេចទេព្ដា
ឯក្រោយវិញទៀត វាបៀតបន្ទា ប្រពន្ធចៅហ្វារ
សម្ដេចក្រហោម។

1240 ថាវាបង្គាប់ រៀបខ្លួនប្រញាប់ ដៀវចុះចេញព្រម

[1] Il faut lire ដក [dăk] "enlever"



វាឲ្យគ្នាវា ចុះទូកទៅក្រោម ប្រពន្ធក្រហោម
សម្ដេចបានទៅ។

1241 ប្រពន្ធចៅហ្វា នាំខ្ញុំអាត្មា រូតរូតចេញក្រៅ
រូតភ្លើងគោកស្មោះ ស្ទើរកោះគេហៅ ស្លាកេតនោះនៅ
រួចតែអាត្មា។

1242 របស់ក្នុងទូក បានយួនវាយក ទៅជាទ្រព្យវា
វាអន្សាដុក ដន្លងផងគ្នា ដុកនោះនៅនា ភូមិចាក់អង្រែ។

1243 ចម្លងយកទៅ ដល់ផ្ទះគាត់នៅ ហើយគាត់គិតប្រែ
រត់ចេញចូលព្រៃ ប្រាស្រ័យរេះរេ ចោលផ្ទះទទេ
ឥតមនុស្សនិងនៅ។

1244 ឯទៀងគុននោះ វាគិតដូច្នេះ ប្រើយួនឲ្យទៅ
ចោមព័ទ្ធផ្ទះជុំ ហើយហ៊ុំពីក្រៅ ប្រើគ្នាភ្លើងទៅ
រកមនុស្សមិនមាន ។

1245 យួនយកអស់ទ្រព្យ គ្រប់គ្រឿងប្រដាប់
ដែលចោលនោះបាន យុកភ្លើងដុតឆេះ ជាផែះគ្រឹះស្ថាន
ស្រេចហើយទើបបាន ទៅផ្ដិងរ្សូងវា។

1246 ក្រោយនោះបន្តិច ទៀងគុនធ្វើស្ដេច បានដូចចិន្ដា
ហើយគិតចង់ចាប់ ឈ្មោះហឹងធ្វើជា ឧទ័យទ្រាជ្ញ[1] ខាង
សំរោងទងនោះ។

1247 វាគិតចាត់ប្រើ ឲ្យអស់បំរើ ទៅយកមកស្មោះ
ឧទ័យទ្រាជ្ញដឹង ដំណើរដូច្នេះ ពុំព្រមទៅសោះ
ប្រឹងប្រែងគំនិត។

1248 តាំងទីពម្ទីម្ទា បំផាយអសុពា ររកវិះគិត
កាប់យួនទាំងឡាយ ស្រុកឆ្ងាយស្រុកជិត តាមដោយគនត
ឫស់បានគ្រប់គ្នា។

1249 ឯទៀងគុនយួន យល់គេគិតគួន មិនខ្លាចអាត្មា
ចាប់ប្រើពូលពល សុកលយោធា យមរាជរដ្ឋជា
នាម៉ឺនខ្មែរទៅ។

www.amelkhmer.org

[1] Il s'agit de ឧទ័យធិរាជ [outeythiréach], titre du gouverneur de la province de Sâmraong Tông

1250 ចោមចាប់ដែលវា ឈ្មោះហីងធ្វើជា ឧទ័យប្រាជ្ញនៅ
ខេត្តសំរោងទង បំណងអ្នងលៅ ស្មានជាចេញទៅ
ចោមចាប់យកបាន។
1251 យោមរាជរដ្ឋទៅ ទីមកណ្ដាលផ្លូវ ឃើញពួកទាហ៊ាន
សេនាយោធា គេជាធំស្ពាន និងចាប់មិនបាន
ត្រឡប់វិលវិញ។
1252 ជំរាបអ្នងលៅ ទ្វៀងគុនដែលនៅ នាថ្នាញភ្នំពេញ
ដឹងដើមដូច្នេះ ឲ្យចុះទូកចេញ ទ័ពទឹកនោះមិញ
ទៅកំពង់ឆ្នាំង។
1253 ពុំឃើញពួកពល ដើងទឹកនិងទល់ និងទប់តតាំង
ឲ្យថយទ័ពទឹក ឥតភ្ញីកកិតកាំង ពីកំពង់ឆ្នាំង
ទៅគៀនស្វាយវិញ។
1254 ប្រទះនិងទ័ព ធម្មាប៉ុកចាប់ ចាំនៅនោះមិញ
ច្បាំងបាញ់កាំភ្លើង គេឡើងគោកវិញ ពុំហ៊ានលើកដេញ
ថយចេញប្រញាប់។
1255 មកដល់ភ្នំពេញ ហើយឡើងទៅថ្នាញ ប្ដឹងអ្នងឲ្យស្ដាប់
អ្នងឯងបានដឹង ដំណើងសារសព្វ ឲ្យរាប់ប្រញាប់
ទូកបាយដប់មួយ។
1256 គ្រប់គ្រឿងប្រដាប់ កាំភ្លើងព្រួងស្រាប់
ស្រេចមិនមានព្រួយ មានទាំងកែណៃវ ដេញគ្រូវប្រាំមួយ
ទូកបាយដប់មួយ លើកទ័ពចេញទៅ។
1257 បានដល់គៀនស្វាយ អ្នងឲ្យទូកពាយ ទីមទន្លេក្រៅ
យកទូកកែណៃវ ចែវដេញគ្រូវទៅ តាមពាក្យអ្នងលៅ
ឲ្យទៅតាមគ្រូវ។
1258 ឯអ្នងធំនៅ ឲ្យអ្នងតូចទៅ តាមដោយបឹងប្លូវ
ចូលទៅក្នុងបឹង នឹងរកចាប់គ្រូវ ក្រែងជ្រកបឹងប្លូវ
ពឹងពាក់អាត្មា។
1259 ទ័ពទន្លេក្រៅ ឡើងគុនឈ្មោះលៅ ឲ្យអស់ពលវា
បាញ់កាំភ្លើងធំ ស្រទំមេឃា ត្រូវគ្រងសាលា
វត្តគៀនស្វាយក្នុង។



1260 ជួបទ័ពធម្មា ប៉ុកពុំរួញរា សឹងចិត្តចូលចង តតាំងច្បាំងគ្នា
បរទៅអំឡុង ពីព្រឹកល្ងះគ្រង់ ចងចូលឃុតគ្នា។
1261 ធម្មាប៉ុកគាត់ ចង់ចូលឡោមព័ទ ទូកទើបកាប់គ្នា
យួនដឹងដំណើរ វាគិតនិងគ្នា ចែវចេញម្ដីម្នា
ទន្លេក្រៅវិញ។
1262 ជួបនិងអ្នងធំ ប្រមូលពលជុំ ចេញមកភ្នំពេញ
រាជដេជះនង ប៉ងគិតរត់ចេញ ពិតពីភ្នំពេញ
ទៅត្រើយបាភ្នំ។
1263 ជួបនិងធម្មា ប៉ុកពិតគិតគ្នា ប្រមូលពលជុំ
សំនួនមួយពាន់ ប្រាំរយជុំនំ គ្នាស្រេចអ្នងធំ ភ្នំពេញចេញខ្ចី។
1264 ទ័ពរាជដេជះ ច្បាំងផងមិនឈ្នះ រត់ទៅផ្លូវត្រើយ
ហួសឡើងបាភ្នំ អ្នងធំឃ្នាតឃ្មើ វិលពីផ្លូវត្រើ
មកគៀនស្វាយវិញ។
1265 ទ័ពធម្មាប៉ុក នោះចាំនៅស្រុក គៀនស្វាយនោះមិញ
រីឯទ័ពយួន រៀបខ្លួនលើកចេញ ឡើងគោកនោះមិញ
តតាំងច្បាំងគ្នា។
1266 ធម្មាប៉ុកកាប់ ពលឈ្លោះផងស្លាប់ ប្រមានគន្នា
ហាហុកសិបនាក់ បាក់ទ័ពរអា ថយចេញម្ដីម្នា
មកថ្នាញវាវិញ។
1267 រាជតេជះនង ទៅគិតកេនកង ពួកពលនោះមិញ
បានពលពីរពាន់ គ្រប់គ្រងចរចេញ មកទល់ទ័ពវិញ
ឯពោធិព្រះបាទ។
1268 ជួបនិងធម្មា ប៉ុកពលពាន់ហា រយរិះសង្វាត
ប្រមូលពលគ្នា ធ្វើការខ្មីឃ្មាត នៅពោធិព្រះបាទ
ទល់ទ័ពយួនយក្ស។
1269 ឯអ្នងទៀងគុន ខ្ញុំខឹងពេកពន់ ពីពលបាតបក្រ[1]
ទ័ពទៅឯថ្នាញ នោះមិញអស់អ័ក្ខ វិតក្កយចិត្តយក្ស
ពិតពីឆ្ងាយគ្នា។

[1] Il faut lire បាត់បាក់ [bat+bak] "perdre+casser" qui signifie "être battu".

1270 ឲ្យលើកទ័ពចេញ ចាកពីភ្នំពេញ ពលពាលសេនា
ទូកហាយកៃណែវ ចែវចេញត្រៀបត្រា ទៅទល់ទ័ពគ្នា
ធម្មាប៉ុកនោះ ។
1271 ហេតុអ្នងឡើងគុន ខឹងចិត្តពេកពន់ ឲ្យបាញផ្លោងផ្លោះ
ស្វរសព្ទសន្ទឹក ពន្លឹកកាលនោះ ស្មើនិងផ្គាយផ្ទះ
កោះពោធិព្រះបាទ ។
1272 ទ័ពរាជដេជោ ធម្មាប៉ុកបាស់ ពុំបានឃ្លាឃ្លាត
ចាកចេញពីនោះ ប្លេកផ្លោះខ្ទីឃ្នាត បាតជើងសព្រាត
ព្រមប្រហែសឯង ។
1273 ឯទ័ពយួនដេញ ទូកទៅឃ្មាតខ្វាញ បន្តិចវាលេង
វាវិលទៅថ្នាញ ភ្នំពេញនោះឯង ពុំបានថ្លាថ្លែង
សង្វេបខានទុក ។
1274 ទើបទៅនិយាយ អស់អារទាំងឡាយ ពិតពីខែត្តស្រុក
សៀមបាត់ដំបង ខ្មែរផងចុងស្រុក កាលកើតអ្នកលុក
ល្ហងផាតព្រាត់ព្រាយ ។

1275 បទពំនោលនៅចែងចាយ បែបទនិយាយ
កាលពីឆ្នាំជូតទោស័ក ។
1276 កាលនោះហ្លួងអង្គអិមអាក់ ព្រះទ័យឋ្នាំងថ្នាក់
រៀមរាក្សអានុជស្នួនគ្រង ។
1277 ស្តេចរូកខ្វាត់ចេញវិញហោង ផាត់ទាំងគ្រួរផង
ពីបាត់ដំបងស្ងួនស្វាត់ ។
1278 ហើយចាប់ទាំងពញាបាឡាត់ យកមកខ្វាយខ្វាត់
ពីបាត់ដំបងនោះឯង ។
1279 ឯក្រោយគេឲ្យចាត់ចែង ជុំនំគ្នាឯង
ក្រែងមានមន្ទិលទោសា ។
1280 ព្រះពិធាក់វជិននាមា ព្រះនរិនយោធា
ធ្វើងាររក្សាខែត្តនោះ ។
1281 ជួបជុំជុំនំពិគ្រោះ ដំណើរអស់នោះ និងធ្វើសំបុត្រប្តឹងមក ។



1282 ឯល្ហងអង្គអិមគិតឆ្លត រត់ទៅខ្មែរយក
បាឡាត់ហើយជាត់គ្រួរផង ។
1283 ដូច្នេះទោសនេះយល់ឆ្អង មន្ទិលសៅហ្មង
និងល្ហងធូលីពុទ្ធិចៅ ។
1284 សំបុត្រចំរើដល់ទៅ ចៅយួនធំនៅ
ទៅទូលព្រះចៅយុធ្យា ។
1285 ស្តេចបានដឹងដានអក្ខរា មានព្រះឱង្ការ
ថាឲ្យចៅយួនរៀបរង ។
1286 ចេញមកឈរបាត់ដំបង យកក្រម្ការផង
ទៅរងបន្ទូលថ្លៃថ្លា ។
1287 ព្រះពិធាក់វជិននាម្រា ព្រះនរិន្ទយោធារ
ព្រះអង្គម៉ាជាបន្ទាប់ ។
1288 ស្នារាជគុជេនឯកប្រាប ដេជោអស់ស្តាប់
ទៅរ៉ាបបន្ទូលតាមគេ ។
1289 ចៅយួនធំលុនថាឯ នគរស្រុកខ្មែរ
អារអ្នងឡើងគុនឈ្មោះលៅ ។
1290 វាយកល្ហងអង្គអិមទៅ ស្រុកខ្មែរឲ្យនៅ
សោយរាជឬនាំទៅយួន ។
1291 ដូច្នេះអស់ឯងគ្រប់ខ្លួន រកមនុស្សមាំប្អូន
ទាំងយួនទាំងខ្មែរដឹងផ្លូវ ។
1292 ដឹងស្រុកដឹងព្រៃប្រើទៅ ឆ្ពោររាជការនៅ
ឲ្យដឹងដំណឹងស្រុកខ្មែរ ។
1293 បើយួនជូនល្ហងទៅហ្វេរ[1] យើងនេះក្នុងខែ
កត្តិកគិតសិកកែនកង ។
1294 លើកទ័ពទៅចាប់ស្រុកផង ឲ្យអង្គឌួងគ្រង
រាជរាំកពិភ័ក្រស្រុកខ្មែរ ។
1295 កាលនោះនាម៉ឺនឯងឯ អោយឲ្យរើសខ្មែរ
បានតែពីរនាក់នោះខ្ញី ។
1296 មនោយ៉ុងពួកដែជោអិ រាជអាជ្ញាក្តិ

[1] Ville de Huè, capitale de l'Annam.

ឈ្មោះគុងពួកលោកនរិននង ។
1297 រើសស្រេចផ្ដាំផ្ដេចពាក្យផង នៅបាត់ដំបង
ហ្នត់ហ្មងមិនមានសង្ការ ។
1298 ហើយធ្វើសំបុត្របោះត្រា អស់គ្រប់ក្រមការ
លាលោកចៅយុនមករាយ ។
1299 បានដល់ខែតកំពង់ស្វាយ ហួសមកបារាយ
សួរសើរដំណើររាជការ ។
1300 បង្ហាញសំបុត្របោះត្រា ដែលសើបរាជការ
ឲ្យលោកចៅហ្វាដេជះ ។
1301 ដេជោរស់រួជងពីរនាក់ ឃើញសំបុត្តដាក់
ហើយបកសំបុត្តប្តឹងវិញ ។
1302 តាមដោយរាជការនោះមិញ បំរើវិលវិញ
ទៅដល់ចៅយុនធំថា ។
1303 តាមដោយដំណើរអក្ខរា សំបុត្របោះត្រា
ចៅហ្វាដេជោគ្រប់ស្រាប់ ។
1304 ឯលោកចៅយុនបានស្ដាប់ អស់អារសារស័ព្ទ
ក៏បកបំរើប្រើទៅ ។
1305 ក្រាបទូលសម្ដេចពុទ្ធិចៅ ស្ដេចបានជ្រាបជ្រៅ
ដោយនូវដំណើរសេចក្ដី ។
1306 សម្ដេចពុទ្ធិចៅចក្រី ស្ដេចឲ្យដោះក្ដី
អង្គឌួងល្ងង់រួចចេញស្មោះ ។
1307 ស្រេចហើយជុំនំពិគ្រោះ ធ្វើរាបសាំងនោះ
ស្មោះមកចៅយុនធំថា ។
1308 ឲ្យចាត់ក្រុមមឿងមុខងារ កែនកងយោធា
ធ្វើការសង្គ្រាមរឿនរុង ។
1309 ជ្រើសអស់សេនាពលពង្ស ចេញទៅទាល់ក្នុង ក្រុងកម្ពុជាបុរី ។
1310 ដេញយួនយក្សទ្រីស្ដដេរថី កៀបកាចអប្រិយ
ឲ្យបានបូរីយរាជស្ថាន ។
1311 ឲ្យល្ងង់អង្គឌួងក្សត្រក្សាន្ត សោយសម្បត្តិបាន
ឲ្យក្សាន្តឲ្យក្សេមសេមា ។



1312 គ្រប់គ្រងក្រុងកម្ពុជា ពលពង្សយោធា
សេនានៅរាស្ត្រទាំងឡាយ ។
1313 ស្ដេចតាំងរាប់សាំងសព្វសាយ ឱ្យនក្សត្រពន្រាយ
ត្រាស់ប្រើលើពញាយោមរាជ ។
1314 ជូនល្ងង់អង្គឌួងឯងអាជ្ញ ទើបពញាយមរាជ
ទទួលបន្ទូលឱង្ការ ។
1315 ហែរល្ងង់អង្គឌួងក្សត្រា ចេញមកដល់ពញា
បឌិនដេជះជាញជ័យ ។
1316 ខ្មែរហៅចៅយុនភូយៀ ក្សត្រសង្គ្រាមជ័យ
ក៏ក្រាបទទួលរាបសាំង ។
1317 ឱង្ការត្រាស់ប្រើឲ្យតាំង ទ័ពតាមរាប់សាំង
សម្រាំងសម្រេចរាជការ ។
1318 កេនកងក្រុមមឿងភពភារ ភិតភ័យមហិមា
ខ្លាចព្រះអាជ្ញាស្មើរគ្រូន ។
1319 រីឯអង្គលោកចៅយុន ជាធំលើសលន់
គន់គិតចែកទ័ពទាំងឡាយ ។
1320 មេកងធំកំពង់ស្វាយ ចាត់មេចាត់នាយ
ចៅហ្វាយនគរសៀមរាប ។
1321 សឹងមានដេជានុភាព នគរសៀមរាប ឲ្យតាំងជាមេកងធំ ។
1322 ព្រះណាយខាល្ងងបន្សំ គ្រប់មឿងតូចធំ
ភ្ជុំចេញជួយយកអាសារ ។
1323 ផ្លូវទឹកកំពតនោះពញា ក្រហោមជាតិជា
មេកងធំជ័យដោយមុក ។
1324 ឯផ្លូវជើងគោកសំបុក សោតសិងដាក់ទុក
ដោយមុកដោយប៉ែកទីទៃ ។
1325 ឯលោកចៅយុនភូយៀ នគររាជនៃ
នៅចោមជើងគោកពោធិសត្វ ។
1326 សឹងមានវាញវាន់ប្រយ័ត្ន ក្នុងខេត្តពោធិសត្វ
នោះឈ្មោះត្រលោមានជាញ ។
1327 យួនវានៅនានោះមិញ ចៅយុនគិតដេញ

បញ្ឆោតដោយកល់ដោយភ្លឹក ។

1328 ឲ្យម៉បរដីរីសិក ព្ធូសព្វសន្ទឹក គគឹកជុំជាញនោះឯង ។

1329 យួនវាតក្កមាស្ងប់ស្ញែង ថាទីពនេះឯង
ច្រើនណាស់គេចាក់ជុំវិញ ។

1330 គិតយល់កល់នោះរត់ចេញ ទាំងយប់នោះមិញ
ចូលថ្នាញធំផ្សាពោធិសត្វ ។

1331 ឯលោកចៅឃុនឲ្យពីទ ពីក្រៅច្រើនក្លាត់
ហើយគិតលើកសិនជុំថាញ ។

1332 យប់នោះលុះព្រឹកឡើងវិញ សិននោះឯងវិញ
ប្រាំមួយអន្លើធ្វើស្រេច ។

1333 ចំងាយឆ្ងាយទៅបន្តិច ប្រមាណពុំស្រេច
ស្រែធំបន្តិចទើបស្មើ ។

1334 លុះព្រឹកយួនយល់សៀមធ្វើ សិនជុំច្នេះប្រើ
អស់កីបិញបាញ់ទំលាយ ។

1335 វាបាញ់ពីថ្នាញខ្ជូខ្ជាយ បាញ់ចេញទំលាយ
មិនធ្លាយមិនធ្លាសិនឡើយ ។

1336 ចៅឃុនយល់យួនចាញ់ហើយ បាញ់វិញពុំស្បើយ
ពុំស្រាកពុំស្រាន្តស្មើដៃ ។

1337 ស្មើរអស់រំសេវទីទៃ បាញ់លុះស្មើដៃ
ដូចភ្លៀងរលឹមគ្មានស្រាក ។

1338 ទើបលោកចៅឃុនមានពាក្យ ថាបាញ់គ្មានស្រាក
ដូចច្នេះនិងគិតម្តេចវិញ ។

1339 ឲ្យធ្វនឲ្យយួនវាចាញ់ បើច្នេះឯងអញ
ចង់រកគំនិតគិតប្រែ ។

1340 ទើបអស់នាម៉ឺនសៀមខ្មែរ ពុំមានអ្នកឯ
ណានិងរំពឹងយល់ម្តេច ។

1341 កាលនោះម្នាខ្មែរមួយលេច យោបលកល់កិច្ច
បន្តិចទើបចូលជំរាប ។

1342 គាត់នោះនាមឈ្មោះចៅចាប ចូលទៅជុំរាប
តាមដោយគំនិតនោះខ្មី ។



1343 ធ្វើងារជាឃុនភក្តី កិច្ចការអ្វីៗ
ឃុំងយោលសេចក្តីពុំឆ្ងល់ ។

1344 ជំរាបផ្តីងដោយយោបល់ ថាខ្ញុំគិតយល់
ធ្វើកល់ឲ្យវាចុះចាញ់ ។

1345 ឲ្យកាត់ដើមចិក[1] នោះមិញ សូវសុកឲ្យពេញ
នៅក្នុងប្រហោងកាំភ្លើង ។

1346 ដង្កាប់ចាប់គ្រាប់នៃយើង ដុតទៅជាភ្លើង
នោះឡើងក្រហមច្រកវិញ ។

1347 រីឯកាំភ្លើងនោះមិញ សំរុកបញ្ចូញ
ក្នុងថ្នាញនិងឆេះមិនលេង ។

1348 ចៅឃុនស្តាប់ពាក្យនោះឯង យល់ត្រូវហើយតែ
គំនិតនោះឯងបាញ់ទៅ ។

1349 ឯគ្រាប់ក្រហមច្រាលឆ្អៅ បាញ់ធ្លាក់ចុះទៅ
ឆេះនៅក្នុងថ្នាញអស់ផង ។

1350 លុះព្រឹកអស់យួននោះឯង វាគិតតាក់តែង
ប្រើក្មេងកាត្តចាតចេញខ្មី ។

1351 ពីនាក់ស្លៀកពាក់ផងក្តី ក្រហមថ្មីៗ
ហើយកាន់ទង់ដែសរចេញ ។

1352 មកឈរឯក្រោយថាញវិញ ហើយវាស្រែកពេញ
សំឡឹងប្តីងលោកជាត្រើយ ។

1353 ថាអ្នងសូមចាញ់លោកហើយ កុំលោកបាញ់ឡើយ
អ្នងសូមទទួលចុះចាញ់ ។

1354 ឯលោកចៅឃុននោះមិញ ឲ្យស្រែកទៅវិញ
ថាបើសុំចាញ់ដូច្នេះ ។

1355 ឲ្យចងគ្រឿងសិកទាំងនោះ នាំមកជូនស្មោះ
ហើយអ្នងទាំងនោះចូលមក ។

1356 និយាយនិងអញហើយយក ទាំងគ្រឿងនោះមក
កុំឆ្លកឆ្អៀកវៀចវេរ ។

[1] Il faut lire ចេក [chêk] "bananier".

1357 វាវិលទៅវិញរមរិះ និងគ្នាសម្រេះ
ហើយចងគ្រឿងគ្រប់ប្រដាប់ ។
1358 កាំភ្លើងធំតូចផ្ទផ្ទាប់ គ្រប់គ្រឿងប្រដាប់
មកជូនចៅយួនធំស្មោះ ។
1359 ហើយអ្នងទាំងបីនាក់នោះ ចរចូលចំពោះ
មកហៅចៅយួនធំឯង ។
1360 ឯអង្គចៅយួនយល់ស្តែង ហើយថាអ្នងឯង
គិតក្រែងខ្លាចអញឬទេ ។
1361 ឯអ្នងទាំងបីរិះរេ ឆ្លាស់ឆ្លើយថាឯ
យើងខ្ញុំនេះខ្លាចលោកហើយ ។
1362 ឯអង្គចៅយួនធំឆ្លើយ ថាបើខ្លាចហើយ
ដូច្នេះជួយច្បាំងទើបត្រូវ ។
1363 ឯអ្នងទាំងបីនោះគួរ ឆ្លាស់ឆ្លើយវិញទៅ
បើច្នេះលោកឲ្យប្រដាប់ ។
1364 មកយើងនិងជួយវាយទ័ព យួនវិញឲ្យឆាប់
បាក់បែកបានស្រុកលោកវិញ ។
1365 ឯលោកចៅយួននោះមិញ ព្រមបើកឲ្យវិញ
ទុកតែប្រដាប់គ្រឿងខ្មែរ ។
1366 ចៅយួនសួរទៀតថាឯ ទៀងគុនគិតប្រែ
កាប់សម្លាប់ខ្មែរច្រើនម្ល៉េះ ។
1367 ចាប់ស្តេចនាម៉ឺនទាំងនេះ នណាគិតរិះ
ដូច្នេះគំនិតអ្នកណា ។
1368 ផ្ទើងឯងឬស្តេចទេព្តា អស់អ្នងនោះថា
គេគិតគំនិតខ្លួនគេ ។
1369 អង្គស្តេចមិនដឹងសោះទេ អស់យើងទាសគេ
មិនបានបទបុណ្យតូចណាស់ ។
1370 គេធំប៉ុនគ្នាមិនទាស់ អស់យើងតូចណាស់
និងទាស់គេពុំបានឡើយ ។
1371 អ្នងថាច្នេះលាព្រងើយ លោកបើកទៅហើយ
ប្រើព្រះនរិនជូនស្មោះ ។





1372 ដល់ទៅលំនៅវានោះ វាចេញចែវចុះ
ស្មោះទៅភ្នំពេញព្រងើយ ។
1373 ពុំបានជួយច្បាំងលោកឡើយ វាចូលទៅហើយ
ទៅហៅឯអ្នងទៀងគុន ។
1374 រីឯអង្គលោកចៅយួន ធំធ្ងន់សក់បុណ្យ
ក៏ចេញចោមពីទបន្ទាយ ។
1375 ពលពង្សចតុរង្គទាំងឡាយ រឹងអាប់ស្មើរផ្កាយ
ភពផែនដែនដីស្រុកខ្មែរ ។
1376 ដំរីសេះសោតសឹងតែ ច្រើនក្រៃបង្វែរ
មកឯទ្វារស្រុកសព្វសាយ ។
1377 ពលពាស់ពេញពីទបន្ទាយ ទ្វារស្រុកទាំងឡាយ
វាយខ្ទាយបែកបាក់សព្វថាន ។
1378 យួនច្បាំងតតាំងពុំបាន ស្លុតស្លាប់ទាហ៊ាន
សេនាអាសារច្រើនក្រៃ ។
1379 រីឯអង្គយួនកូយៀ រិងរិតជាញជ័យ
រើយដៃដេជះចេស្តា ។
1380 ផ្កាញយួនមមើត្រៀបត្រា ដោយដែកវិទ្ធិ
ឥតណានិងពារប៉ះបាន ។
1381 ទើបយួនខ្លាចខ្លួនពុំហ៊ាន រត់ចេញចាកស្ថាន
បន្ទាយទាំងឡាយនោះមិញ ។
1382 ចូលដល់មណ្ឌលភ្នំពេញ អ្នងទៀងគុនមិញ
ក៏ចេញទល់ទ័ពសៀមនោះ ។
1383 ចៅយួនធំលន់លើកបោះ កងទ័ពទាំងនោះ
ឯលិចឧដុង្គមានជ័យ ។

1384 បទព្រហ្មាគិតកាប់ កាលពីទ័ពខ្មែរនោះន័យ
ចៅហ្វាយស្រុកទីទៃ កែនកំឡាំងបានគ្រប់គ្នា ។
1385 ហើយលើកទ័ពទាំងឡាយ ខែត្តជិតឆ្ងាយ មកត្រៀបត្រា
ទោះបូកបញ្ជីការ ពលសំនួនប្រាំពាន់នៃ ។

1386 នៅនាម៉ឺនតាលាំង  ត្រៀមទ័ពចាំយួនចម្រៃ
ប្រមាណបានបីថ្ងៃ  យួននោះនៃវាប្រើទៅ។
1387 ប្រាប់ទ័ពពួកឯខ្មែរ  ថាឲ្យប្រែប្រយ័ត្ននៅ
ថ្ងៃស្អែកអ្នកឲ្យទៅ  ច្បាំងឲ្យដឹងរិទ្ធិចេស្តា។
1388 ទើបទ័ពពួកឯខ្មែរ  គិតប្រាប់ប្ដេជ្ញាំវិញថា
អ្នកឯងមកចុះណា  កុំរួញរាខ្លាចយើងឡើយ។
1389 ក្រោយនោះនាម៉ឺនខ្មែរ  គិតប្រាប់ផ្ដែផ្ដាំច្នេះហើយ
ពុំលង់បង្អង់ឡើយ  ជាន់អារ័ក្ខលំពែងជ័យ។
1390 សួរថាយួនលើកទ័ព  តាមវាប្រាប់មកនោះនៃ
ឬវាភូតបំភ្លៃ  បំភ្លាត់ឲ្យខុសគំនិត។
1391 អារ័ក្ខចូលជាន់ផាំង  ធ្វើងេងងាងតាំងគួនគិត
បន្តិចថាមកពិត  ដូចវាគិតថានោះហោង។
1392 សួរទៀតថាបើច្នេះ  បន្ទាយច្រុះជារបង
ដូច្នេះនិងទប់ផង  កងទ័ពយួនបានឬទេ។
1393 អារ័ក្ខថាកុំឲ្យ  មានចិត្តព្រួយគិតរិះរេ
ធ្វើយើងមិនបានទេ  យើងធ្វើគេបានវិញស្មោះ។
1394 សួរស្រេចហើយទើបគិត  ដោយគំនិតទ័ពទាំងនោះ
ដល់មាន់រងាវក្រុះ  ពុំដឹងសោះយួនចូលមក។
1395 វាចូលខុសល្បាតឯង  ពុំគិតក្រែងហើយចូលតក្វ[1]
ចំរូងគោះប៉កៗ  ឮសព្ទមកដល់ឯងជាក់។
1396 អស់មេកងទ័ពខ្មែរ  ឮហើយប្រែសួរអារ័ក្ខ
លំពែងជ័យស្ដាប់ជាក់  ថាសព្ទគ្រោះនោះទ័ពយួន។
1397 វាតក្វចំរូងហើយ  កុំគិតឡើយអស់គ្រប់ខ្លួន
កុំខ្លាចទ័ពអាយួន  វាធ្វើខ្លួនពុំបានទេ។
1398 ទើបអស់នាម៉ឺនឯង  សួរលំពែងជ័យថាឯ
កាំភ្លើងយើងទំនេរ  និងបាញ់គេទៅឬម្ដេច។
1399 លំពែងជ័យឆ្លើយថា  កុំអស់គ្នាបាញ់រំពេច  ចាំថ្ងៃរះបន្តិច
លិចស្មើឈើប្រើចាំនៅ។

[1] Il faut lire ដក [dăk] "enlever".



1400 លុះព្រឹកព្រាងស្រាងស្រេច  ភ្លឺភ្លើងលេចមៀងមើលទៅ
ក្រហមច្រើនច្រាលឆ្នៅ  មីរដេរដាសសឹងពលយួន។
1401 វាបាញ់កាំភ្លើងធំ  តូចរងំមករកខ្លួន  ដំរីឯអ្នកយួន
បង្អិនកាច់បន្ទាយខ្មី។
1402 អារ័ក្ខលំពែងថា  ឲ្យអស់គ្នាយកឫស្សី  សំរួចចាក់ដំរី
ដើមចង្ការវាប្រាសចេញ។
1403 អស់ពលកងទ័ពជាក់  ពាក្យអារ័ក្ខថាច្នេះមិញ
គិតចាក់ដំរីវិញ  វាប្រាសចេញទៅក្រៅស្មោះ។
1404 យួនយល់ដំរីវា  ខ្លាចរួញរារត់ដូច្នេះ  ចោមចាក់ដំរីនោះ
វាវិលគេចព្រេចវិងវិញ។
1405 យួនស្លាប់ដោយដំរី  វាវក់វីព្រេចនោះមិញ
បាហុកសិបទើបបាញ់  កាំភ្លើងចេញទៅត្រូវបាន។
1406 កាំភ្លើងធំកងទ័ព  ខ្មែរច្រកគ្រាប់ក្រួសរវាន់
ចេញទៅត្រូវយួនបាន  ដោយប្រមានសែសិបឮយ។
1407 យួនយល់គ្នាវាស្លាប់  បន្ថយទ័ពចេញឆ្ងាយ
ហើយអូសខ្មោចទាំងឡាយ  យកទៅដុតអស់ឥតសល់។
1408 ហើយប្រើអស់គ្នាវា  សង់សាលាប្រក់នូវផ្ដល់
រមិលមើលទៅយល់  ជាចំងាយដោយប្រមាន។
1409 ជាស្រែយើងធំពីរ  ពេញក្រមុំប្រាំមួយបាន
ស្រេចហើយវារិះធ្យាន  រើសក្មេងបានទាំងពីរនាក់។
1410 ក្មេងនោះធ្វើកិច្ចការ  តាមច្បាប់វាឲ្យស្លៀកពាក់
ក្រហមទាំងពីរនាក់  កាន់ទង់ជ័យសដើរចេញ។
1411 មកប្រាប់នាម៉ឺនខ្មែរ  ឲ្យរិះរេរកមនុស្សមិញ
បានពីរនាក់ទៅវិញ  និយាយគ្នានៅសាលា។
1412 បទអ្នកទៀងគួនធំ  គិតជុំនំនិងសូមលា
ទៅស្រុកវិញហើយណា  លែងច្បាំងគ្នានិងលាសិន។
1413 កាលនោះនាម៉ឺនខ្មែរ  ចាត់ប្រើងពេជចន្លួន
គាត់នោះរស់របាន់  ហើយទាហានគ្មានពីរសោះ។
1414 យកបាវទៅកំដរ  ក្រែងក្រក្រគ្រាន់ជួយដោះ
ប្រាំពីរនាក់ចិត្តនោះ  សិងស្មើស្មោះឥតសង្ស័យ។

www.ameKhmer.org

**1415** ពេជង់ងដើរគយា ដូចសីហារនារនិសភ័យ
ដើរដល់យួនហើយន័យ ឡើងសាលាវាំងព្រះដើយ ។
**1416** ជាមួយនិងអ្នងយួន ពុំភិតខ្លួនដល់តិចឡើយ
ផ្អែកផឹកស្រាព្រះដើយ ហើយពុំទាន់ជំនុំការ ។
**1417** កាលនោះអាវិទ្ធិម៉ា មានគំនិតគិតពុំជា
ចង់ឲ្យយួននោះវា សំឡាប់គ្នាឯងនោះមិញ ។
**1418** អាវិទ្ធិចាត់កូនក្មួយ ពីរនាក់ឲ្យលបលម្ពេញ
ទៅដល់យួនហើយបាញ់ ស្លាប់កូនក្មួយអស់ពីរនាក់ ។
**1419** ឯពេជចន្លននោះ ដឹងដូច្នេះឡើងមើលជាក់
ហើយស្ទុះលោតទម្លាក់ ពីសាលាយាត្រាទៅ ។
**1420** កាលនោះអ្នងទៀងគុន ធំលើសលន់នាមឈ្មោះលៅ
ឲ្យបាញ់បន្ដោយទៅ ត្រូវជង្គង់ពេជដួលចុះ ។
**1421** កូនក្មួយប្រាំពីរនាក់ ស្ទុះកន្ទ្រាក់សែងចេញស្មោះ
រត់រួចពីទីនោះ បានដល់ទៅទីពង់ងវិញ ។
**1422** ទើបពេជស្រដីថា ចាត់ប្រើការងឲ្យចេញ
ទៅដល់យួនហើយបាញ់ វាខឹងវិញហើយសម្លាប់គ្នា ។
**1423** នាម៉ឺនពួកអាងង ឆ្លើយប្រកែងថានណា
ទៅបាញ់ដូច្នេះណា យើងគ្រប់គ្នាមិនដឹងទេ ។
**1424** ឯអ្នងទៀងគុននោះ ចរចេញស្មោះនាំពលរេ
កងទ័ពចូលទៅឯ ចាញក្នុំពេញវិញព្រះដើយ ។
**1425** និទានវេនេះទៀងទេ ពិតពីខ្សែពីរមកហើយ
ដល់បុណ្យយួននិងសៀម គិតរៀបរត់ទៅស្រុកវា ។
**1426** ប្រចាប់ប្រជួបចង តាមទម្ងន់កម្ពុជា
ពិតពុំពោលពានពា ហៅខ្សែបីបរិបូណ៌បាន ។

ចប់ខ្សែ ៣

ចម្លងតាមសាស្ត្រាវត្តក្រូច ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម